អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jul-2013, 13:43
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី២០៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡៃ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកកែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ស្ទីវ ហេដឌ័រ (TCE-33) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស៊ីវ ហេងឌុំ** (TCE-33)

សួរបន្តដោយលោក ឃីត រេយ៍ន័រ ផ្តើមពី..............................................................ទំព័រ ១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មសាក្សី ស្ទីវ ហេដឌ័រ ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

នៅថ្ងៃនេះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ស្ទីវិន ហេដឌ័រ ហើយលោកមានវត្តមានរួចហើយក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស្ទីវ ហេដឌ័រ។ សូមអញ្ជើញ!

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរមេធាវីការពារ និងភាគីទាំងអស់ ហើយនិងជម្រាបសួរលោកសាក្សី លោក ហេដឌ័រ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំសូមអនុញ្ញាតចាប់ផ្តើម សូមឲ្យលោកបំភ្លឺនូវបញ្ហាមួយចំនួនទាក់ទងទៅនឹងសក្ខីកម្មរហូត

មកដល់ចុងថ្ងៃម្សិលមិញ។ លោកនៅចាំហើយ លោកបានបញ្ជាក់អំពីសេចក្ដីដកស្រង់មួយចំនួនពីឯកសារ E3/1714 ទាក់ទងទៅនឹងបទសម្ភាសន៍ជនភៀសខ្លួននៅឆ្នាំ១៩៨០ និងឯកសារយោងទៅអ្នកសម្ភាសម្នាក់ ឡុង ឈ្មោះ ឡុង គឺខ្លឹមសារនិយាយអំពីការដកចេញប្រជាជនពីខ្មាំង។ អំពីជាពាក្យស្លោករបស់សម័យនោះ។

[០៩:០៥:១៥]

ទាក់ទងនឹងបញ្ហានេះ លោកបានឮពីមនុស្សភាគច្រើនក្នុងរយៈពេលជាច្រើនឆ្នាំ។ លោកបានឮពីអានេះមុនឆ្នាំ១៩៧៥ តាមការផ្សាយវិទ្យុផងដែរ។ គឺជាវិទ្យុផ្សាយសំឡេងដែលខ្ញុំចង់សួរលោកបន្តឲ្យលោកបំភ្លឺ។ តើលោកអាចបំភ្លឺតុលាការបានទេ តើក្នុងបរិបទអ្វីដែលឃ្លាដែលគេថា “ដកប្រជាជនរំដោះប្រជាជនចេញពីខ្មាំង” នោះ គឺអ្វីជាកម្មវត្ថុ ហើយអ្វីជាបរិបទដែលគេប្រើឃ្លាបែបនេះ?

**លោក ស៊្មីវ ហេដឌ័រ៖**

**ឆ៖** ឃ្លានេះយោងទៅរកស្ថានភាពដែលមានការប្រទាញប្រទង់យកការត្រួតត្រានូវប្រជាជន ហើយនិងជាសញ្ញានៃឃ្លានេះគឺថា ទោះបីជាមានវិធានការនយោបាយ ឬយោធាក្ដី គឺសមាមាត្រនៃចំនួនប្រជាជននៅក្រោមការគ្រប់គ្រងរបស់ខ្មាំងតាមពាក្យរបស់ខ្មែរក្រហមត្រូវតែបន្ថយ ដើម្បីឲ្យខ្លួនបានគ្រប់គ្រង ហើយជាវិធីគឺដើម្បីដកប្រជាជនយកទៅកន្លែងមួយទៅដាក់នៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហមនោះឯង។

[០៩:០៧:០៤]

នេះហើយដែលគេយកប្រជាជនពីតំបន់ដែលត្រួតត្រាដោយខ្មាំង យកទៅដាក់តំបន់រំដោះជាបណ្ដោះអាសន្ន ហើយយកទៅកន្លែងមួយផ្សេងទៀត។ នេះគេបង្ហាញថាជាពាក្យស្លោកមួយដែលគេត្រូវតែយកទៅអនុវត្ត ហើយគេលើកទឹកចិត្តឲ្យប្រជាជនចាកចេញពីតំបន់ដែលកាន់កាប់ដោយខ្មាំង ហើយឲ្យចូលទៅតំបន់រំដោះរបស់គេ។ នៅក្នុងទិន្នន័យបទសម្ភាសន៍ទាំងមុន ហើយនិងក្រោយខែមេសា ឆ្នាំ១៩៧៥ កាលណាខ្ញុំនិយាយថាបន្ទាប់នោះ គឺនិយាយចុងឆ្នាំ១៩៧០ រហូតដល់ទសវត្សរ៍ឆ្នាំ៨០។ ពាក្យថា “ការជម្លៀស” ហើយពាក្យថា “ដកប្រជាជនជាបណ្ដោះអាសន្ន” នេះក្ដី យើងឃើញថាតាមដែលខ្ញុំចាំនៅក្នុងបទសម្ភាសន៍នោះ គឺយើងការជម្លៀសនោះគឺថាច្រើនតែធ្វើឡើងដោយការបង្ខិតបង្ខំ។ យើងអាចយោងទៅរក គឺថាអ្នកដែលទទួលការបញ្ចុះបញ្ចូលតាមនយោបាយឲ្យចេញពីតំបន់ខ្មាំងទៅតំបន់រំដោះនោះ គឺអាចថាក៏តែងតែយោងទៅរកទៅការកាន់កាប់ដោយយោធាទៅតំបន់នោះ ហើយគេដកប្រជាជន

មួយក្រុម ហើយគេបញ្ជូនទៅតំបន់រំដោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមរំឭកលោក ស៊ីវ ហេងឆ័រ បន្តិចថា អង្គជំនុំជម្រះកោះអញ្ជើញលោកមកផ្តល់សក្ខីកម្ម គឺនិយាយឲ្យអង្គជំនុំជម្រះស្តាប់។ អ៊ីចឹងសូមឲ្យលោកសម្រួលនូវឥរិយាបថរបស់លោក ក្នុងន័យថាលោកនិយាយនេះ គឺនិយាយឲ្យអង្គជំនុំជម្រះស្តាប់។ បានន័យថាការបង្ហាញនូវការនិយាយស្ដីមុខហ្នឹងគឺបែរមុខមកអង្គជំនុំជម្រះ គប្បីជាការសមស្របជាង។ សូមលោកយល់ទេ? លោកសម្រួលឥរិយាបថក្នុងការនិយាយហ្នឹងគឺនិយាយឲ្យអង្គជំនុំជម្រះស្តាប់។

សូមអញ្ជើញបន្តលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:០៩:២៧]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំចង់សួរសំណួរទៅលោក លោកសាក្សីអំពីហេតុការណ៍ដែលលោកបានដឹងផ្ទាល់អំពីក្រុងឧដុង្គ ហើយនិងកំពង់ចាម។ ឥឡូវនេះយើងនិយាយពីខេត្តកំពង់ចាម លោកនិយាយក្នុងខែកញ្ញា ឆ្នាំ ១៩៧៣ ទាក់ទងទៅនឹងការជម្លៀសនៅក្នុងកំពង់ចាមនោះ ទីរួមខេត្តកំពង់ចាម តើលោកបានទទួលព័ត៌មានអ្វីអំពីអ្នកផ្តល់សម្ភាស ថាតើការជម្លៀសដោយស្ម័គ្រចិត្ត ឬក៏ជាការជម្លៀសដោយបង្ខំដែរឬទេ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** មុនពេលដែលគេហៅ ហើយនិងគេឲ្យអ្នកទាំងអស់នោះចាកចេញនោះ គឺគេហៅថាសមាសភាពអ្នកនៅទីនោះ។ ខ្ញុំមិនបាននៅទីនោះទេ បន្ទាប់ពីមានហេតុការណ៍នោះ។ បាទ បើសិនជានៅឧដុង្គវិញ គឺថាមានហេតុការណ៍ចប់ភ្លាម ខ្ញុំបានទៅដល់ភ្លាម ប៉ុន្តែនៅទីនោះ ខ្ញុំអត់បានទៅទេភ្លាមៗ។ តាមដែលខ្ញុំចាំ គឺមនុស្សមួយចំនួនរៀបរាប់ថា មានការបង្ខំឲ្យចាកចេញ។ ហើយអ្នកខ្លះក៏បានត្រឡប់មកកន្លែងនោះវិញ ប៉ុន្តែអ្នកផ្សេងទៀតរៀបរាប់វាមិនជាស្ម័គ្រចិត្តទេ ក៏ប៉ុន្តែខ្លួនឯងចង់ទៅ ដូចជាមានអ្វីថាគួរទៅចេញ។ អ្នកខ្លះដែលជាមនុស្សដែលភៀសខ្លួន ភៀសសឹកពីកន្លែងមួយទៅកន្លែងកាលណោះ ហើយចូលមកទីរួមខេត្តកំពង់ចាម ដោយមូលហេតុមួយចំនួនកាលណោះ ហើយក៏ដូចមានឆន្ទៈចង់ត្រឡប់ទៅកន្លែងដើមដែលគេ ជាស្រុកកំណើត ឬកន្លែងដើមដែលគេមកនោះវិញ។ អានេះគឺតាមដែលខ្ញុំចងចាំ។

[០៩:១១:៤៨]

**ស៖** សំណួរដូចគ្នានេះដែរ ទាក់ទងទៅនឹងឧដុង្គដែលលោកបានទៅដល់នោះ ខែមីនា ឆ្នាំ១៩៧៤ ទាក់ទងទៅនឹងថាតើការជម្លៀសដោយស្ម័គ្រចិត្ត ឬក៏ដោយបង្ខំ?

**ឆ៖** តាមអ្វីដែលខ្ញុំចាំនឹកឃើញនោះ គឺថាខ្ញុំបានទៅ១ថ្ងៃ ឬក៏២ថ្ងៃ។ ខ្ញុំមិនបានធ្វើការសម្ភាសលម្អិតពិស្តារនោះទេ។ អ៊ីចឹងចំពោះសេចក្ដីលម្អិតហ្នឹង ខ្ញុំមិនបាន -- ព័ត៌មានខ្លះមិនបានពិនិត្យឡើងវិញ ខ្ញុំមិនអាចឆ្លើយបញ្ជាក់ឲ្យច្បាស់ពីគំនិតនេះទេ។

**ស៖** ទាក់ទងទៅនឹងឧដុង្គ លោកនិយាយថា ឧដុង្គហ្នឹងគឺបានក្លាយទៅជាទីរហោឋាន បានន័យថា គ្មានមនុស្សរស់នៅ។ តើពាក្យនោះ លោកអាចបន្ថែមអ្វីបានទៀតទេ?

**ឆ៖** នៅពេលដែលខ្ញុំបានទៅដល់ឧដុង្គ ទីក្រុងគឺមើលទៅគ្មានមនុស្សនៅច្រើនទេ ដូចជាទីរហោឋាន គឺថាមានមនុស្សមួយចំនួនតូច។ បាទ គឺអ្នកទាំងនោះ អ្នកជៀសពីការជម្លៀសរបស់គេកាលណោះ។ គេបានដកខ្លួនចេញពីដំណើរការជម្លៀស ហើយលាក់ខ្លួន ឬក៏ហើយក្រោយក៏បានមកនៅទីនោះ។ ក្រៅពីអ្នកហ្នឹងគឺមិនមានអ្នកណានៅទេ។ នៅពេលដែលខ្ញុំទៅដល់ ហើយខ្ញុំបានឃើញសាកសពដូនជី មិនព្រះសង្ឃ ហើយមិនមានអ្នកណានៅទីនោះទេ មានតែសាកសពទេ មិនមានអ្នកណានៅរស់នៅលើតំបន់ដែលខ្ញុំទៅដល់ កន្លែងដែលខ្ញុំទៅដល់ទេ។ ទីក្រុង ហើយនិងវត្ត គឺទទេរគ្មានមនុស្សនៅ។ បាទ គឺមើលទៅឃើញទទេរ អត់មានអ្នកណានៅទេ។

[០៩:១៣:៥២]

**ស៖** សំណួរចុងក្រោយម្សិលមិញរបស់ខ្ញុំ គឺនិយាយអំពីការជម្លៀស។ បាទ ការជម្លៀសទីក្រុងភ្នំពេញ ហើយយើងបាននិយាយអំពីសៀវភៅកំណត់ដែររបស់ ប៉ុន។ ខ្ញុំចង់សួរលោកនៅក្នុងសំណុំឯកសារនេះ។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ជូនសំណុំឯកសារ ដែលយើងបានផ្ដល់ទៅឲ្យគាត់ម្សិលមិញ យើងបានសុំគាត់យកមកវិញ ទុកពេលយប់នេះ។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីម្សិលមិញយកជូនសាក្សីវិញ!

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ហេដឌ័រ ខ្ញុំឲ្យលោកមើលឯកសារ៤ *ថេប*១បាទ។ ខ្ញុំគិតថា លោកមាននិយាយពី

ឃ្លាហៅថា ការវាយតម្លៃឡើងវិញ តើលោកបានមើលឃើញ -- ខ្ញុំឲ្យលោកពិនិត្យមើលទំព័រទី៦ គឺផ្នែកមួយដែលនាំឲ្យយើងឈានទៅដល់កំណត់ជើងទំព័រលេខ១៧ គឺឯកសារ E190.1.398។ បាទ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះលើអេក្រង់កុំព្យូទ័រផងដែរបាទ។

[០៩:១៥:៥៦]

“គាត់ត្រូវលុបបំបាត់ឲ្យចូលទៅក្នុងកម្មករ កសិករផងដែរ និយាយអំពីបដិវត្តន៍សង្គមនិយម ហើយជាសមាជិករបស់ការវិភាគវណ្ណៈបក្សកុម្មុយនីស្តកម្ពុជា ការបំបែក ឬក៏ប្រភេទវណ្ណៈពិសេស មិនស័ក្តិសមត្រឹមត្រូវទៅនឹងវណ្ណៈទូលំទូលាយរបស់សក្តិភូមិ គហបតី អនុធន កសិករ ហើយនិងកម្មករ។ បន្ថែមទៅនឹងពួកបញ្ញវន្ត វណ្ណៈដទៃទៀត រាប់បញ្ចូលទាំងទាហានសាធារណរដ្ឋ នគរបាល ព្រះសង្ឃពុទ្ធសាសនា ហើយនិងជនជាតិទាំងអស់ បាទគឺជនជាតិភាគតិចទាំងអស់”។

កំណត់ជើងទំព័រ១៧ សេចក្តីយោង បាទ គឺជាកំណត់របស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ ខេ.អិន.អេច ០០១០ ហើយនិង ខេ.អិន.អេច ០៧១ ។ ហើយខ្ញុំសូមសួរលោកអំពីកំណត់សៀវភៅកំណត់ដៃរបស់កម្មាភិបាលបក្សកុម្មុយ -- កម្ពុជាប្រជាធិតេយ្យ។ សូមឲ្យលោកនិយាយលម្អិតបន្តិចអំពីអ្វីដែលលោកបានឃើញ ហើយលោកកត់សម្គាល់នោះ?

[០៩:១៧:៣៨]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** នេះគឺនិយាយត្រឡប់ទៅពេលវេលាមុនពេល ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើកាតាឡុកឯកសារ។ មជ្ឈមណ្ឌលឯកសារក៏បានទទួលបានឯកសារមួយចំនួនច្រើន ដែលជាសៀវភៅកំណត់ដៃ ដែលជាសៀវភៅសរសេរមកពីសង្គមចាស់ ពីមុនគេយកមកប្រើសម័យនោះ។ ហើយខ្លឹមសារនោះ គឺខ្ញុំបានឃើញថា ជាសៀវភៅកំណត់ដៃរបស់បក្សកុម្មុយនីស្តកម្ពុជា មានការកត់សម្គាល់អំពីការប្រជុំដែលគេចូលរួម មានឯកសារសិក្សារបស់បក្ស ដូចជា ខ្លឹមសារនិយាយអំពីឯកសារទស្សនាវដ្តីទង់បដិវត្ត ឬក៏ទង់យុវជន យុវនារី។ ហើយខ្ញុំបានពិនិត្យមើលឯកសារទាំងអស់នេះ ហើយនិងខ្លឹមសារនៃអត្ថបទទាំងអស់នោះ គឺចេញមកអំពីកំណត់ -- សៀវភៅកំណត់ដៃដែលមានចែងនៅក្នុងលេខយោងទំព័រនេះឯង។ ឯកសារទាំងអស់នោះមានជាភាសាខ្មែរ ហើយគេបកប្រែទៅជាភាសាអង់គ្លេស ហើយនិងខ្ញុំផ្អែកលើខ្លឹមសារនោះ ដើម្បីសរសេរ។

**ស៖** ហើយសូមឲ្យលោកជួយនិយាយឲ្យក្បែរមីក្រូហ្វូនបន្តិចដើម្បីឲ្យឮច្បាស់។ បន្ទាប់ទៀតដូច

ខ្ញុំនិយាយអំពីឯកសារ មិនមាននៅក្នុងសំណុំឯកសារទេ ឯកសារ E3/387។ ខ្ញុំសូមបញ្ជូនឯកសារនេះទៅលោក ជាបទសម្ភាសន៍ដែលលោកបញ្ជាក់នៅថ្ងៃទី១ នៃការផ្តល់ភស្តុតាងជាមួយបុគ្គលនេះ។ ខ្ញុំមិនបញ្ជាក់ឈ្មោះគាត់ទេ គឺ TCW-494។

[០៩:១៩:០០]

**លោក ឃីត វេយ្យ័ន៍វ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតជូនកំណត់ហេតុដែលលោក ហេងឆ័រ បានសម្ភាសជាមួយបុគ្គលនេះជូនគាត់ពិនិត្យបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

**សួរដោយលោក ឃីត វេយ្យ័ន៍វ៖**

**ស៖** តើលោកមើលឃើញទំព័រទី១ តើលោកនឹកឃើញពីអ្វីដែលលោកបានសម្ភាសនោះដែរទេ? គឺជាប្រតិចារឹកនៃបទសម្ភាសន៍ខ្ញុំមើលទំព័រលេខ៤។ នៅក្នុងឯកសាររបស់លោក គឺអង់គ្លេស ERN 00350203, បារាំង 00441416, ខ្មែរ 00379483-84។ បើយើងមើលទំព័រ៤ នៅលើឯកសារដែលលោកមាន លោក ហេងឆ័រ គឺប្រហែលជាពីរភាគបី នៅខាងក្រោមទំព័រមានប្រយោគមួយដែលចាប់ផ្តើមឡើងនៅក្នុងខែកក្កដា ឆ្នាំ១៩០០ *(ស៊ីក)* តទៅនោះ។ “នៅក្នុងខែកក្កដាឆ្នាំ១៩៧៥ ខ្ញុំបានទៅតំបន់ជាច្រើន ហើយខ្ញុំទទួលការងារថ្មី ទទួលការតែងតាំងជាលេខាតំបន់២១ ទទួលបន្ទុកខាងការសេដ្ឋកិច្ច ការអប់រំ”។ តើនេះជាការកត់ត្រាត្រឹមត្រូវអ្វីដែលនិយាយអំពីរឿងហ្នឹងក្នុងពេលសម្ភាសដែរឬទេ?

[០៩:២១:៣៥]

**លោក ស៊ួវ ហេងឆ័រ៖**

**ឆ៖** ដោយលើកលែងតែថា ការបកប្រែហ្នឹងវាមានល្អៀងខ្លះ ប៉ុន្តែខ្លឹមសារហ្នឹងគឺអ៊ីចឹងមែន។

**ស៖** ខ្ញុំសូមឱ្យលោកមើលទំព័រមួយទៀតគឺទំព័រ៥ គឺអង់គ្លេស ERN 00350204, ខ្មែរ 0037 9484 ដល់ 85។ សូមដកស្រង់ “ឥឡូវនេះយើងចូលទៅដល់វគ្គកាលទី២ ចាប់ពីឆ្នាំ១៩៧៣ ថ្ងៃ១៨ ឆ្នាំ១៩៧៥ ក្នុងអំឡុងពេលនេះ ប៉ុល ពត បានកែនយោបាយរបស់គាត់។ ហើយក្នុងការកែនយោបាយរបស់គាត់ខ្ញុំកត់សម្គាល់ដូចខាងក្រោម៖

ទី១ គឺគេលើកឡើងពីបញ្ហាវណ្ណៈ និងការតស៊ូវណ្ណៈនៅក្នុងសង្គមគឺពេលហ្នឹងគេលើកវណ្ណៈប្រាំ គឺវណ្ណៈកម្មករ កសិករ អនុធន សក្ដិភូមិ និងមូលធននិយម។ មានប្រាំអ៊ីចឹង ក៏ប៉ុន្ដែមានសមាសភាពនៃប្រាំ គឺមានតែកម្មករ និងពលករ រីឯ*ភាស* ផ្សេងៗទៀត ក៏វណ្ណៈផ្សេងទៀតគេបំភ្លេចចោល។ ទោះបីជាកសិករកណ្ដាល កសិករថ្នាក់លើ អនុធនក៏ដោយ ព្រះសង្ឃបញ្ញវន្ដ គឺត្រូវបានគាបសង្កត់ទាំងអស់។ គឺយើងសូមជម្រាបអ៊ីចឹង។ គឺនិយាយពីបញ្ហាផ្ដាច់ការ វណ្ណៈអធនរបស់គេពិនិត្យឃើញច្បាស់ផ្ដាច់ការអធនខ្លាំងដែរ"។ តើលោកនឹកឃើញថាខ្លឹមសារហ្នឹងពិតជាលោកបានស្ដាប់ពីអ្នកផ្ដល់សម្ភាស អ៊ីចឹងដែរឬទេ?

[០៩:២៣:២៦]

**ផ៖** ម្ដងទៀត ដោយការលើកលែងមិនមែនជាការបកប្រែរបស់ខ្ញុំទេ ហើយខ្ញុំនិយាយថាបាទអ៊ីចឹងមែន។ ប៉ុន្ដែវាមានអ្វីគឺការនិយាយអំពីការគាបសង្កត់ហ្នឹង ខ្ញុំមិនទាន់ច្បាស់ក្នុងការបញ្ជាក់ពីអត្ថន័យដែលខ្ញុំចង់ពិនិត្យមើលខ្មែរ ឬក៏ស្ដាប់សំឡេងជាខ្មែរថាតើវាច្បាស់ពាក្យដែរឬអត់ទេ ប៉ុន្ដែខ្ញុំដូចជាសង្ស័យបន្ដិចនឹងពាក្យហ្នឹង ប៉ុន្ដែខ្ញុំលើកលែងតែខ្លឹមសារហ្នឹងទេ ទាំងអស់មិនអ្វីទេ។

**ស៖** យើងនឹងឲ្យគេបោះពុម្ពជាអត្ថបទភាសាខ្មែរបាទ។ ឥឡូវនេះខ្ញុំសូមបន្ដទៅទៀតបន្ទាប់មកខ្ញុំនឹងត្រឡប់មកចំណុចនេះដើម្បីបញ្ជាក់ម្ដងទៀតនៅពេលក្រោយព្រឹកនេះ។

អ៊ីចឹងយើងចូលទៅខាងក្រោមនៃទំព័រលេខ៥ ERN ដដែល។ ប្រាំមួយបន្ទាត់ក្រោមរាប់ពីខាងក្រោមមក គឺថាសូមដកស្រង់ បាទ និយាយពីពេលវេលា គឺនិយាយអំពីសេចក្ដីដកស្រង់ ហើយយើងមានកាលបរិច្ឆេទ គឺពីរបន្ទាត់មើលពីខាងក្រោម។ ចាប់ពីឆ្នាំ១៩៧៣ មកគឺមានជម្លោះជាមួយវៀតណាម គឺគាត់និយាយអំពីឆ្នាំ១៩៧៣ គឺទំព័រ៦ របស់ឯកសាររបស់លោក, អង់គ្លេស 00353205, ខ្មែរ 00379485 ដល់ 86, បារាំង 00441418។

[០៩:២៥:៤១]

នៅខាងលើទំព័រ "ដូច្នេះជាការព្រួយបារម្ភអំពីកម្លាំងដែលនៅសេសសល់ ទាក់ទងទៅនឹងសកម្មភាពផ្សេងៗ។ ពេលនេះគេប្រើពាក្យថា សេចក្ដីសម្រេចខាងសន្ដិសុខ គឺគោលជំហរខាងសន្ដិសុខដែលពាក់ព័ន្ធទៅនឹងការតស៊ូវណ្ណៈ ហើយនិងវណ្ណៈផ្ដាច់ការវណ្ណៈ។ នេះយើងខ្ញុំជម្រាបអ៊ីចឹងដោយសង្ខេប ហើយយើងពិនិត្យឃើញត្រង់នេះទៀត គួរកត់សម្គាល់ ពេលហ្នឹងចាប់បំបាត់ព្រះសង្ឃបណ្ដើរៗ វត្តអារាមហ្នឹងក៏ផងដែរ ឈ្លើយសឹកក៏ដោយក៏គេឲ្យរស់នៅក្នុងរបៀបមួយដាច់ដោយឡែក។ ពេលនេះជន

ឈ្លើយសឹក ហើយអ្នកដែល លន់ នល់ ដែលចុះចូលត្រូវបានគេលុបបំបាត់ចោល។ ការជំនឿ និងសាសនាទាំងខ្មែរ ហើយនិងជនជាតិដទៃទៀតត្រូវបានហាមឃាត់។ ហើយជំនឿអរូបិយ និងពុទ្ធសាសនាក៏ត្រូវហាមឃាត់ផងដែរ"។ តើនេះអ្វីវាផ្ទុះបញ្ចាំង ដែលលោកបានស្តាប់ឮដែលនៅក្នុងសម្ភាសដែលគេប្រាប់លោកដែរឬទេ?

**ឆ៖** បាទ ប៉ុន្តែមានការរក្សាសិទ្ធិដដែល ខ្ញុំអាចឃើញភាសាខ្មែរនៅទីនេះ ប៉ុន្តែប្រសិនបើខ្ញុំមានជាឯកសារលើក្រដាសអាចល្អ។

[០៩:២៧:០៩]

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំនឹងមានឯកសារលើក្រដាស។ សូមអនុញ្ញាតលោកប្រធានដើម្បីជូនទៅគាត់បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក ហេដឌ័រ ខ្ញុំនឹងទៅចំណុចទី១ ពាក់ដែលថាទំព័រខ្មែរ ពាក្យថា "គាបសង្កត់" នោះគឺពាក្យ ERN ដែលដិតខ្មៅនោះ គឺ -- បាទពាក្យថា "*អុបប្រេស*" – ពាក្យថា "គាបសង្កត់" ហ្នឹងគឺថាទំព័រ 00379485។ ឃ្លានោះគឺនិយាយថា "ទោះបីជាកសិករថ្នាក់កណ្តាល ឬក៏ថ្នាក់លើ គឺអនុធន ព្រះសង្ឃបញ្ញវន្តក៏ត្រូវបានគាបសង្កត់"។ បាទនៅក្នុងអត្ថបទបកប្រែជាភាសាផ្លូវការរបស់តុលាការ។ អង់គ្លេស ERN 00350204 ទំព័រ៥។

**ឆ៖** ពាក្យខ្លឹមសារដើមនៅទីនេះ គឺយើងអាចៗនឹងអានខុសទៅការបកប្រែជាភាសាអង់គ្លេសដែលមានន័យថា "វណ្ណៈ" ដែលបញ្ជាក់នៅក្នុងទីនេះគឺនិយាយថាជា វណ្ណៈដែលត្រូវគាបសង្កត់ដោយខ្មែរក្រហម។ ពួកទាំងអស់នោះគឺស្ថិតនៅចំណោមវណ្ណៈ ដែលត្រូវបានគាបសង្កត់ដោយវណ្ណៈជិះជាន់នៅក្នុងសង្គមចាស់នោះទេ។

[០៩:២៨:៤០]

**ស៖** នៅក្នុងផ្នែកទី២ ប្រយោគដែលខ្ញុំនិយាយនោះគឺថា អង់គ្លេស ERN ទំព័រ៦ ខ្មែរទំព័រ 00379485 រហូតទៅដល់ចុងក្រោយ ខាងក្រោមនៃទំព័រនេះ។ ឃ្លាដែលខ្ញុំចាប់អារម្មណ៍នោះ ឃ្លាដែលចង់បានបកប្រែនោះគឺនិយាយអំពីពួកឈ្លើយសឹក ហើយនិងពួកទាហាន លន់ នល់ ដែលចុះចូលនោះត្រូវ

បានគេលុបបំបាត់ចោល។

**ឆ៖** បាទ។ នេះជាឃ្លាដែលខ្ញុំបានបកប្រែថាបោសសម្អាត។

**ស៖** បាទ សូមអរគុណ។ គឺយើងបានយល់ពីឃ្លានេះហើយ។ ឥឡូវខ្ញុំនិយាយពីអត្ថបទភាសាអង់គ្លេស គឺសូមទុកភាសាខ្មែរមួយឡែកសិន គឺនៅត្រង់ទំព័រ ពាក់កណ្ដាលទំព័រ៦ គឺខ្ញុំជូន ERN រួចហើយ។ "គេបានបញ្ជាឲ្យយើងវាយប្រហារនៅម៉ោងមួយព្រឹក គឺនៅឆ្នាំ១៩៧៤ ថាតើថ្ងៃទី៣០, ៣១ ខែធ្នូ តើសង្គ្រាមត្រូវចប់នៅក្នុងឆ្នាំ១៩៧៥ គេបានរៀបកោះប្រជុំដើម្បីបញ្ជាក់អំពីការវាយប្រហារគ្រប់សមរភូមិនៅពេលដែលគេជោគជ័យ។ បើយើងនិយាយជាទូទៅ នៅមានស្នូរកាំភ្លើងនៅគ្រប់សមរភូមិនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៥ ដូចដែលមានផែនការនោះឯង"។ ដូច្នេះតើអ្វីដែលលោកចាំនៅក្នុងបទសម្ភាសន៍គេប្រាប់លោក លោកហ្នឹងខ្លឹមសារដូចនេះដែរ ឬដូចម្ដេច?

[០៩:៣២:០១]

**ឆ៖** ជាការពិតដូច្នោះមែន។

**ស៖** នៅត្រង់ទំព័រដដែល ហើយ ERN នោះក៏លេខដដែល។ "ក្នុងពេលវាយប្រយុទ្ធ ប៉ុល ពត គិតថាជោគជ័យនឹងទទួលបានក្នុងខែកុម្ភៈ ឆ្នាំ៧៥ ហើយគាត់បានបញ្ជូនព័ត៌មាននេះទៅតាមស្រុក និងតំបន់ឲ្យបានដឹង។ គេប្រាប់ឲ្យខាងតំបន់ស្រុកនេះធ្វើការជម្លៀសទីក្រុងភ្នំពេញទៅកាន់កន្លែងស្រុកទាំងអស់នោះ។ ក្នុងពេលនោះគេប្រកាសថាអ្នកនៅក្នុងភ្នំពេញត្រូវជម្លៀស។ ដូច្នេះនៅក្នុងខែកុម្ភៈ ឆ្នាំ៧៥ គេបានផ្សាយដំណឹងទៅឲ្យគ្រប់ស្រុក គ្រប់តំបន់ ដើម្បីរៀបចំធ្វើផ្ទះសម្រាប់ជូនប្រជាពលរដ្ឋដែលត្រូវបានជម្លៀសចេញពីទីក្រុង ឬទីប្រជុំជនរួមខេត្ត"។

ខ្ញុំនឹងបន្តទៀត ដោយសារតែផ្នែកបន្តនោះក៏ពាក់ព័ន្ធដែរ "ជិត២ខែក្រោយមក រំដោះទឹកដីនៃប្រទេសហ្នឹងបានដូចបំណង"។ អត់ទេ! ខ្ញុំឈប់ត្រង់ចំណុចហ្នឹងសិន តើលោកអាចបញ្ជាក់ទេថាអានេះចំណុចនេះគឺជាការរៀបរាប់តាមអ្វីដែលលោក គេប្រាប់លោកនោះបានត្រឹមត្រូវពិតប្រាកដ តើអ៊ីចឹងដែរឬទេ?

[០៩:៣៣:៥១]

**ឆ៖** បាទពិតជាការរៀបរាប់ត្រឹមត្រូវ។

**ស៖** ខ្ញុំសូមបន្តទៅដល់ប្រធានបទទូទៅមួយ។ ខ្ញុំសូមឲ្យលោកយកឯកសារហ្នឹងទុកមួយឡែកសិនទៅ បន្ទាប់មកយើងនឹងត្រឡប់មកឯកសារ មើលឯកសារនេះវិញ។ ប្រធានបទទូទៅនេះគឺអំពីរចនា

សម្ព័ន្ធបញ្ហា និងរចនាសម្ព័ន្ធអំណាច។ សំណុំឯកសារលេខ៤ *ថេប*លេខ៣ លោកមើលទៅឃើញតែមួយទំព័រទេ ត្រឹមត្រូវទេ? E131/1/13.3 ជាចំណុចដកស្រង់ចេញពីសៀវភៅរបស់លោកចំណងជើងថា “មាក្សនិយម និងពូជសាសន៍និយម ប្រល័យពូជសាសន៍” ហើយនិងការលើកឡើងអំពីបញ្ហាប្រល័យពូជសាសន៍នេះដោយ ប៉ែន យៀរនិន។ លោកបាន នៅក្នុងនេះលោកនិយាយអំពីទស្សនទាននៃបក្ស ហើយលោកបានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជានេះទទួលមរតកពីកុម្មុយនីស្តចិន លេខ*ហ្វូតណូត* ៤៨។ ហើយក្នុងនេះ ក៏បានយោងទៅលើរចនាសម្ព័ន្ធបក្សថ្នាក់ខ្ពស់ ហើយនិងក្របខ័ណ្ឌនៃអំណាចរបស់រដ្ឋ ដែលក្នុងរួមទាំងមជ្ឈិមបក្ស និងសាខាផ្សេងទៀតរបស់បក្ស ក្រសួង និងថ្នាក់ក្រោមៗទៀត។ បន្ទាប់មកលោកយោងទៅលើលេខ៤៨ ជើងទំព័រ លោកនិយាយអំពីឯកសារឆ្នាំ៧១នៅប៉េកាំង ហើយនិងឆ្នាំ១៩៨០ ឯកសារហាណូយពីឆ្នាំ១៩៧៨។ តើលោកអាចបញ្ជាក់ទេ លោកពិតជាបានអានឯកសារទាំងអស់នោះ ហើយពិតជាទាញចេញមកពីប្រភពឯកសារទាំងអស់នោះមែន?

[០៩:៣៦:២៦]

**ឆ៖** ជាការពិតដូច្នោះមែន។

**ស៖** លោក ហេដឌ័រ នៅក្នុងឯកសារដែលលោកបានពិនិត្យមើលជាភាសាខ្មែរ វៀតណាម និងចិន។ តើលោកធ្លាប់ឃើញពាក្យគេប្រើពាក្យថា “មជ្ឈិមបក្ស” សំដៅទៅលើគណៈកម្មាធិការកណ្ដាលរបស់បក្សដែរឬទេ?

**ឆ៖** សូមអធ្យាស្រ័យអំមិញ ខ្ញុំរកអត់ទាន់ឃើញ។ ខ្ញុំគិតថា ចម្លើយដែលខ្ញុំអាចឆ្លើយចំពោះករណីនេះ គឺខ្ញុំធ្លាប់ឃើញ។ ក៏ប៉ុន្តែនៅក្នុងន័យថា គណៈកម្មាធិការមជ្ឈិមបក្ស គឺជាអង្គការមួយចំនួនដែលគេអាចនិយាយបានដូច្នេះ ហើយគេអាចប្រើឈ្មោះដូច្នេះ។ គេប្រើឈ្មោះថាជា មជ្ឈិមតែម្ដង។ មជ្ឈិមគឺជាថ្នាក់កណ្ដាលមួយនៅក្នុងរចនាសម្ព័ន្ធបក្ស ហើយមិនមែនជាអង្គការមួយជាក់លាក់នៅក្នុងកម្រិតនោះទេ ទោះបីជាមួយ ឬក៏ពីរក៏ដោយ។ ពាក្យថា “មជ្ឈិមបក្សនេះ” គឺថាវាមានលក្ខណៈស្រពេចស្រពិលមិនច្បាស់ទេ។

[០៩:៣៧:៥៥]

**ស៖** សូមអរគុណ។ សំណុំឯកសារលេខ៤ *ថេប*៤ សូមឲ្យលោកបើកទៅកាន់*ថេប*៤ ឯកសារ E3/48 បេក្ខជនប្រាំពីរនាក់ដែលនឹងត្រូវកាត់ទោស។ ហើយសូមឲ្យលោកមើលទំព័រ៤៦ ទំព័រ៤៦គឺថាប្រហែលជាលោកមិនមានទាំងអស់នោះទេ។ ក៏ប៉ុន្តែទំព័រដែលលោកមាននោះ គឺថានៅខាងលើនៅនៃ

ឯកសារនោះ។ តើលោកបានរកឃើញឯកសារទំព័រ៤៦ហើយឬនៅ បើលោករកឃើញហើយ ខ្ញុំសូមអរគុណ។

យោងទៅលើលក្ខន្តិកៈលោកបានឆ្លើយដូច្នេះថា លោកបានសរសេរដូច្នេះថា "លក្ខន្តិកៈបានប្រកាសថា បក្សនោះគឺត្រូវអនុវត្តមាគ៌ារបស់ខ្លួននៅទូទាំងប្រទេស។ ផ្តល់ការណែនាំទៅដល់ថ្នាក់ក្រោមៗ ភូមិភាគ តំបន់ និងអង្គការក្រុង ហើយនិងទៅដល់អង្គការបក្សទទួលខុសត្រូវចំពោះខាងសាខាថ្នាក់ជាតិនានា ហើយនិងចាត់ចែង និងបញ្ជូនកម្មាភិបាល និងសមាជិកបក្សនៅក្នុងបក្សជារួម។ ក្នុងខណៈរក្សានូវការក្តោបក្តាប់ប្រវត្តិរូប និងនយោបាយ រួមទាំងជំហរអង្គការ ហើយធ្វើការអប់រំពួកគេជាដរាប និងបំពាក់បំប៉នពួកគេអំពីនយោបាយ មនោគមន៍វិជ្ជា និងការរៀបចំចាត់តាំង"។ យើងស្គាល់ឯកសារនេះច្បាស់ណាស់ គឺឯកសារ E3/214--

[០៩:៣៩:៤៩]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន លោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ ភាគី មេធាវីទាំងអស់។ នៅពេលនេះ យើងឈានមកដល់ប្រធានបទមួយដែលសួរសំណួរ ដែលយើងទាមទារឲ្យមានការសម្រេចពីអង្គជំនុំជម្រះ។ ខ្ញុំជំទាស់ទៅនឹងរបៀបសួរសំណួរជាក់លាក់តែម្តង សហព្រះរាជអាជ្ញាយោងទៅលើសៀវ-ភៅមួយដែលមាននៅក្នុងសំណុំរឿង។ សហព្រះរាជអាជ្ញាសួរទៅកាន់សាក្សី អំពីប្រភពនៅក្នុងលេខយោងជើងទំព័រ ក៏ប៉ុន្តែសៀវភៅនេះ មានចំណងជើងថា "បេក្ខជនប្រាំពីរនាក់ដែលនឹងត្រូវចោទប្រកាន់កាត់ទោស"។ ជាការពិតទៅគឺថាការសួរដូច្នេះ សួរលើសៀវភៅនេះដោយសារតែមានគោលបំណងជាក់លាក់។ សាក្សីនៅពេលមួយនោះ គឺថានឹងអាចបង្ហាញហេតុផល ហេតុអ្វីបានជាគាត់សរសេរសៀវភៅនេះ។ ចំណងជើងសៀវភៅដែលហៅថា "ប្រាំពីរនាក់ដែលត្រូវកាត់ទោស" នោះ គឺថាសាក្សីជាអ្នកសរសេរ ដើម្បីមានគោលបំណងបង្ហាញភស្តុតាងចោទប្រកាន់ មិនត្រឹមតែទៅលើ ខៀវ សំផន ទេ រួមទាំងកូនក្តីរបស់ខ្ញុំផងដែរ។

[០៩:៤១:១១]

ហេតុដូច្នេះនៅពេលនេះយើងស្តាប់ឮស្ថានភាពដែលសាក្សីមួយរូប គឺគាត់មានតួនាទីយ៉ាងសំខាន់នៅក្នុងការស៊ើបអង្កេត។ នៅពេលនេះគាត់ត្រូវបានសួរសំណួរអំពីសៀវភៅមួយក្បាលហ្នឹង ដែលវាជាចំណុចសំខាន់ក្នុងការចោទប្រកាន់ និងការកាត់ទោសកូនក្តីរបស់ខ្ញុំ។ ទោះបីជាការជំទាស់នេះ ទៅលើបច្ចេកទេសនៃការសួរសំណួរនេះក៏ដោយ នៅពេលនេះគឺយើងឃើញថា ស្ថានភាពចូលមកដល់ដំណាក់-កាល ដែលថាសាក្សីនេះជាមូលដ្ឋានទៅលើកឡើងអំពីសៀវភៅរបស់គាត់ដែលថា ហេតុអ្វីកូនក្តីរបស់ខ្ញុំត្រូវយកមកកាត់ទោស? ខ្ញុំនៅពេលនេះ សូមលើកឡើងជូនអង្គជំនុំជម្រះអំពីភាពត្រឹមត្រូវស្របច្បាប់ពាក់ព័ន្ធទៅនឹងសំណួរសួរដែលសួរទៅកាន់សាក្សី ជាពិសេសការសួរសំណួរទៅកាន់សាក្សីអំពីសៀវភៅមួយនេះ។

[០៩:៤២:១៥]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមលើកឡើងសាមញ្ញដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញ។ ខ្ញុំនឹងមិនសួរលោក ហេងឌ័រ ឲ្យគាត់ផ្តល់ជាមតិយោបល់ផ្អែកទៅលើសៀវភៅនេះឡើយ។ សៀវភៅមួយក្បាលនេះត្រូវបានទទួលយកមកធ្វើជាភស្តុតាងរួចមកហើយ ការជំទាស់ ឬក៏បានលើកឡើងផងដែរ ហើយក៏បានសម្រេចរួចហើយផងដែរ។ យើងឃើញមាននៅក្នុងសំណុំរឿងសៀវភៅនេះ។ សៀវភៅនេះ មានលេខសម្គាល់ E3 ទៀត ហេតុដូច្នេះគឺសៀវភៅនេះមានភាពអាចទុកចិត្តបាន និងពាក់ព័ន្ធ។ វាចាំបាច់ត្រូវមានការសម្រេច ប្រសិនបើខ្ញុំសួរសាក្សីឲ្យផ្តល់មតិយោបល់។ ខ្ញុំមិនសួរឲ្យផ្តល់មតិយោបល់នោះទេ នៅពេលនេះ គឺថាខ្ញុំគ្រាន់តែអនុវត្តតាមការងាររបស់ខ្ញុំ ក្នុង១ថ្ងៃកន្លះនេះ គឺថាខ្ញុំបានអនុវត្តទៅតាមការណែនាំរបស់អង្គជំនុំជម្រះអានចម្លើយ ឬចំណុចដកស្រង់ចេញពីសៀវភៅ ហើយខ្ញុំគ្រាន់តែសួរសំណួរអំពីប្រភពដែលគាត់ផ្អែកមូលដ្ឋានតែប៉ុណ្ណោះ។

ការសួរបែបនេះ គឺខ្ញុំធ្វើឡើងរហូតក្នុងអំឡុងពេញពេលដែលខ្ញុំដេញដោលសំណួរទៅកាន់សាក្សី ហេតុដូច្នេះហើយ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះឲ្យខ្ញុំអនុវត្តរបៀបដែលខ្ញុំសួរដូច្នេះក្នុងពេលដែលខ្ញុំដេញដោលទៅលើសាក្សីនេះរហូតដល់បញ្ចប់តែម្តង។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៤:០៨]

**លោក ឃីត វេយ៍នរ៉ះ**

ហើយអម្បាញ់មិញនេះ ខ្ញុំមិនទាន់បានសួរសំណួរនៅឡើយទេ លោកប្រធាន លោក លោកស្រីចៅក្រម។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៥:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់ពីសេចក្ដីសម្រេចចំពោះសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា ទៅលើរបៀបនៃការតាំងសំណួរដែលផ្អែកលើសៀវភៅនិពន្ធរបស់អ្នកនិពន្ធរូបនេះនៅក្នុងកិច្ចពិភាក្សាដេញដោលនៅពេលនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានសម្រេចថាការជំទាស់គឺគ្មានសុពលភាពឡើយ។ ចំណុចទី១ គឺសៀវភៅនេះមាននៅក្នុងសំណុំរឿង ហើយក៏ត្រូវបានដាក់លេខ E3 ផងដែរ។ ចំណុចទី២ ប្រសិនបើការជំទាស់ពាក់ព័ន្ធទៅនឹងតម្លៃនៃភស្តុតាងលើសៀវភៅនេះ វាជាបញ្ហាសម្រាប់អង្គជំនុំជម្រះសម្រេចនូវដំណាក់កាលចុងក្រោយ។ សូមអរគុណលោកប្រធាន។

[០៩:៤៦:២១]

**សួរដោយលោក ឃីត វេយ៍នរ៉ះ**

**ស៖** តើលោកបានដឹងថាលក្ខន្តិកៈនេះបានសរសេរជាប៉ុន្មានច្បាប់ដែរ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំមានលក្ខន្តិកៈច្បាប់ដើមមួយចំនួន ខ្ញុំជឿថាវាជាឯកសារដើម ខ្ញុំកំពុងតែកាន់កាប់។ ហើយមានឯកសារថតចម្លង លក្ខន្តិកៈថតចម្លងនេះខ្ញុំសន្មតថាជាឯកសារដូចទៅនឹងឯកសារដើម ខ្ញុំក៏មានដែរ។ ឌី.ស៊ី.ខេម ក៏មានឯកសារច្បាប់ដើមមួយចំនួននៅក្នុងសំណុំឯកសាររបស់គេ។ លក្ខន្តិកៈនេះច្បាប់ដើមក៏មាននៅតាមកន្លែងផ្សេងៗទៀតផងដែរ។ ដេវីឌ ឆេនដ៍ល័រ ក៏ប្រហែលជាអាចមានមួយច្បាប់ដើម និង/ឬក៏អាចថតចម្លង ច្បាប់ថតចម្លងមួយច្បាប់ទៀត អ្នកផ្សេងក៏អាចមាន។ ចំពោះច្បាប់នេះប៉ុន្មាននោះគឺថាខ្ញុំមិនបានដឹងទេ។

**ស៖** តាមការស្រាវជ្រាវរបស់លោក មិនឲ្យលោកផ្តល់មតិយោបល់នោះទេ តើលក្ខន្តិកៈនេះ អនុម័តនៅក្នុងពេលណាដែរ?

**ឆ៖** ខ្ញុំគិតថា នៅពេលសម្ភាសនោះគឺគេបានប្រាប់ខ្ញុំថា អនុម័តនៅខែមករា ឆ្នាំ១៩៧៦ ហើយ គេបានយោងនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ឬក៏យុវជនទង់បដិវត្តផងដែរ ហើយក៏បានលើកឡើងថាក្នុង អំឡុងឆ្នាំនោះឯង។

[០៩:៤៨:០៧]

**ស៖** តើលោកដឹងទេ នៅពេលណាដែលលោកបានផ្តល់ភស្តុតាងអំពីសន្និបាតឆ្នាំ១៩៦០ នៅក្នុង ប្រទេសកម្ពុជានោះ? ថាតើលោកអាចបញ្ជាក់ទេ គេបានអនុម័តនៅពេលណាដែរ ក្នុងទសវត្សរ៍៦០ ឬក៏ នៅក្នុងឆ្នាំណា?

**ឆ៖** ជាការពិតយើងអាចជឿថា ប៉ុល ពត, នួន ជា និងអ្នកផ្សេងដែលបានលើកឡើង អ្នកទាំង អស់នោះគឺថាគាត់បាននិយាយច្រើនអំពីបញ្ហាលក្ខន្តិកៈនេះ។

**ស៖** សំណុំឯកសារលេខ៤ *ថេប*១ ទំព័រ ១២ អង់គ្លេស ERN 00661466, ខ្មែរ 00830775, បារាំង មានលេខ 00792925 ខ្ញុំយោងលើលេខយោង ៦៤។ សូមអធ្យាស្រ័យឯកសារ E190.1.398 ចំណងជើងថា "ការវិភាគឡើងវិញ"។ "ការផ្លាយចេញព័ត៌មានមកពីមជ្ឈិម និងស្រុកគឺបានសម្រប សម្រួលដោយតំបន់ និងភូមិភាគដែលនាំឲ្យកម្មាភិបាលស្រុក តំបន់ និងភូមិភាគ បានមកពីទីក្រុងភ្នំពេញ ដើម្បីប្រជុំ ហើយនិងធ្វើការពិគ្រោះយោបល់ជាលក្ខណៈពិសេសជាមួយនឹង ប៉ុល និង នួន។ នៅក្នុង លិខិតឆ្លើយឆ្លងជាច្រើនបានធ្វើឡើងរវាងទៅវិញទៅមករវាងភូមិភាគ និងមជ្ឈិម"។

លេខយោង៦៥ យោងទៅលើការសម្ភាសជាមួយនឹង កែ ពក។ លោកបានបន្តរៀបរាប់ថា សូម អធ្យាស្រ័យ គឺលេខយោង១៤ទេ។ ត្រង់ទំព័រ៥ នៅក្នុងនេះក៏បានបញ្ចូលលេខយោង១៤ ដែលបានផ្តល់ បរិបទលើកិច្ចសម្ភាសន៍ជាមួយនឹង កែ ពក។ លោកបានលើកឡើងថា កិច្ចសម្ភាសន៍ដែលអ្នករៀបចំ ឡើងគឺ ស្ទីវិន ហេដឌ័រ នៅក្នុងឆ្នាំ២០០១ ក្នុងខេត្តសៀមរាបប្រទេសកម្ពុជា។

[០៩:៥១:២៨]

"ពក ឯកភាពពិភាក្សាលើភស្តុតាងដាក់បន្ទុកលើគាត់ និងអ្នកដទៃទៀត ដោយផ្អែកលើលក្ខខណ្ឌ ថាចម្លើយរបស់គាត់នេះមិនត្រូវផ្សព្វផ្សាយទេក្នុងពេលដែលគាត់នៅរស់"។ ពាក់ព័ន្ធទៅនឹងអ្វីដែលគាត់ និយាយ គឺគាត់បានលើកឡើងថា ទទួលស្គាល់ថា "ក្នុងនាមជាលេខភូមិភាគឧត្តរ ក្រោយមកភូមិភាគ

កណ្តាលរបស់បក្ស គាត់បានអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរ ហើយនិងផ្តួចផ្តើមឲ្យមានការចាប់ខ្លួន ហើយបញ្ជាឲ្យមានការកាប់សម្លាប់ទៅលើអ្នកដែលត្រូវបានគេចោទថាជាពួកក្បត់ ក្នុងចំណោមសមាជិកបក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតនៅក្រោមគាត់។ ហើយក៏គាត់អនុវត្តតាមបញ្ជារបស់ នួន ផងដែរ ក្នុងការជួយចាត់ចែងលើការចាប់ខ្លួនអ្នកដែលត្រូវបានចោទប្រកាន់ថា ជាពួកក្បត់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ដែល ពក បានដឹងថាអ្នកទាំងអស់នោះនឹងត្រូវបានគេយកសម្លាប់ចោលក្រោយពេលមន្ទីរសន្តិសុខបក្សកុម្មុយនីស្តកម្ពុជា ស-២១ នៅទីក្រុងភ្នំពេញសួរចម្លើយរួចរាល់។ “ពក ទទួលស្គាល់អំពីការដែលគាត់ជួយផ្តួចផ្តើមនៅក្នុងការចាប់ខ្លួន”។ ចម្លើយនេះគឺមានភាពស៊ីសង្វាក់ តាមរយៈកិច្ចសម្ភាសន៍របស់អ្នកដែលធ្វើសម្ភាសនេះ។ ហើយ ពក នេះគឺជាអ្នកដែលស្ថិតនៅក្នុងជួរទី៤ នៅក្នុងភូមិភាគឧត្តរជាមួយនឹងបុគ្គលម្នាក់ដែលឈ្មោះ ផៅ (*ស៊ុក*) ស្ថិតនៅក្នុងខេត្ត -- នៅក្នុងអន្លង់វែងក្នុងប្រទេសកម្ពុជា”។ សំណួរដំបូងរបស់ខ្ញុំគឺ តើអ្វីដែលលោករៀបរាប់នេះឆ្លុះបញ្ចាំងនូវសម្តីពិតដែល កែ ពក បានឆ្លើយដែរឬទេ ក្នុងពេលដែលលោកបានសម្ភាសលើរូបគាត់នោះ?

**ឆៈ** បាទជាសម្តីពិតរបស់គាត់។

[០៩:៥៤:០៣]

**សៈ** និយាយអំពីបរិបទ កែ ពក ជាលេខាភូមិភាគឧត្តរ ក្រោយមកភូមិភាគកណ្តាល។ សូមឲ្យលោកធ្វើការផ្តល់នូវព័ត៌មានបន្ថែមបន្តិច ក៏ប៉ុន្តែមិនមែនផ្តល់ព័ត៌មាននៅពេលនេះតែម្តងទាំងអស់នោះទេ។

**ឆៈ** គាត់ គឺថានៅក្នុងខែឧសភា ឆ្នាំ៧៥ ជាលេខាភូមិភាគឧត្តរ ក្រោយចាត់តាំងឲ្យលេខាភូមិភាគកណ្តាល ហើយជាសមាជិកគណៈមជ្ឈិមនៅក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់កាប់។ ហើយក្រោយមកគឺគាត់ -- ក្រោយឆ្នាំ៧៩ ខែមករា នោះគឺថាគាត់មិនមានការគាំទ្រពីខ្មែរក្រហមទេ គាត់ក៏បានចូលនិវត្តន៍ ហើយនៅចុងឆ្នាំទសវត្សរ៍៩០ និង៩៨នោះ គឺគាត់បានចូលរួមជាមួយនឹងកងទ័ពរាជរដ្ឋាភិបាល។ កិច្ចសម្ភាសន៍បានរៀបចំឲ្យខ្ញុំដោយលោកឧត្តមសេនីយ៍ ប៉ុល សារឿន ដែលគាត់នៅពេលនោះជាមេបញ្ជាការនៅក្នុងកងទ័ពរបស់រាជរដ្ឋាភិបាលខ្មែរនាពេលនោះផងដែរ។

**សៈ** លោកប្រធាន ដោយគោរពតាមការណែនាំ និងការលើកឡើងរបស់អង្គជំនុំជម្រះ ខ្ញុំសូមសួរសំណួរមួយសំណួរទៅកាន់លោក ហេដឌ័រ។ តើកិច្ចសម្ភាសន៍ដែលលោកធ្វើឡើងជាមួយកែ ពត ត្រូវបានកត់ត្រាក្នុងទម្រង់ណាមួយដែរឬទេ?

**ឆ៖** កំណត់ហេតុជាលាយលក្ខណ៍អក្សរ ក៏ប៉ុន្តែអត់មានថតខ្សែអាត់ទេ។

[០៩:៥៦:០៥]

**ស៖** តើកំណត់ហេតុនោះអាចបញ្ជូនមកទីនេះក្នុងថ្ងៃនេះ ឬក៏នៅក្នុងត្រឹមចុងសប្ដាហ៍បានដែរឬទេ?

**ឆ៖** ខ្ញុំអត់យកមកជាមួយទេ ប្រហែលជានៅចក្រភពអង់គ្លេសនោះ តែមិនដឹងនៅម៉ុំណាទេ។

**ស៖** ប្រសិនបើអង្គជំនុំជម្រះ ឬលោកប្រធានបង្គាប់ឲ្យលោកផ្ដល់ឯកសារព័ត៌មានទាំងឡាយដែលលោកមាននោះមកជូនតុលាការនេះ តើលោកអាចធ្វើទៅរួចទេ?

**ឆ៖** ចម្លើយគឺមាន៤0ឯកសារនៅក្នុងបន្ទប់ -- ៤៥ឯកសារ បានន័យថានៅក្នុងបន្ទប់ចំនួន៤៥នៅតាមទីកន្លែងនៅក្នុងចក្រភពអង់គ្លេស។ ដូច្នេះហើយវាមិនមែនងាយស្រួលក្នុងការទៅរកមើលនោះទេ។

**ស៖** សូមអរគុណ។ កិច្ចសម្ភាសន៍លើកទី២ដែលលោកបានលើកឡើងថាការទទួលស្គាល់របស់ពក ដែលគាត់ផ្ដួចផ្ដើមនៅក្នុងការចាប់ខ្លួនដែលស៊ីសង្វាក់ជាមួយនឹង ពេជ្រ ឈាន ហៅ ថាវ (ស៊ីក)។ តើកិច្ចសម្ភាសន៍ហ្នឹងរៀបចំដោយរបៀបណាដែរ? ហើយមានការកត់ត្រា និងថតយ៉ាងម៉េចដែរ?

[០៩:៥៧:៣៤]

**ឆ៖** បុគ្គលម្នាក់នេះ គឺក្រោយខែមករា ឆ្នាំ១៩៧៩ គឺគាត់ធ្វើជាអគ្គរដ្ឋទូតនៅចិន ឲ្យកម្ពុជាប្រជាធិបតេយ្យ។ នៅចុងឆ្នាំ១៩៧៨នោះ គឺថាយើងខ្ញុំ ហើយនិងគាត់ហ្នឹងស្គាល់គ្នា។ នៅក្នុងឆ្នាំ២០០១ខ្ញុំទៅជួបគាត់ផ្ទាល់តែម្ដង គឺខ្ញុំជួបជាមួយគាត់ និងប្រពន្ធរបស់គាត់ផ្ទាល់នៅអន្លង់វែង ហើយគាត់ឯកភាពនិយាយសម្ភាសជាមួយខ្ញុំ។ គ្មានថតខ្សែអាត់ទេ ក៏ប៉ុន្តែមានការកត់ត្រាជាលាយលក្ខណ៍អក្សរដូចទៅនឹងការសម្ភាស កែ ពក ផងដែរ។

**ស៖** ដើម្បីបញ្ជាក់ទៅលើចំណុចនេះ លេខយោងដែលលោកបញ្ជាក់នោះគឺថាកំណត់ហេតុនៅក្នុងកិច្ចប្រជុំនៅថ្នាក់មូលដ្ឋាន ឯកសារ E3/232 ថ្ងៃទី៨ ខែមិនា ឆ្នាំ៧៦។ ឯកសារដដែលការវិភាគវាយតម្លៃឡើងវិញ លេខយោង៦៨ និង៦៩។ លេខាភូមិភាគបានផ្ដល់ព័ត៌មានទៅដល់មជ្ឈិមអំពីស្ថានការណ៍នៅតាមតំបន់ដែលពួកគេទទួលខុសត្រូវបានបង្ហាញថា ភូមិភាគកំពុងតែតាមដានលើសកម្មភាពទៅដល់ថ្នាក់ស្រុក ហើយកំពុងតែវិភាគភូមិភាគទៅលើសកម្មភាពត្រឹមត្រូវ ឬក៏ខុសឆ្គងនៅក្នុងការអនុវត្តគោលនយោបាយបក្ស។ ហើយនៅក្នុងនោះយោងទៅលើសារទូរលេខចំនួនពីរ គឺមាននៅក្នុង--

[០៩:៥៩:២៩]

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឱ្យតំណាងសហព្រះរាជអាជ្ញាបញ្ជាក់លេខឯកសារនេះឡើងវិញ។

**លោក ឃីត វេយ្យ័ន័រ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ពីលេខឯកសារអម្បាញ់មិញនេះឡើងវិញ ព្រោះអ្នកបកប្រែ បកប្រែមិនទាន់ទេ។

**លោក ឃីត វេយ្យ័ន័រ៖**

សូមអធ្យាស្រ័យលោកប្រធាន ខ្ញុំនឹងផ្តល់ព័ត៌មានលម្អិត។

**សួរដោយលោក ឃីត វេយ្យ័ន័រ៖**

**ស៖** ឯកសារ E3/97 "សារទូរលេខលេខ៩៤ ផ្ញើជូនពី ពក ទៅកាន់ ប៉ុល ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧៦" និងឯកសារ E3/87 "សារទូរលេខ២១ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៦"។ សៀវភៅនោះគឺ E190.3 សូមចាប់ផ្តើមម្តងទៀត E190.1.398 ប្រធានបទនេះ គឺថាតើលោកបានឃើញដំបូងហ្នឹងនៅពេលណា? តើជាសារទូរលេខបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ ទាក់ទងទៅនឹងអ្វីដែលលោកបានឃើញនោះ?

[១០:០១:០១]

**លោក ស្មីរ ហេដឌ័រ៖**

**ឆ៖** នៅចុងឆ្នាំ១៩៩០ គឺមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** ឯកសារ E190.1.398 ទាក់ទងទៅនឹងជើងទំព័រ៧០។ "អនុលោមតាមលក្ខន្តិកៈបក្ស គណៈតំបន់របស់បក្សត្រូវតែដឹកនាំ និងអនុវត្តគោលនយោបាយមាគ៌ាបក្សរហូតដល់ស្រុក ហើយនិងថ្នាក់ក្រោមតទៅទៀត"។ ប្រភពរបស់លោកនោះ រួមមាន E3/214 ជាលក្ខន្តិកៈ។ លោកបានយោងទៅរកមាត្រា១៩ ជាការបកប្រែរបស់លោក ដែល ប៉ុល ពន្យល់ថា "បញ្ហាទាំងអស់គឺអាស្រ័យលើបក្ស នៅគ្រប់មូលដ្ឋានទាំងអស់ ប៉ុន្តែមេដឹកនាំថ្នាក់កម្មាភិបាលថ្នាក់ខ្ពស់ ត្រូវតែពាក់ព័ន្ធនឹងការងារមូលដ្ឋាន។ កម្មាភិបាលភូមិភាគដឹកនាំកម្មាភិបាលមូលដ្ឋានក្នុងការអនុវត្ត"។ ហើយឯកសារ E3/135 ដែលជារបាយការណ៍នៅក្នុងទស្សនាវដ្តី ខែមិថុនា ឆ្នាំ១៩៧៦។ ឯកសារ E3/8 ជាឯកសារប្រមូលចងក្រងដែល

សរសេរដោយ ប៉ែន យៀវនិន ហើយនិង ឆេនដ៍ល័រ គឺផែនការ ប៉ុល ពត សម្រាប់អនាគត។ ខ្ញុំមានសំណួរពីរសម្រាប់លោក។ នេះអំពីនយោបាយ ពីថ្នាក់លើចុះទៅដល់ថ្នាក់ស្រុក ហើយនិងមូលដ្ឋានក្រោមទៅទៀត។ តាមការសម្ភាស ហើយនិងការជួបផ្ទាល់ដែលលោកបានជួបជាមួយអ្នកផ្តល់សម្ភាសនោះ តើលោកបានទទួលព័ត៌មានណាដែលតាមពិតមានហេតុការណ៍ហ្នឹងកើតដែរឬទេ?

[១០:០៣:១៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

សហព្រះរាជអាជ្ញា បាទ គឺថានិយាយ សួរសំណួរបន្ថែមៗគឺក្នុងលក្ខណៈជារឹតត្បិតទៅលើសាក្សី មិនឲ្យមានលទ្ធភាពសាក្សីឆ្លើយតាមគំនិតគាត់។ គាត់ដូចជាដឹកនាំសំណួរ សូមឲ្យគាត់បញ្ចេញយោបល់ពីសាក្សីដូច្នេះដែរ។ យើងសង្ឃឹមថា ថ្ងៃនេះដូចដែលយើងបានធ្វើម្សិលមិញនោះដែរ គឺថាជាសំណួរទៅសាក្សី។ ក៏ប៉ុន្តែខ្ញុំស្តាប់សំណួរ យើងអាចឃើញគឺថាសំណួរទាំងអស់នេះ គឺមិនមែនជាអ្វីក្រៅដែលថា ជាសំណួរសុំឲ្យអ្នកជំនាញបញ្ចេញយោបល់នោះទេ។ ប៉ុន្តែយើងមិនយល់ស្រប ហើយខ្ញុំសូមជំទាស់នឹងការរៀបសំណួរបែបនេះ។

[១០:០៤:២១]

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណចំពោះអ្វីដែលលោកឲ្យយោបល់ទៅលើការក្រងរៀបសំណួររបស់ខ្ញុំ។ មិនមែនជាការសុំយោបល់ទេ ទៅប្រាប់ឲ្យអ្នកណាម្នាក់ គឺអ្វីតាមពីបទសម្ភាសន៍ ដែលលោកបានជួបផ្ទាល់ជាមួយអ្នកផ្តល់សម្ភាស ដែលបានលោកបានធ្វើនោះ តើលោកសាក្សីបានទទួលព័ត៌មានជាអង្គហេតុតាមពី ដូចគំនិតដែលកត់នេះដែរឬទេ? ខ្ញុំមិនឲ្យគាត់បញ្ជាក់យោបល់ទេ។ ខ្ញុំមិនសុំឲ្យសាក្សីនិយាយស្មានព្រាវដែរ។ ខ្ញុំសួរ ខ្ញុំបានសួរបែបនេះ ប្រហែលជាប្រាំមួយ ប្រាំពីរសំណួរហើយ គឺមិនមានការជំទាស់ទេ។ ដូច្នេះតាមបទសម្ភាសន៍ដែលលោកបានធ្វើ មិនមែនពីអ្វីដែលអ្នកណាប្រាប់លោក មិនមែនជាការនិយាយស្មាន មិនឲ្យ មិនត្រូវឲ្យយោបល់ទេ។ ខ្ញុំសួរថា តើលោកសាក្សីអាចឆ្លើយបំភ្លឺតុលាការទេ? នេះមិនមែនជា

សក្ខីកម្មរបស់អ្នកជំនាញ ហើយមិនមែនជាការផ្តល់យោបល់ដែរ។

[១០:០៥:៣៤]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំនឹងសូមឆ្លើយដោយសង្ខេបលោកប្រធាន។ បើសិនយើងចាត់ទុកគាត់ជាសាក្សីពិតប្រាកដថា តើសួរ -- តើអ្នកនេះប្រាប់លោកពីអ្វីខ្លះ គឺសួរតែប៉ុណ្ណឹង។ អ្វីសហព្រះរាជអាជ្ញាធ្វើនៅទីនេះ គឺសួរគាត់ឲ្យសង្ខេបពីអ្វីដែលអ្នកផ្សេងប្រាប់ ហើយតាមការអានរបស់គាត់ ផ្អែកលើឯកសារ ហើយសូមឲ្យគាត់ផ្តល់ចម្លើយ។ នេះពិនិត្យទៅ គឺជាការ -- ដូចជាការសួរទៅអ្នកជំនាញ មិនមែនសួរទៅសាក្សីទេ របៀបដែលសហព្រះរាជអាជ្ញាសួរនោះ។ ដូច្នេះនេះជាការកត់សម្គាល់ និងឆ្លើយតប។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន សំណួររបស់ខ្ញុំហ្នឹង គឺខ្ញុំសួរថាតាមបទសម្ភាសន៍ ហើយនិងការជួបផ្ទាល់របស់លោកជាមួយនឹងអ្នកដែលលោកសម្ភាស តើលោកសាក្សីបានប្រមូលព័ត៌មានណាថា មានហេតុការណ៍បែបនេះកើតដែរឬទេ? ខ្ញុំមិនសួរពីឯកសារអ្វីនោះទេ ហើយខ្ញុំធ្វើហ្នឹង គឺក្នុងគោលបំណងដោយច្បាស់គឺបទសម្ភាសន៍ ការសម្ភាសដោយផ្ទាល់ គឺមិនឲ្យយោបល់ទៅលើឯកសារទេ។ បញ្ហាដែលសួរទៅលើឯកសារហ្នឹង គឺនិយាយអំពីបញ្ជាក់យថាភាពទៅលើលេខជើងទំព័រទេ។ គឺសំណួររបស់ខ្ញុំ គឺខ្ញុំសួរអំពីរឿងសម្ភាសន៍នោះទេបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៧:៣២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា ចំពោះរបៀបការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ឃើញថាមិនសមស្របទេ។ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើលោកនៅចងចាំនូវសំណួរ!

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោកបានបញ្ជាក់ពីសេចក្តីខ្លឹមសារដកស្រង់ផ្អែកតាមលក្ខខណ្ឌបក្ស បាទ បក្ស ភូមិភាគ ហើយត្រូវដឹកនាំនយោបាយទៅដល់ថ្នាក់ស្រុក ហើយនិងទៅថ្នាក់ក្រោម។ ផ្អែកតាមបទសម្ភាសន៍ដែល

លោកមាន ហើយការទាក់ទងជាមួយអ្នកផ្តល់សម្ភាស តើលោកបានប្រមូលព័ត៌មានណាមួយថាមានការធ្វើបែបនេះដែរឬទេ?

[១០:០៨:៤៣]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ផ្អែកតាមបទសម្ភាសន៍ ហើយតាមពិតនោះជាសេចក្តីសង្ខេបនៃបទសម្ភាសន៍ យើងឃើញច្បាស់ ចម្លើយដែលច្បាស់បំផុតទៅនឹងសំណួរនេះ គឺថា បទសម្ភាសន៍ទូទៅរៀបរាប់អំពីទម្រង់នៃគោលនយោបាយត្រូវបាន -- ដែលបានសរសេរដូចដែលដកស្រង់នេះឯង ពីឯកសារ ប៉ុន្តែក្នុងពេលនោះដែរ គឺបទសម្ភាសន៍តែងតែបញ្ជាក់អំពីនយោបាយជាផ្លូវការ ហើយរចនាសម្ព័ន្ធជាផ្លូវការ មិនដំណើរការដូចដែលគេចែងនៅលើក្រដាសនោះទេ។ បាទ អ៊ីចឹងចម្លើយហ្នឹងគឺថា “បាទ” និង “ទេ”។

**ស៖** សូមអរគុណ។ ឥឡូវនេះនៅលើឯកសារដដែល គឺឯកសារ E3/190.1.398 គឺជើងទំព័រ ៧១ និង៧២។ “រហូត -- វាអាស្រ័យទៅនឹងមេដឹកនាំភូមិភាគក្នុងការកាន់ក្តាប់អំពីនយោបាយបក្ស ហើយសូមឲ្យថ្នាក់ស្រុក និងថ្នាក់ក្រោមអនុវត្តតាម មានតែលេខាភូមិភាគត្រូវមានអំណាចនឹងធ្វើការណែនាំទៅដល់រចនាសម្ព័ន្ធដល់ថ្នាក់ស្រុកនោះ”។ ហើយខ្ញុំឃើញថា លោកយោងទៅរកឯកសារ E3/8 គឺឯកសារ ប៉ុល ពត ការពន្យល់បឋម មុននឹងអានផែនការដោយមជ្ឈិមបក្ស “២១ សីហា ឆ្នាំ១៩៧៦ ទូរលេខ១៥ ដែលទាក់ទងទៅនឹង បងប៉ុល ជាទីស្រលាញ់”។ តើលោកអាចបញ្ជាក់ ថាតើទាំងអស់នោះជាប្រភពដែលបញ្ជាក់ពីខ្លឹមសារដែលនៅក្នុងសៀវភៅរបស់លោកនោះ?

**ឆ៖** បាទ។

[១០:១១:០៥]

**ស៖** លេខជើងទំព័រ៧៣ និង ៧៤ ឯកសារដដែល E190.1.398 “ការអនុវត្តនូវអំណាចនេះគឺលេខាភូមិភាគ ហើយនិងកម្មាភិបាលដឹកនាំភូមិភាគតែងតែប្រជុំជាញឹកញាប់នូវកម្មាភិបាល រហូតដល់ថ្នាក់ស្រុកហើយបញ្ជូនឯកសារលាយលក្ខណ៍អក្សរទៅថ្នាក់ស្រុក ហើយនិងថ្នាក់មូលដ្ឋានផ្សេងទៀត”។ ទាក់ទងទៅនឹងនេះគឺថា ជើងទំព័រលេខ៧៣ នៅក្នុងប្រជុំហ្នឹងកម្មាភិបាលភូមិភាគពិនិត្យមើលរបាយ-ការណ៍របស់ថ្នាក់ស្រុក ហើយពន្យល់អំពីនយោបាយបក្ស ហើយនិងណែនាំឲ្យមានការអនុវត្ត ហើយផ្តល់ការណែនាំ ហើយនិងស្វែងរកបញ្ហាជាក់លាក់។ ហើយនៅទីនេះលោកបានយោងទៅរកបទសម្ភាសន៍ជាមួយ កែ ពក។ តើនេះជាបទសម្ភាសន៍ដដែលដែលយើងបានពិភាក្សាខាងដើមនេះឬ?

[១០:១២:១៧]

**ឆ៖** បាទ។

**ស៖** មានឯកសារមួយទៀត ខ្ញុំនឹងអានគឺមិនមែននៅក្នុងសំណុំរឿងទេគឺ 1.6 "មេបញ្ជាការគឺតំបន់៣០២ (*ស៊ីក*) គឺបញ្ជូនទៅស្រុក ឃុំ ២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៥"។ ហើយឯកសារ 1.64 "តំបន់ ២៣ បញ្ជូនទៅស្រុកហើយនិងទីបញ្ជាការតំបន់ ថ្ងៃទី២២ តុលា ឆ្នាំ១៩៧៥" (បន្ទាប់ពីឯកសារនីមួយៗនោះ គឺមានឯកសារ ប៊ី.ឌី.អិន អក្សរ)។ តើលោកបានឃើញ ប៊ី.ឌី.អិន នោះ តើអក្សរកាត់នោះមានន័យដូចម្ដេចទាក់ទងទៅនឹងប្រភពនេះ?

**ឆ៖** តាមដែលខ្ញុំយល់គឺជាលេខកាតាឡុក បាទកាតាឡុកមកពីបណ្ណសាររបស់វៀតណាម។

**ស៖** តើលោកទទួលបានព័ត៌មាននេះដូចម្ដេច ដើម្បីយកមកប្រើជាបង្អែកនៃសៀវភៅរបស់លោកនោះ?

**ឆ៖** នោះបានពន្យល់នៅក្នុងជើងទំព័រមួយទៀតដែលខ្ញុំរកមិនទាន់ឃើញ -- ខ្ញុំឃើញប្រហែលអម្បាញ់មិញនេះឯងនៅក្នុងអត្ថបទនេះឯង បាទនៅក្នុងសំណុំឯកសារ។ ជាមូលដ្ឋាននោះគឺថា រឿងរ៉ាវខ្ញុំទទួលបានអត្ថបទជាភាសាអង់គ្លេសមួយឈុត ជាភាសាដែលមានលិបិក្រមទៅនឹងឯកសារពីរដោយ ប៉ាទ្រិកស្យា ហ្គូសា *(តាមសូរស័ព្ទ)* ដែលធ្វើការនៅក្នុងប្រវត្តិសាស្ត្រទំនាក់ទំនងប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍នៅដែនដីវៀតណាម-កម្ពុជានោះ ដែលគាត់ធ្វើបន្តមកពីបញ្ញវន្តដែលបានទទួលការសិក្សា និងស្រាវជ្រាវនៅប្រទេសវៀតណាម។

[១០:១៤:៤៦]

អ៊ីចឹងគឺថាមានឯកសារពីរប្រភេទមានការបកប្រែប្អូនច្បាប់ទៅលើឯកសារខ្មែរក្រហម ដែលវៀតណាមមាននោះ គឺថាមានលិបិក្រមជាភាសាវៀតណាមនៅលើឯកសារផ្សេងពីឯកសារផ្សេងទៀតហើយដែលវៀតណាមគេរក្សាទុក។ ហើយឯកសារទាំងអស់នោះ គឺគេបកប្រែមកឲ្យខ្ញុំ ដោយ រីឆាត អារិន ដែលធ្លាប់បានធ្វើការនៅទីនេះផងដែរ។

**ស៖** ខ្ញុំនឹងសួរបញ្ហានេះនៅពេលក្រោយ រីឆាត អារិន នោះ។ ប៉ុន្តែឯកសារដដែលគឺ *ហ្វូតណូត* ៧៨ គឺ E190.1.398 ថ្នាក់តំបន់ក៏បញ្ជូនការណែនាំជាឯកសារទៅថ្នាក់ស្រុក។ បាទ លេខជើងទំព័រនីមួយៗ គឺបានយោងទៅរកឯកសារមួយចំនួន។ ដូច្នេះឯកសារ 11551.66.50 ហើយនិង ប៊ី.ឌី.អិន លោកបានរៀបរាប់អំពីការប្រមូលផ្ដុំឯកសារនោះ។ តើលោកយកពីបណ្ដុំឯកសារដដែលហ្នឹង ឬយ៉ាង

ដូចម្ដេច?

**ឆ៖** បាទគឺជាឯកសារជាភាសាវៀតណាម ប្រភពដដែលនោះឯង។

**ស៖** ឥឡូវនេះខ្ញុំនឹងទៅប្រធានបទដោយឡែកមួយទៀត។ ហើយខ្ញុំនឹងឲ្យលោករៀបចំ *ហ្វាយឆ្វ* បាទអ៊ីចឹងគឺថាប្រធានបទហ្នឹង គឺនិយាយអំពីខ្មាំងបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការជួយមើលប្រដាប់ស្ដាប់សំឡេងគាត់ហ្នឹងមានបញ្ហាទេ។ មិនអីទេ!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តតាំងសំណួរ!

[១០:១៧:១៥]

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** គឺ *ហ្វាល*២ *ថេប*១ ឯកសារ E3/1714 សូមលោកមើលទំព័រ៦៦។ អង់គ្លេស ERN 00170757, ខ្មែរ 00324776 ដល់ 77 ហើយបារាំង 00649019 ដល់ 20។ នៅទំព័រ ៦៦ នៅផ្នែកខាងក្រោមលោក ហេដឌ័រ ហើយយោងទៅរកលេខ៣៣ នៅក្នុងឆ្នាំ១៩៨០, ម៉ែ រុត, លេខ ៣៣ ថ្ងៃទី១៦ ខែមីនា។ ហើយយើងមើលទំព័រមួយទៀត ដែលខ្ញុំនឹងជូនលេខ ERN។ បាទនេះ គឺស្រង់ចេញពីបុគ្គលនេះឯង។ “នៅឆ្នាំ១៩៧២ មានទាហាន លន់ នល់ ជាច្រើនដែលត្រូវបានគេចាប់ខ្លួន ប្រហែលជា ៥០០នាក់ឯណោះ។ អ្នកទាំងអស់នោះត្រូវបានគេសម្លាប់ គេមិនទុកអ្នកណាម្នាក់ទេ”។ តើលោកអាចបញ្ជាក់បានទេនេះគឺជាអ្វីដែលលើកឡើងនេះត្រឹមត្រូវ អ្វីដែលលោកបានឮនៅក្នុងបទសម្ភាសន៍ដែរឬទេ?

**ឆ៖** បាទ។

[១០:១៩:១៨]

**ស៖** នៅពេលដែលយើងនិយាយថាទាហាន -- ឯកសារយោងហ្នឹងគឺ ទាហានមកពីអង្គស្នួល តំបន់អង្គស្នួល។ ប៉ុន្តែយើងមិនទាន់ដឹងច្បាស់ ខ្ញុំឲ្យលោកមើលទំព័រ៦៧ ERN ខ្ញុំបានប្រាប់រួចហើយ គឺការយោងទៅរក “អតីតទាហាន លន់ នល់ គេបានតាមដានជននោះយ៉ាងប្រយ័ត្នរហូតនៅខាងក្រោមអតីតទាហាន លន់ នល់ គឺថានគរបាលតាមដានខ្ញុំ ហើយគេតាមដានខ្ញុំនៅពេលណា គ្រប់ពេលខ្ញុំដែលទៅទីណាកន្លែងណានោះ”។ តើនេះជាសេចក្ដីត្រឹមត្រូវតាមលោកបានឮពីអ្នកផ្ដល់សម្ភាសឬទេ?

**ឆ៖** បាទ នេះគឺនិយាយអំពីខ្មែរក្រហមប្រើពាក្យ "ទាហាន" គឺនិយាយទៅរកទាហានសាធារណរដ្ឋនោះឯង។

**ស៖** នៅក្នុងឯកសារ E3/1714 ទំព័រ៤៣ដដែល ទំព័រ៤៣, ឯកសារបទសម្ភាសន៍២៣ ទំព័រ៤៣។ បាទ បទសម្ភាសន៍២៣ ខែមីនា-- ថ្ងៃទី១០ ឆ្នាំ១៩៨០ នៅសាកែវ អ៊ុំ សាម៉ាន *(ស៊ីក)* នៅតំបន់២១ ភូមិភាគបូព៌ា។ គាត់និយាយនៅកថាខណ្ឌទី២ ខ្ញុំសូមជូន ERN ជាភាសាអង់គ្លេស 00170734, ខ្មែរ 00324742 ដល់ 3, បារាំង 00648998 ដល់ 9។ បាទ ទំព័រទី២ដំបូង នៅក្នុងកថាខណ្ឌទី២ "អ៊ុំ សម្អាង: នៅក្នុងសម័យសង្គ្រាម ខ្ញុំស្ថិតនៅក្នុងកងទ័ពតំបន់រហូតដល់ឆ្នាំ១៩៧០"។

[១០:២២:១០]

ឥឡូវនេះខ្ញុំមើលទំព័រ៤៦ អង់គ្លេស ERN 00170737, បារាំង 00649000 ដល់ 01, ខ្មែរ 00324746។ "ប្រជាជនដែលនៅមានការភ័យខ្លាចមិនដឹងថា តើកម្មាភិបាលប៉ុន្មាននាក់អាចគេចោទថាជាខ្មាំង។ ប៉ុន្តែខ្សែកម្មាភិបាលទាំងអស់ រហូតដល់ទៅដល់ថ្នាក់ក្រោម គេដឹងថា មានបញ្ហាអាក្រក់កើតឡើង ប៉ុន្តែគេមិនអាចធ្វើអ្វីបានទេ ដោយសារខ្លាចគេចាប់ខ្លួនពួកគេនោះដែរ។ វិធីសាស្ត្រចាប់ខ្លួនគឺគេហៅអ្នកនោះឲ្យទៅចូលវគ្គសិក្សារៀនសូត្រ បើគេមិនព្រមទៅ គេប្រាប់ថាជាភារកិច្ចរបស់គេត្រូវតែចូលវគ្គនោះ។ គេមិនចាប់ទៅតាមអំណាចរបស់មជ្ឈិមទេ គឺគេ គឺលេខាថ្នាក់តំបន់ និងភូមិភាគ ឬក៏លេខាខាងយោធាតំបន់ គេអ្នកចាប់។ ហើយគេកោះហៅអ្នកទាំងនោះ ថាឲ្យទៅកន្លែងមួយរៀនសូត្រ បន្ទាប់មកគេចាប់អ្នកនោះ។ វិធីសាស្ត្រដូចគ្នានោះ គឺគេប្រើដែរ ប្រឆាំងមន្ត្រី លន់ នល់ ក្នុងឆ្នាំ១៩៧៥។ គេប្រាប់អ្នកទាំងអស់នោះ ឲ្យទៅជួបអង្គការដោយស្ម័គ្រចិត្ត ហើយនិងលើកលែងទោសឲ្យ។ បន្ទាប់គេយកអ្នកទាំងអស់នោះទៅសម្លាប់ចោល។ មានអង្គភាពសន្តិសុខពិសេសដែលភ្ជាប់ទៅនឹងគណៈមជ្ឈិមដែលទទួលខុសត្រូវក្នុងការងារទាំងអស់នេះ។ នៅថ្នាក់មជ្ឈិម កងទ័ពនោះ គឺថាមាននៅភ្នំពេញ គេបញ្ជូនអ្នកទាំងអស់នោះទៅឲ្យមន្ទីរសន្តិសុខ។ តាមពិត អង្គភាពសន្តិសុខពិសេសមាននៅគ្រប់លំដាប់ ចាប់ពីគណៈមជ្ឈិមរហូតទៅដល់ថ្នាក់ភូមិភាគ តំបន់ ហើយនិងស្រុក។ ម្នាក់ៗទទួលខុសត្រូវក្នុងបញ្ហាសន្តិសុខ ហើយក៏នឹងត្រូវសម្លាប់អ្នកដែលគេចោទនៅក្នុងតំបន់របស់ខ្លួនដែរ"។ តើលោកសាក្សីអាចប្រាប់បានទេថា តើខ្លឹមសារទាំងអស់នេះ លោកបានស្តាប់ពីអ្នកផ្តល់បទសម្ភាសន៍ទាំងនោះដែរឬទេ?

**ឆ៖** បាទ។

[១០:២៥:០៦]

**ស៖** នៅក្នុងព័ត៌មានដដែលគឺ E3/1714 លោកសាក្សីទៅមើលទំព័រ២៥។ តើលោកមានបទសម្ភាសន៍លេខ១៥ទេ? ថ្ងៃទី០៧ មីនា ឆ្នាំ១៩៨០, សាកែវ, អង់គ្លេស 00170716, ខ្មែរ 00324712, បារាំង 00648981 ដល់82។ ប្រភពអតីតនីរសាររបស់ ជ័យ សួន ក៏មានឈ្មោះហៅថា ណុន សួន ដែរ។ សូមលោកពន្យល់តុលាការដោយសង្ខេបថា តើ ណុន សួន នេះជាអ្នកណាបាទ?

**ឆ៖** ជាអតីតទាហានកុម្មុយនីស្តចុងទសវត្សរ៍ឆ្នាំ១៩៧០ ហើយគាត់ជាប្រធានគណៈកសិកម្មនៅថ្នាក់មជ្ឈិម គឺមានឋានៈស្មើនឹងរដ្ឋមន្ត្រីក្រសួងកសិកម្ម។

**ស៖** ទំព័រ២៨ អង់គ្លេស ERN 00170719, ខ្មែរ 00324717, បារាំង 00648984។ "នៅតំបន់២៥ យើងត្រូវបានគេប្រាប់ឲ្យរៀបចំទទួលអ្នកជម្លៀសមកពីភ្នំពេញ នៅតែថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ តែប៉ុណ្ណោះ យើងត្រូវបានណែនាំឲ្យរៀបចំអាហារ និងទឹក និងកន្លែងស្នាក់នៅសម្រាប់អ្នកជម្លៀសមក និងកាប់គោក្របី ដើម្បីឲ្យពួកហូប និងផ្តល់បាយឲ្យពួកគេ។ ស្រុកនីមួយៗត្រូវបានគេតម្រូវឲ្យទទួលយកជនជម្លៀសចំនួនប្រហែល ដែលគេកំណត់ប្រាប់យើងថា គេប្រាប់យើងថា ប្រសិនបើអ្នកជម្លៀសទាំងនោះធ្វើឲ្យមានបន្ទុកធ្ងន់នៅក្នុងសហករណ៍ពួកគេត្រូវទៅជួបគណៈឃុំ ឬក៏គណៈស្រុក ដើម្បីឲ្យគេជួយដោះស្រាយនៅបញ្ហា។ ក្នុងចំណោមអ្នកជម្លៀសទាំងនោះ អតីតទាហានលន់ នល់ ជាពិសេសនាយទាហាន ត្រូវបានគេចាត់ទុកថាជាខ្មាំង"។

[១០:២៨:២២]

តើនេះជាការកត់ត្រាត្រឹមត្រូវអំពីអ្វីដែលលោកបានស្តាប់ឮនៅក្នុងបទសម្ភាសន៍ទាំងនេះ -- ទាំងនោះដែរឬទេ?

**ឆ៖** បាទ ភ្ជាប់ទៅនឹងអ្វីដែលស្ថិតនៅក្នុងកថាខណ្ឌទាំងមូលនោះដែរ។

**ស៖** នៅក្នុងសំណុំឯកសារដដែល *ថេប*ទី៦ ឯកសារ E3/390។ ខ្ញុំមិនទាន់បញ្ជាក់ឈ្មោះទេ យើងត្រូវពិនិត្យ គឺថាបទសម្ភាសន៍ E3/390នេះ។ តើលោកអាចបញ្ជាក់បានទេ នៅទំព័រទី១ អ្នកសម្ភាសគឺ ស្ទីវ ហេដឌ័រ អ៊ីចឹងមែនឬទេ?

**ឆ៖** ហើយខ្ញុំពិនិត្យមើលហ្នឹង ថាតើនិយាយអំពីការសរសេរឈ្មោះនៃអ្នកផ្តល់បទសម្ភាសន៍ សូមឲ្យពេលខ្ញុំ២, ៣នាទី។

*(សម្រាករយៈពេលខ្លី)*

[១០:៣០:១៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកសាក្សី អរគុណតំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី នៅក្នុងអំឡុងពេលឈប់សម្រាកដល់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។ ហើយសូមឲ្យគាត់ពិនិត្យនូវឯកសារ ដែលបានបញ្ជាក់អម្បាញ់មិញនេះផងដើម្បីឲ្យគាត់មានមូលដ្ឋានក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់លើឯកសារនេះនៅពេលដែលចូលត្រឡប់មកវិញ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊្មីវ ហេងឆ័រ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក ហេងឆ័រ មុនពេលដែលខ្ញុំសួរសំណួរលោកអំពីឯកសារដែលលោកមាននៅក្នុងដៃ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់លាស់ឯកសារចុងក្រោយអម្បាញ់មិញ។ សំណុំឯកសារទី២ដដែល *ថេប២* ទំព័រ ២៨ ឯកសារ E3/1714។

[១០:៥៤:៣៥]

ខ្ញុំសូមលើកឡើងសាថ្មីដើម្បីឲ្យលោកយល់ពីបរិបទរួម។ "នៅក្នុងចំណោមអ្នកដែលត្រូវបានជម្លៀសនោះ គឺថាគឺមន្ត្រី លន់ នល់ និងកងទ័ព លន់ នល់ ត្រូវបានចាត់ទុកជាខ្មាំង។ អ្នកដែលទទួលខុសត្រូវចំពោះការកាប់សម្លាប់នោះ ដែលត្រូវបានគេចាត់ទុកថាជាខ្មាំង។ ក្រៅពីរដ្ឋមន្ត្រី មន្ត្រីរដ្ឋការ គឺមិនត្រូវបានគេចាត់ទុកថាជាខ្មាំងនោះទេ"។ លោកអាចបញ្ជាក់បានដែរឬទេ នេះជាចម្លើយដែលគេ អ្នកដែលលោកត្រូវសម្ភាសនេះបានឆ្លើយប្រាប់លោកក្នុងពេលសម្ភាស?

**លោក ស្មីរ ហេដឌ័រ៖**

**ឆ៖** ជាការពិត គឺជាចម្លើយនោះមែន។

**ស៖** នៅពេលនេះ ខ្ញុំសូមចូលទៅដល់ឯកសារដែលលោកមាននៅក្នុងដៃ។ គឺឯកសារមួយដែលលោកបានពិនិត្យមើលក្នុងពេលឈប់សម្រាកអម្បាញ់មិញនេះ ឯកសារ E3/390។ ឯកសារមួយច្បាប់ដែលលោកបានយកចេញទៅជាមួយ។ តើលោកអាចបញ្ជាក់ទេ គឺលោកមានឯកសារនេះមែន?

[១០:៥៥:៣៥]

សំណួរទី១របស់ខ្ញុំ គឺយើងឃើញថានៅលើឯកសារនេះ មានឈ្មោះ សំណុំឯកសារ២ *ថេបង*។ តាមការអះអាងនូវចម្លើយនេះ តើលោកអាចជួយបញ្ជាក់បានដែរឬទេ ឈ្មោះដែលមាននៅលើឯកសារនេះ គឺជាឈ្មោះមួយដែលត្រឹមត្រូវ ឬក៏ជាឈ្មោះបុគ្គលផ្សេងទៅវិញទេ?

**ឆ៖** ខ្ញុំបានពិនិត្យមើលទៅលើឯកសារនេះ។ ឈ្មោះនេះ គឺថាឈ្មោះគឺជាបុគ្គលហ្នឹងមែន នៅខាងលើ ខាងស្តាំ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន មិនមានរហស្សនាម ឈ្មោះរហស្សនាមសម្រាប់បុគ្គលនេះទេ។ ដូច្នេះសូមការអនុញ្ញាតពីលោកប្រធាន ខ្ញុំហៅបុគ្គលនេះ ដោយឈ្មោះបានដែរឬទេ? សូមអនុញ្ញាតហៅដោយឈ្មោះតែម្តងទៅ ដោយសារតែមិនមានឈ្មោះរហស្សនាម។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៦:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ លោកតំណាងសហព្រះរាជអាជ្ញាមិនមានបញ្ហាអីទេ។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** គឺ ម៉ាត់ លី ឈ្មោះនេះមានឈ្មោះ ម៉ាត់ លី។ សូមឲ្យយើងពិនិត្យមើលទំព័រ៣០ ERN ជាភាសាអង់គ្លេស 00436875, ខ្មែរ 00392106 ដល់ 07។ ខ្ញុំសូមអធ្យាស្រ័យទំនងជាមិនមានជាភាសាមួយទៀត គឺខ្ញុំមិនមានលេខ ERN ជាភាសាបារាំងនោះឡើយ សូមអធ្យាស្រ័យ។ ខ្ញុំកំពុងតែមើលនៅទំព័រចុងក្រោយនៃអត្ថបទជាភាសាបារាំង។ នៅក្នុងការពន្យល់តួនាទីរបស់គាត់ នៅក្នុងចំណុចមួយចំនួនគាត់បានលើកឡើងថា "គាត់ជាគណៈសមាជិកស្រុក ហើយគាត់ជាគណៈស្រុក និងគណៈសមាជិកអចិន្ត្រៃយ៍សភាផងដែរ"។ តើចំណុចនេះ ត្រឹមត្រូវដែរឬទេ គឺគេប្រាប់លោកដូច្នេះនៅក្នុងពេលសម្ភាសមែនដែរឬទេ?

[១០:៥៨:០៣]

**លោក ស៊ីវ ហេងឥវ៖**

**ឆ៖** បាទ គាត់ប្រាប់ដូច្នេះមែន។

**ស៖** ខ្ញុំសូមឲ្យលោកមើលទំព័រ២២ ត្រឡប់ទៅទំព័រ២២វិញ។ នៅខាងក្រោម ប្រយោគដែលនិយាយថា "គោលនយោបាយក្នុងស្រុក" តើលោកមើលឃើញហើយឬនៅ? ខ្ញុំសូមអានចំណុចនេះតែម្តង។ គោលនយោបាយក្នុងស្រុក ចាប់ផ្តើមពីចំណុចនេះទៅ "គឺវាមានចាំបាច់ក្នុងការដឹកត្រង់សេនៅតាមមូលដ្ឋាន។ ជាពិសេសគឺដើម្បីសម្រាប់ប្រជាជនក្រុង។ ទោះបីជាមានអ្នកស័ក្តិ១ ឬក៏ស័ក្តិ២ ក៏ដោយដែលធ្លាប់ធ្វើការងារ អ្នកទាំងអស់នោះ គឺត្រូវបានគេសម្លាប់ចោល។ ចំណុចនេះហើយ គឺថាយើងអាចសម្លាប់ពួកវា ហើយយើងចាត់ទុកពួកវាជាខ្មាំង។ ពួកគេនេះបម្រើខ្មាំង ទី១គឺបរិវារ សេ.អ៊ី.អា។ សេ.អ៊ី.អា នេះបានន័យថា របស់ខាងអាមេរិក។ ទី២គឺខាងពួកគាត់ជា ខេ.ជី.ប៊ី – កា.ហ្សេ.បេ – ដែលជារបស់រុស្ស៊ីបម្រើយួន។ ពួកគេបានធ្វើការងារដើម្បីសម្របសម្រួលការសម្លាប់"។

[១០:៥៩:៣៤]

នៅក្នុងសំណួរដែលលោកបានសួរនោះ គឺលោកសួរថា "តើមានលទ្ធភាពណាមួយក្នុងការទប់ស្កាត់ចំណុចនេះទេ? គេចាប់ខ្លួន ខ្ញុំជាគណៈស្រុក ខ្ញុំជាសមាជិករបស់សភាផងដែរ។ គេសួរខ្ញុំហេតុអ្វីហេតុអ្វីបានគេចាត់ទុកថា សេ.អ៊ី.អា។ ខ្ញុំសួរពួកគេ ពួកគេឆ្លើយថា ពួកគេជាគិញយួន។ គ្រាន់តែសួរថា

ហេតុអ្វីទៅ? ពួកគេគ្រាន់តែឆ្លើយថា ពួកគេជា កា.ហ្សេ.បេ។ ចាប់ពីពេលនោះមក គឺថាការកាប់សម្លាប់បានកើតឡើង។ ការបន្តការកាប់សម្លាប់ គឺបានចាប់ផ្តើមក្រោយពេលរំដោះក្នុងឆ្នាំ១៩៧៥ រហូតមកដល់យើងបានរំដោះប្រទេសទាំងស្រុងនៅក្នុងឆ្នាំ១៩៧៩"។ តើលោកអាចបញ្ជាក់ទេ ចំណុចទាំងអស់នេះគេបានប្រាប់លោកក្នុងពេលសម្ភាស?

**ឆ៖** បាទ គាត់ប្រាប់ខ្ញុំដូច្នេះ។

**ស៖** នៅក្នុងទំព័រដដែលគេនិយាយថា "ក៏ប៉ុន្តែខ្ញុំគិតថា លោកអ្នកមើលការកាប់សម្លាប់ គេសម្លាប់តែអ្នកប្រជាជនធំ ហើយនិងអ្នកអប់រំ។ អ្នកទាំងអស់នោះ គឺត្រូវបានគេចាត់ទុកដូច្នោះ នៅពេលដែលយើងដឹងថា គាត់ជាសិស្ស និស្សិត គ្រូ យុទ្ធជន ឬក៏មន្ត្រីរដ្ឋការ វេជ្ជបណ្ឌិត គឺពួកវាសម្លាប់អ្នកទាំងអស់នេះចោលទាំងអស់។ ហេតុអ្វីបានជាបញ្ញាជនច្រើននៅសល់? តាមអ្វីដែលខ្ញុំដឹង បញ្ញាជននោះ គឺថាលាក់ប្រវត្តិរូបរបស់ពួកគេ។ ហើយការងាររបស់គេនោះ គឺថាគេមិនឲ្យដឹងនោះឡើយ។ ការស្វែងរកអ្នកទាំងអស់នោះ គឺសូមឲ្យអ្នកទាំងអស់នោះ និយាយដោយស្មោះត្រង់។ តើលោកដឹងអ្វីខ្លះ? ការងារអ្វីខ្លះ? យើងរៀបចំឋានៈឲ្យស្មើ ធ្វើការឡើងវិញ អ៊ីចឹងប្រជាជនខ្មែរ គឺស្មោះត្រង់ណាស់ តែគេនិយាយអីសរសេរហ្នឹងហើយ ដល់សរសេរទៅអាប្រវត្តិរូបហ្នឹង ដែលសម្លាប់ខ្លួនឯង។ តែអ្នកខ្លះក៏គិតគូរដែរ នៅតែមិនអស់ចិត្ត ថាខ្ញុំនៅឯណោះធាក់ស៊ីក្លូ នៅនោះជាកម្មករទេ។ អាហ្នឹងអាចរួចខ្លួនខ្លះ"។ តើលោកអាចបញ្ជាក់ទេចំណុចនេះ គឺគេប្រាប់លោកនៅក្នុងពេលសម្ភាស?

[១១:០២:១០]

**ឆ៖** បាទ គេប្រាប់ខ្ញុំដូច្នេះមែន។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ដដែលទំព័រ២៩, ERN ជាភាសាអង់គ្លេស 00436874, ខ្មែរ 0039 2105 ខ្ញុំមានលេខ ERN ជាភាសាបារាំង 00479818។ "ខ្ញុំខ្លួនឯងបានឃើញការកាប់សម្លាប់ ចាប់ផ្តើមពីឆ្នាំ១៩៧៥ នៅពេលដែលគាត់ (សំដៅលើ ប៉ុល ពត) បានកាន់កាប់អំណាចពេញលេញនៅក្នុងផែនការរបស់គាត់ គឺពេលនោះហើយដែលចាប់ផ្តើមឡើង។ ដូចដែលខ្ញុំបាននិយាយពីខាងដើមសួរពួកគេទៅពួកគេឆ្លើយថាជា សេ.អ៊ី.អា សួរពួកគេទៅពួកគេថា ជាវរសេនីយ៍ ឬក៏អនុសេនីយ៍ស័ក្តិ១ ស័ក្តិ២ ហើយនិងជាជនជាតិចាម។ ខ្ញុំក៏ជាជនជាតិចាមផងដែរ។ ពួកគេដឹកអ្នកទាំងអស់នោះទៅ ចេញទៅ។ ពួកគេមិនឲ្យអង្គុយនោះទេ។ មិនឲ្យពួកគាត់ដេក ហើយគេមិនឲ្យនគរបាល ឬក៏យោធានោះអង្គុយផងដែរ។ គេចាប់កម្មាភិបាលម្តងម្នាក់ៗ ម្នាក់ជាឈុត ហើយនិងក៏ចាប់មហាជនរួមទាំងយុទ្ធជនផងដែរ"។

តើលោកអាចបញ្ជាក់ទេ ចំណុចទាំងអស់ហ្នឹងគេបានប្រាប់លោកក្នុងពេលសម្ភាស?

**ឆ៖** បាទ គេប្រាប់ដូច្នេះមែន។

**ស៖** ខ្ញុំសូមឱ្យលោកមើលសំណុំឯកសារទី២ *ថេប៥* ។ ជាថ្មីម្តងទៀត មិនបញ្ជាក់ឈ្មោះបុគ្គលនេះទេ។ ទំព័រទី១ បន្ទាប់ពី*ថេប៥*, ERN ជាភាសាអង់គ្លេស00352076 ឯកសារមានលេខ D224.81។ នេះជាលេខឯកសារ D224.81។

[១១:០៥:១៨]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធានគ្មានរហស្សនាមទេ។ ហេតុដូច្នេះហើយ ខ្ញុំសូមហៅឈ្មោះបុគ្គលនេះប្រើឈ្មោះតែម្តង។

**ប្រធានអង្គជំនុំ៖**

បាទ លោកអាចធ្វើដូច្នេះបាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** បុគ្គលនេះឈ្មោះ វៀម ឌី។ គាត់បានឆ្លើយដូចតទៅ "ភូមិភាគពាយ័ព្យបានសម្លាប់ច្រើនណាស់ក្រោយ១៧ មេសា ឆ្នាំ៧៥។ ការជម្លៀសបាត់ដំបង មិនទាន់បានចប់ពេញលេញនៅឡើយទេនៅពេលកម្មាភិបាលពាយ័ព្យបានចាប់ផ្តើមសម្លាប់មនុស្សនៅក្នុងពេលជម្លៀស។ ពួកគេបានសម្លាប់អ្នកដែលនៅក្នុងជួរទាហាន និងអ្នករដ្ឋការដែលមានបណ្តាស័ក្តិ។ អ្នកទាំងអស់នេះត្រូវគេយកទៅសម្លាប់ចោល"។ តើចំណុចនេះ គឺគេប្រាប់លោកនៅក្នុងពេលសម្ភាសមែនដែរឬទេ?

**លោក ស៊ីវ ហេងឌ័រ៖**

**ឆ៖** បាទ ពិតជាដូច្នោះមែន។

[១១:០៦:៣៨]

**ស៖** នៅពេលនេះ ខ្ញុំសូមឱ្យលោកត្រឡប់ថយក្រោយលើមើលឯកសារមួយដែលលោកមាននៅក្នុងដៃ ដែលយើងបានពិភាក្សាគ្នាមុននេះបន្តិច។ ឯកសារលេខ E3/387 គឺ TCW-494 លេខទី១នៅខាងឆ្វេងខាងលើ 00350200។ TCW-494 គឺសរសេរមានលេខហ្នឹងនៅលើទំព័រទី១តែម្តង។ លោកអាចមើលឃើញបាន។ នៅពេលនេះខ្ញុំសូមឱ្យលោមើលទំព័រទី៦ ERN ជាភាសាអង់គ្លេស 00350205, ខ្មែរ 00379486, បារាំងមានលេខ 00441418។

នៅខាងក្រោមទំព័រដែលលោកមើលនោះគឺ នៅក្នុងខែមេសា សំដៅលើឆ្នាំ៧៥ តាមរយៈកថាខណ្ឌដែលយើងអាចមើលខាងក្រោម។ “នៅក្នុងខែមេសា ប៉ុល ពត ចេញនូវគោលនយោបាយសម្ងាត់មួយ គឺកម្ទេចរាល់សមាសធាតុទាំងអស់នៅក្នុងរបប លន់ នល់។ ចំពោះអ្នកជាជនជាតិស៊ីវិល និងអ្នកស្រុក អ្នកទាំងអស់នោះនឹងត្រូវបោសសម្អាតចេញមកពីឃុំ ទៅរហូតទៅដល់ថ្នាក់លើ។ ពាក់ព័ន្ធទាហានអ្នកទាំងអស់នោះត្រូវតែបោសសម្អាតឲ្យអស់ចាប់ពីស័ក្តិ១ រហូតទៅដល់ឧត្តមសេនីយ៍”។ តើលោកអាចបញ្ជាក់បានដែរឬទេ ចំណុចនេះគឺគេប្រាប់លោកនៅក្នុងពេលសម្ភាសនោះ?

[១១:០៩:០២]

**ឆ៖** ខ្ញុំសូមលេខខ្មែរ ERN សាជាថ្មី។ បាទ ខ្ញុំបានឃើញហើយ។ បាទ គឺអត់ដូចគ្នាទេ ឯកសារនេះដូចដែលលោកបានបញ្ជាក់អំមិញ គឺខុសគ្នា។

**ស៖** 00379486 លេខ ERN ជាភាសាខ្មែរ។ ហើយខ្ញុំអ្វីដែលខ្ញុំអានអម្បាញ់មិញចេញពីចំណុចខាងក្រោមនៅក្នុងទំព័រនោះ។ បាននៅពេលនេះឃើញហើយនៅលើអេក្រង់។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺយើងខ្ញុំទាំងអស់គ្នារកឯកសារហ្នឹងអត់ឃើញទេ គឺយើងខ្ញុំរកអត់ឃើញទេ មិនដឹងឯកសារលេខប៉ុន្មានទេ?

**លោក ឃីត រស្មីន័រ៖**

គឺឯកសារ E3/387។

[១១:១០:៤៨]

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ពិតមែន។ ភាសាអង់គ្លេសអាចអានខុសបន្តិចបន្តួច អាចច្រឡំបន្តិចបន្តួចតាមការយល់ឃើញរបស់ខ្ញុំ។ ពាក្យដែលប្រើប្រាស់នោះគឺថា“បោសសម្អាត”។ តាមដែលខ្ញុំយល់ខ្មែរមិនបានលើកឡើងថាសមាសភាពទាំងអស់នោះទេ។ អត់មានប្រើពាក្យថាទាំងអស់នោះទេ គ្រាន់តែថាសម្អាតសមាសភាព។ ពាក្យដែលគេប្រើប្រាស់នៅក្នុងនេះគឺគ្រាន់តែថានៅក្នុងរបប លន់ នល់ នោះ មិនមែនថាសមាសភាពទាំងអស់នោះគឺត្រូវបានគេបោសសម្អាតនោះទេ។ ហើយគេមិនបានកំណត់និយមន័យច្បាស់លាស់អំពីសមាសភាពនៅក្នុងរបបនោះទេ។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ខ្ញុំសូមបញ្ជាក់លើប្រយោគចុងក្រោយដែលខ្ញុំបានដកស្រង់ "ពាក់ព័ន្ធនឹងទាហាន វាចាប់ផ្ដើមឲ្យបោសសម្អាតពីនាយទាហានស័ក្តិ១ ឡើងទៅរហូតដល់ឧត្តមសេនីយ៍"។ តើត្រឹមត្រូវដែរឬទេតាមការបកប្រែនោះ?

**ឆ៖** បាទ ត្រឹមត្រូវហើយចំពោះការបកប្រែនេះ។

[១១:១២:១៤]

**ស៖** ទំព័របន្ទាប់គឺទំព័រ៧ ខ្មែរ ERNគឺ 00379488 ខ្ញុំសូមអធ្យាស្រ័យខ្ញុំអត់មាន ERN ជាភាសាបារាំងទេ។ នៅខាងក្រោម ទំព័រ៧, "នៅក្នុងខែឧសភា ឆ្នាំ ១៩៧៥ ប៉ុល ពត បានកោះអញ្ជើញកម្មាភិបាលថ្នាក់ស្រុក ថ្នាក់តំបន់ ទូទាំងប្រទេស កម្មាភិបាលយោធា និងចាប់ពីកងវរសេនាតូចឡើងទូទាំងប្រទេសគឺមកជួបជុំគ្នានៅសាលាបច្ចេកទេសមិត្តភាពកម្ពុជា-សូវៀត។ ពេលនោះ វាប្រកាសនូវគោលនយោបាយថ្មីរបស់វា គោលនយោបាយថ្មីនោះ វានិយាយថាត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមតទៅទៀត។ អានេះជាគោលនយោបាយក្នុងខ្លឹមសារនៃបដិវត្តន៍សង្គមនិយមនេះ វាបានកំណត់អ៊ីចេះ ត្រូវតស៊ូប្រឆាំងដោយម៉ឺងម៉ាត់ គាស់រំលើងនូវរបបចាស់លើនយោបាយសតិអារម្មណ៍ ផ្នែកចាត់តាំង។ អានេះវាប្រកាសអ៊ីចឹង។ ពីព្រោះវាយល់ថា បើកាលណាមិនគាស់រំលើងឥទ្ធិពលនៃរបបចាស់ខាងវិស័យនយោបាយ យោធា សេដ្ឋកិច្ច សង្គម និងសតិអារម្មណ៍ទេ មិនអាចធ្វើបដិវត្តន៍សង្គមនិយមទៅបានទេ។ នេះគឺគេកំណត់គោលនយោបាយរួមរបស់គេ។ បានគេបញ្ជាក់ទៀតថា ការបន្តធ្វើបដិវត្តន៍សង្គមនិយមនឹងគាស់រំលើងនូវរាល់ឥទ្ធិពលកាកសំណល់ចាស់នៃរបបចាស់លើគ្រប់វិស័យនេះ។ នៅឯណា? គេបានបញ្ជាក់ច្បាស់ថានៅលើ ទៅលើកម្មាភិបាល ទៅលើបុគ្គលិករដ្ឋ និងយោធា។ អាហ្នឹងគឺធ្វើនៅកន្លែងហ្នឹង។ អានេះ គោលនយោបាយធំក្នុងកិច្ចការកសាងសង្គមនិយមរបស់គេ"។

ខ្ញុំសង្ឃឹមថាលោកមាន លោកអាចអាន ភាសាខ្មែរនៅលើអេក្រង់។ ដូច្នេះសំណួរសួរដដែលទេ តើលោកអាចបញ្ជាក់បានដែរឬទេ ការដែលបក ប្រែនេះគឺថាវាបកទៅតាមពាក្យដែលគេនិយាយក្នុងនេះត្រឹមត្រូវ?

[១១:១៤:៤១]

**ឆ៖** ក៏ប៉ុន្តែមានចំណុចពីរ លើកលែងតែចំណុចពីរ។ លើសពីនេះគឺថា ពាក្យថាសតិអារម្មណ៍នេះខ្ញុំគិតថាវាសំដៅលើមនោគមវិជ្ជា។ ហើយពាក្យថាគេបញ្ជាក់ ហើយនិយាយថាទៅលើកម្មាភិបាល

បុគ្គលរដ្ឋ និងយោធា កម្មាភិបាលនេះ សំដៅទៅលើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បុគ្គលិករដ្ឋ និងយោធាសំដៅលើបុគ្គលិករដ្ឋនិងយោធាកម្ពុជាប្រជាធិបតេយ្យ មិនមែនរបស់ខាងសាធារណរដ្ឋនោះឡើយ គឺពួកដែលនៅក្នុងជួររបស់កម្ពុជាប្រជាធិបតេយ្យ។

**ស៖** ដោយមិនចាំបាច់បញ្ជាក់ឈ្មោះ តើបុគ្គលដែលលោកសម្ភាសនេះឈ្មោះអីដែរ? គឺនរណាដែរ? ហើយគាត់មានតួនាទីអ្វីដែរចន្លោះឆ្នាំ៧៥ ដល់៧៩ គឺតួនាទី និងងាររបស់គាត់នេះខ្លីៗបានហើយ?

**ផ៖** ក្នុងអំឡុងពេលនោះ ភាគច្រើនគឺគាត់ជាអនុលេខាតំបន់២១ នៅខាងភូមិភាគបូព៌ា ហើយគាត់ជាសមាជិកភូមិភាគបូព៌ា សមាជិកគណៈអចិន្ត្រៃយ៍ខាងភូមិភាគបូព៌ា។

[១១:១៦:០៦]

**ស៖** សូមអរគុណ។ យើងនៅក្នុងសំណុំឯកសារទី២ យើងកំពុងមើលសំណុំឯកសារទី២ ក៏ប៉ុន្តែនៅពេលនេះសូមឲ្យលោកមើលសំណុំឯកសារទី៤វិញម្តង។ សំណុំឯកសារទី៤ *ថេប១* ឯកសារ E190.1.398 *ហ្វូតណូត* ២០, ២១, ២២ ត្រង់ទំព័រ៧ សម្រាប់លោកឲ្យលោកមើលទំព័រ៧។ នៅក្នុងនេះនិយាយអំពីបណ្តាញនោះមានដល់កម្រិតណាទៅ។ លោកបាននិយាយអំពីការពង្រីក ការកាប់សម្លាប់ដោយធ្វើឡើងរហូតដល់ជួរយោធា និងមន្ត្រីមេបញ្ជាការនគរបាល។ មន្ត្រីរដ្ឋការដែលមានឋានៈស្មើគ្នាក៏ត្រូវបានសម្លាប់។ អ្នកបណ្តាស័ក្តិក៏បានសម្លាប់ផងដែរ។ ទោះបីជាមិនមែនជាសាមញ្ញទាហានក៏ដោយ។ នៅក្នុងចំណុចនេះ គឺលោកបានយោងទៅលើឯកសារ E3/79 កិច្ចសម្ភាសន៍ដែលលោកធ្វើឡើងជាមួយអៀង សារី ថ្ងៃ១៧ ខែកញ្ញា ឆ្នាំ៩៦។

[១១:១៧:៥៣]

ពាក្យថា បណ្តាស័ក្តិនៅក្នុង *ហ្វូតណូត* គឺលោកសំដៅទៅលើកងកម្លាំងប្រដាប់អាវុធ និងមេបញ្ជាការនគរបាល។ បណ្តាស័ក្តិក៏សំដៅទៅលើមន្ត្រីរដ្ឋការនៅមុនរបបកុម្មុយនីស្ត។ ហើយវាត្រូវជាមួយនឹងបណ្តាស័ក្តិដែលពួកគេមាននៅក្នុងឋានានុក្រមនោះផងដែរ។ ហើយកំណត់ហេតុកម្មាភិបាលពីរដែលយើងបានពិភាក្សាគ្នារួចមកហើយ ក៏មានយោបល់បន្ថែមថា សេចក្តីសម្រេចនេះផ្ទុះបញ្ចាំងអំពីការវាយតម្លៃជាផ្លូវការថា អំពីការបំបែកវណ្ណៈដែលទាហាន និងនគរបាលគឺស្ថិតនៅក្នុងពួកប្រតិកិរិយា ទោះបីជាអ្នកទាំងអស់នោះមិនមែនជាពួកប្រតិកិរិយាក៏ដោយ។ លោកបានយោងទៅលើឯកសាររបស់លោកប៊ែនឃៀរនិន។ ខ្ញុំគ្រាន់តែចង់សួរលោកអំពីពាក្យថា "បណ្តាស័ក្តិ" លោកបាននិយាយអំពីមន្ត្រីរដ្ឋការដែលស្ថិតនៅក្នុងមុនរបបកុម្មុយនីស្ត ដែលក្នុងនោះគេពាក់សម្លៀកបំពាក់ ហើយមានរូបសញ្ញាដែលបង្ហាញ

អំពីបណ្ដាស័ក្ដិរបស់គេផង។ តើលោកអាចបញ្ជាក់ចំណុចនេះបានដែរឬទេ?

[១១:១៩:១៩]

**ឆៈ** តាមការចងចាំរបស់ខ្ញុំនូវអ្វីដែលខ្ញុំបានឃើញ នៅពេលដែលខ្ញុំស្ថិតនៅក្នុងប្រទេសកម្ពុជាក្នុងរបបសាធារណរដ្ឋខ្មែរនៅពេលនោះ គឺខ្ញុំឃើញដូច្នោះមែន។

**សៈ** ខ្ញុំសូមចូលទៅដល់ឯកសារ*ថេប* ឯកសារសំណុំឯកសារទី៤នេះដដែល ក៏ប៉ុន្តែ*ថេប*៥។ ឯកសារ E3/48 បេក្ខជនប្រាំពីរនាក់ ដែលអាចនឹងត្រូវចោទប្រកាន់ ប្រសិនបើលោកអាចមើលទំព័រ៣៥។ ខ្ញុំគិតថា វាជាទំព័រដំបូងដែលមាននៅក្នុងសំណុំឯកសារលោក។ ខ្ញុំអាចផ្ដល់ ERN 00393521 គ្មាន ERN ជាភាសាខ្មែរ ឬបារាំងទេ។

ជាការពិត គឺយើងឃើញមានសរសេរនៅក្នុងលេខយោងហ្វូតណូត១១៧។ “មន្ទីរសេវាសន្តិសុខនិងឈ្លប ប្រតិបត្តិការនៅក្នុងសង្គម ដែលប្រជាជនជារួមត្រូវបានបែងចែកជាបីក្រុម គឺពេញសិទ្ធ ត្រៀម និងបញ្ញើ។ ប្រព័ន្ធនេះរួមបញ្ចូលនិយមន័យអំពីសិទ្ធិរបស់ពួកគេជាសមាជិកសហករណ៍។ ដោយប្រើប្រាស់ពាក្យសម្រាប់កំណត់ស្លាកប្រជាជន ពាក់ព័ន្ធទៅនឹងភាពមិនស្មោះត្រង់របស់ពួកគេលើបដិវត្តន៍។ អ្នកដែលត្រូវបានគេដាក់ឲ្យស្ថិតនៅក្នុងប្រភេទខាងក្រោមគេបំផុត រងនូវការរើសអើងពាក់ព័ន្ធទៅនឹងសិទ្ធិនយោបាយ រួមទាំងសិទ្ធិសេដ្ឋកិច្ច។ ក៏ប៉ុន្តែពួកគេក៏រងនូវការកាប់សម្លាប់តាមទំនើងចិត្តផងដែរ។

[១១:២២:០៥]

ដូច្នេះនៅក្នុងដំណាក់កាលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យនិយាយជារួមទៅ ក្រុមពេញសិទ្ធិទទួលបាននូវរបបម្ហូបពេញលេញតាមទ្រឹស្ដី ឬក៏បានច្រើនជាងនេះ ហើយមានសិទ្ធិចូលរួមជាមួយអង្គការនយោបាយ រួមទាំងបក្ស និងកងទ័ព និងអាចកាន់តួនាទីនយោបាយណាមួយបាន។ ក្រុមត្រៀម គឺជាក្រុមទី២ គាត់ស្ថិតនៅក្នុងបញ្ជីបែងចែករបបម្ហូបដែរ។ ហើយគាត់មានសិទ្ធិកាន់កាប់តួនាទីនយោបាយថ្នាក់ក្រោមៗ។ បញ្ញើគឺក្រុមនៅក្នុងក្រុមថ្នាក់ក្រោម ដែលស្ថិតនៅក្នុងក្រុមដែលត្រូវយកទៅសម្លាប់ចោល ហើយគ្មានសិទ្ធិនយោបាយនោះទេ”។

លោកបានយោងទៅសៀវភៅរបស់លោក ស្ទីវ ហេដឌ័រ កម្ពុជា ការកាន់កាប់ និងការបះបោរ។ លេខ២ ឆ្នាំ១៩៨០ ហើយចំណុចឯកសារយោងមួយទៀត គឺជាឯកសារធ្វើអត្ថាធិប្បាយ។ “នៅក្នុងឆមាសទី២ ឆ្នាំ៧៨ ការបែងចែកជាបីក្រុមនេះ ត្រូវបានលុបបំបាត់ចោលជាផ្លូវការ។ ក៏ប៉ុន្តែវាបានធ្លាក់ចូលទៅដល់អ្វីដែល ប៉ុល ពត ហៅថា ជាការបែងចែករវាងអ្នកដែលល្អ អ្នកកណ្ដាល និងធាតុដែលមិន

ល្អ នៅក្នុងចំណោមប្រជាជន និងនៅក្នុងបក្ស"។

ហើយចំណុចយោងនេះ គឺយោងទៅលើ "ប៉ុល ពត ឲ្យយើងបន្តប្រកាន់ជំហរខាងលើ និងស្ពាក ជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជាដ៏ជោគជ័យ ដើម្បីធ្វើការការពារកម្ពុជាប្រជាធិបតេយ្យបន្តបដិវត្តន៍ សង្គមនិយម និងកសាងសង្គមនិយម"។

[១១:២៤:០១]

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ៧៨ លោកបានបន្តលើកឡើងទៀតថា "ក្រៅផ្លូវការ ទាំងនៅក្នុងក្របខ័ណ្ឌ បក្ស និងនៅក្នុងក្របខ័ណ្ឌមហាជន ការបែងចែកជាបីក្រុមនេះ ទំនងជាបានបន្ថយមកត្រឹមតែបែងចែក ត្រឹមតែថាជាយុទ្ធជន និងប្រជាជនថ្មី ដែលសំដៅទៅលើប្រជាជនផ្អែកទៅតាម ថាតើពួកគេបានចូលជា មួយបដិវត្តន៍មុនពេល ឬក៏ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥។ ចាប់ពីដើមរហូតមក ទោះបីជាថ្នាក់ដឹកនាំ បានធ្វើការបែងចែកយ៉ាងច្បាស់ រវាងបញ្ញើ ឬក៏អ្នកថ្មី ហើយជាអ្នកដែលមានសមាសភាពមិនល្អផ្នែក នយោបាយក៏ដោយ សន្តិសុខមូលដ្ឋានត្រូវបានឲ្យគេយល់ថា ត្រូវបានផ្តល់ការយល់ឃើញថា អ្នកដែល ជាប្រជាជនថ្មីគឺជាអ្នកដែលមិនមានសមាសភាពល្អ"។

ហើយលោកក៏បានយោងឯកសាររបស់យើងគឺ E3/216 និង E3/797 ។ ឯកសារ E3/216 គឺ កំណត់ហេតុគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ២៤ ដល់ ២៤ ខែសីហា ឆ្នាំ៧៥។ ហើយពាក់ព័ន្ធទៅ នឹងការពន្យល់លើឯកសារនេះ លោកបានលើកឡើងថា៖ "យោងតាមអ្នកតំណាងម្នាក់ដែលមិនមាន ឈ្មោះនៅក្នុងគណៈអចិន្ត្រៃយ៍បានប្រាប់ភូមិភាគថារាល់គ្រប់សមាសភាពដែលគួរឲ្យភ័យខ្លាច គឺវាស្ថិត នៅក្នុងចំណោមប្រជាជនថ្មី"។

ឯកសារ E3/797 គឺជាកំណត់ហេតុនៃកិច្ចប្រជុំលេខា និងអនុលេខា នៅកងពលវរសេនាធំ ឯករាជ្យ ចុះថ្ងៃទី -- ចុះខែសីហា -- ខែមេសា ឆ្នាំ១៩៧៦។ សំណួររបស់ខ្ញុំ គឺចង់សួរថា មានក្រុមចំនួន ពីរនៅក្នុងនោះ ដូចដែលលោកបានលើកឡើង ក្រុមប្រជាជនថ្មី និងក្រុមមួយទៀតនោះ លោកហៅក្រុម អីដែរ?

[១១:២៦:៣៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមលើកឡើងក្នុងប្រតិចារឹកថាចំណុចដែលបានលើកឡើងនេះគឺមិនសមស្រប។ អ្វីដែលគាត់ធ្វើគឺអានចេញពីសៀវភៅ "បេក្ខជនប្រាំពីរនាក់ត្រូវចោទប្រកាន់ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម"។ ហើយបន្ទាប់មក គឺសហព្រះរាជអាជ្ញា គឺគាត់បានលើកឡើងចំណុចយោង ហើយនិងយោងទៅលើថៅក្រុមស៊ើបអង្កេត។ គាត់យោងទៅលើហ្វូតណូត ហើយបន្ទាប់មកគាត់សួរសំណួរអំពីប្រភេទក្រុមចំនួនពីរនោះ។ ចំណុចហ្នឹង គឺវាគ្មានអ្វីពាក់ព័ន្ធទៅនឹងការស្វែងរកការពិតនោះទេ។ ដូច្នេះហើយ គឺថាសូមឲ្យសហព្រះរាជអាជ្ញា គួរតែធ្វើការចាត់ចែង និងលើកឡើងបញ្ហានេះសាជាថ្មី។

[១១:២៧:២៨]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ។ តាមកិច្ចសម្ភាសន៍ដែលលោកធ្វើឡើងជាមួយអ្នកដែលនៅក្នុងពេលនោះ ការបែងចែក ចំពោះការបែងចែករវាងប្រជាជនថ្មី និងប្រជាជនចាស់នោះ តើចំណុចការបែងចែកប្រជាជនចាស់ ប្រជាជនថ្មី គឺជាប្រធានបទដែលបានលើកឡើងក្នុងពេលដែលលោកសម្ភាសនោះដែរឬទេ?

**លោក ស្ទីវ ហេឌ័រ៖**

**ឆ៖** ជាការពិត គឺបានលើកឡើង តែវាមិនមែនពាក់ព័ន្ធតែអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ និងក្រោយមកទៀតនោះទេ។ វាជា -- វាកើតឡើងមុនពេលនោះទៀត គឺក្នុងអំឡុងទសវត្សរ៍៧០ ដូចដែលហ្វូតណូតបានព្យាយាមពន្យល់រួចមកហើយ នៅគេមានការបែងចែកក្រៅផ្លូវការនៅក្នុងចំណោមប្រជាជនមុនឆ្នាំ៧៥ ប្រជាជនដែលទើបតែគេរំដោះថ្មីៗនោះ ឬក៏អ្នកដែលទើបតែមកដល់ថ្មីៗ មកដល់ភូមិភាគរំដោះនោះ អ្នកទាំងអស់នោះ ត្រូវបានគេចាត់ទុកថា ជាប្រជាជនថ្មីដដែល។ គឺវាខុសពីអ្នកដែលនៅក្នុងតំបន់រំដោះនោះតាំងពីមុនពួកគេ។ ការអនុវត្តនេះគឺជាការអនុវត្តក្រៅផ្លូវការតាំងពីពេលមុនដែលគេព្យាយាមបែងចែករវាងអ្នកដែលបានឆ្លាប់ឆ្លងកាត់បដិវត្តន៍ និងអ្នកដែលទើបតែមកដល់ ទៅតាមលទ្ធផលមធ្យោបាយដែលគាត់អាចធ្វើទៅបាន។ ហើយបក្ស គឺគេបានលើកឡើងអំពីបញ្ហានេះមុនឆ្នាំ៧៥ ហើយវាបានបន្តអនុវត្តក្រោយមកទៀត។

[១១:២៩:២០]

**ស៖** លោកអាចបញ្ជាក់បានដែរឬទេអ្វីដែលលោកនិយាយនេះ គឺផ្អែកទៅលើកិច្ចសម្ភាសន៍មិន

មែនផ្អែកទៅលើការដែលលោកផ្តល់មតិយោបល់ទេ តើអ៊ីចឹងដែរឬទេ ដើម្បីកុំឲ្យមានការជំទាស់?

**ឆ៖** ខ្ញុំរៀបរាប់ថា វាចេញពីសេចក្តីសង្ខេបតាមអ្វីដែលខ្ញុំបានសិក្សាពីកិច្ចសម្ភាសន៍ និងឯកសារនានា ដែលខ្ញុំបានពិនិត្យមើល។

**ស៖** សំណុំឯកសារទី៤ ត្រឡប់ទៅ*ថេប*១ ឡើងវិញ។ ឯកសារ--

**ប្រធានអង្គជំនុំ៖**

ផ្អាក១បន្តិចសិនលោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោកមេធាវី វែកគែន!

[១១:៣០:០០]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាចម្លើយចុងក្រោយអម្បាញ់មិញនេះរបស់លោកសាក្សីធ្វើបង្ហាញថា ហើយយើងហាក់ដូចជាដូចនឹងការពិពណ៌នារបស់សហភាគាខ្ញុំអម្បាញ់មិញអ៊ីចឹង។ ឧទាហរណ៍ គឺថាសវនាការនេះដូចជាសវនាការដែលយើងធ្លាប់ជំទាស់ជាច្រើនណាស់មកហើយ គឺសវនាការលើឯកសារគន្លឹះ។ លោក ហេដឌ័រ បានធ្វើដំណើររាប់រយ រាប់ពាន់គីឡូម៉ែត្រដើម្បីមកដល់កន្លែងនេះ សហព្រះរាជអាជ្ញាហើយបែរជាអានវគ្គដែលខ្លួនចង់បាន ដើម្បីបង្ហាញគំនិតរបស់ខ្លួនចេញពីសៀវភៅរបស់លោកសាក្សី។ ហើយដូចការអះអាងទាំងអស់នូវអ្វីដែលគេបានលើកឡើងតាមរយៈសំណួរជាទូទៅ សួរថាតើវាត្រឹមត្រូវដែរឬទេ? អ៊ីចឹងមែនទេ? អ៊ីចឹងការសម្ភាសហ្នឹង សួរហ្នឹងមិនមានភាពច្បាស់លាស់ទេ យើងមិនដឹងថានៅពេលណា? យើងមិនដឹងថាសម្ភាសនៅកន្លែងណា?

[១១:៣១:១២]

អ៊ីចឹងនៅពេលដែលយើងខាងការពារក្តីនេះមកសួរលោក ហេដឌ័រ វិញ ហើយយើងធ្វើយ៉ាងម៉េចយើងនឹងសួរដូចរបៀបឆោតល្ងង់ របៀបទៅលោក ស្ទីវ ហេដឌ័រ ដូចគ្នានឹងសហព្រះរាជអាជ្ញាហ្នឹង ឬយ៉ាងម៉េច? សួរថា ជាទូទៅគាត់ធ្លាប់បានឮការនិយាយផ្ទុយពីហ្នឹងទេ? ឥឡូវនេះគឺថាយើងកំពុងតែធ្វើការនៅឈរលើមូលដ្ឋានមិនច្បាស់លាស់មួយ។ អ៊ីចឹងការធ្វើដូចនេះនេះ ដូចគ្មានន័យអីទាស់តែសោះ ហើយខ្ញុំសូមគាំទ្រទាំងស្រុងលោកមេធាវី កូប៉េ ដែលគាត់បានលើកឡើងអម្បាញ់មិញនេះ។

**លោក ឃីត រេយ៍ន័រ៖**

មេធាវីចង់ឲ្យខ្ញុំពន្យល់អំពីការសួរដេញដោលហើយមើលទៅ។ គាត់យល់អំពីការសួរតទល់ គាត់

ចង់សួរដេញដោលនោះ នៅពេលដែលគាត់មានយុទ្ធសាស្ត្រអ្វី ខ្ញុំមិនដឹងទេ។ ប៉ុន្តែគាត់ត្រូវតែសួរដេញដោល បើគាត់គិតថាវាមានអ្វីជាបង្អែកនៅលើឯកសារដូចដែលខ្ញុំបានយោងនេះ សៀវភៅដែលនិពន្ធដោយលោក ហេងឌ័រ។ ខ្ញុំមិនគិតថាមានជំទាស់បែបនេះ ថាមិនឱ្យលោក ហេងឌ័រ មកផ្តល់ភស្តុតាងទេ ប៉ុន្តែវាមិនអ្វីទាក់ទងទៅនឹងសវនាការលើឯកសារនេះទេ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតតុលាការសម្រេចឱ្យខ្ញុំបន្ត។

[១១:៣២:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរបន្តទៀតចុះ។ សេចក្តីជំទាស់ហ្នឹងគឺមានលក្ខណៈដដែលៗទេ។ ដូច្នេះមិនមានប្រសិទ្ធភាពទេ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ឯកសារ៤ *ថេប*១ ឯកសារ E190.1.389 ទំព័រ១០ ជើងទំព័រ ៤៤។ បាទ កាលវាយតម្លៃឡើងវិញ គឺមេដឹកនាំជាន់ខ្ពស់ យោងទៅរកប្រជាជនថ្មីនោះ ជើងទំព័រលេខ៤៤ នៅត្រង់ទំព័រ១០។ “ដោយហេតុគាត់រស់នៅក្នុងជីវិតងាយស្រួលពីមុននោះ គាត់មិនពឹងផ្អែកលើនយោបាយដូចជាមនុស្សមូលដ្ឋាននោះទេ ហើយគឺអាចងាយពាក់ព័ន្ធទៅនឹងក្នុងសកម្មភាពជនក្បត់ដែលអតីត ពាក្យខ្មែរដែលប្រើថា ខ្មែរ ហៅថាភ្នាក់ងារប៉ូលិសសម្ងាត់នោះ ដែលៗព្យាយាមផ្តួលបដិវត្តន៍ក្នុងនាម សេ.អ៊ី.អា ហើយនិងភ្នាក់ងារស៊ើបការណ៍បរទេស”។ ឯកសារដែលយោងនោះ គឺឯកសារបី -- លេខ៤៣ ទាក់ទងទៅនឹងគឺឯកសារ E3/781។ ទាក់ទងទៅនឹងពាក្យដែលគេប្រើថា “យកមកពីពាក្យវៀតណាម” តើលោកត្រូវសិក្សាដើម្បីរក ឬក៏លោកដឹងពាក្យហ្នឹងដែលគេប្រើប្រៀបធៀបនេះ?

[១១:៣៥:០០]

**លោក ស្មីរ ហេងឌ័រ៖**

**ឆ៖** នេះជាពាក្យដែលមើលទៅជាភាសាខ្មែរ ដូចជាពាក្យមានសិល្បៈមួយ ហើយខ្ញុំត្រូវមើលវចនានុក្រមដើម្បីកំណត់ ថាតើវាមានអត្ថន័យ គឺថាប្រើពាក្យយកមកពីវៀតណាមដែលថាវាមានធាតុផ្សំពីរដែលមានខ្លឹមសារដើម ហើយមានន័យជាសាមញ្ញដែលគេប្រែ។

**ស៖** ហ្វូតណូតបន្ទាប់ គឺ៤៥ គឺE190.1389 គឺការវាយតម្លៃមេដឹកនាំជាន់ខ្ពស់ឡើងវិញ។ “ដោយហេតុការណ៍ប្តូរនោះទើបតែចាប់ផ្តើម គេស្ថិតនៅដឹកនាំនៅចក្រពត្តិនិយម សក្តិភូមិនិយម គោល

ជំហរចាស់ មនោគមន៍វិជ្ជាចាស់ លោកទស្សនៈ ហើយនិងសេចក្ដីលោភលន់។ ពួកគេព្យាយាមផ្សព្វផ្សាយអំពីកាកសំណល់ចាស់របស់គេ ហើយនិងឥទ្ធិពលអាក្រក់នៅក្នុងចំណោមពួកប្រជាជនចាស់ ហើយនិងអ្នកដែលមានជាបដិវត្តន៍”។

គឺឯកសារ E379 *(ស៊ីក)* គឺថា យុវជនរបស់យើងគឺពង្រឹង ហើយនិងវណ្ណៈតស៊ូ និងវណ្ណៈដាច់ខាតនៅក្នុងទង់បដិវត្តគឺឯកសារទី១០ គឺឆ្នាំ១៩៧៥។ និយាយពីកាកសំណល់ ជាពាក្យពិបាកនៅក្នុងភាសាអង់គ្លេស តើពាក្យថា *“រេមនិន គ្រេដ”* ជាកាកសំណល់នេះគឺហៅជាខ្មែរហ្នឹងជាអ្វី? តើលោកយល់ដូចម្ដេចកាលនោះនៅពេលនេះ?

[១១:៣៦:៥១]

**ផ៖** ខ្ញុំយល់ថា ខ្ញុំនៅថាចេះភាសាវិលនោះ គឺថាមិនច្បាស់ទេ គេហៅថា “កម្អែលចាស់” ដែលខ្ញុំយល់ គឺយោងទៅរកស្បែកដែលមានក្អែលនៅជាប់នៅហ្នឹងស្បែកយើង យើងត្រូវដុសបើសិនជាយើងចង់កុំឲ្យវាប្រលាក់នោះ។ នេះជាពាក្យប្រើតាមអត្ថន័យត្រង់ ដែលថាគេប្រើដើម្បីយោងទៅរកកាកសំណល់ចាស់ ដែលគេត្រូវដោយគេប្រើវិធីមួយចំនួនដើម្បីដុសឲ្យស្អាតចេញនោះ។

**ស៖** ខ្ញុំចង់ឲ្យលោកពិនិត្យនៅលើឯកសារ *ហ្វូតណូត*គឺជើងទំព័រយោងដដែល បាទឯកសារដដែល គឺថា បាទគឺថា E ឯកសារដដែល គឺថាការវាយតម្លៃមេដឹកនាំនោះគឺថា ទំព័រលេខ១៨។ អង់គ្លេស ERN 0066 *(ស៊ីក) ហ្វូតណូត*៨២ នៅលើទំព័រ១៦។ “ដើម្បីសម្លាប់ខ្មាំដែលមានបណ្ដាស័ក្តិ យើងត្រូវតែនិយាយឲ្យត្រង់គឺភូមិភាគបក្សកុម្មុយនីស្តកម្ពុជាតំបន់ ស្រុក ឃុំ ហើយនិងគណបក្សនៅតាមភូមិបន្តអនុវត្តភារកិច្ចនៅក្នុងអង្គភាពយោធា នៅក្នុងនិងជុំវិញភ្នំពេញ និងក្រុងផ្សេងទៀតដោយស្វែងរកហើយសម្លាប់ដោយសម្ងាត់នូវពួកអ្នកមានបណ្ដាសក្តិពីមុន។ ភារកិច្ចនេះគឺត្រូវបន្តអនុវត្តនៅគ្រប់ទីកន្លែងភាគច្រើនដោយគ្មានក្ដីមេត្តា ហើយសេចក្ដីយោងដែលគាំទ្រនោះគឺនៅត្រង់ ជាឧទាហរណ៍ភស្តុតាងនោះគឺភូមិភាគឧត្តរ។ នៅក្នុងគណៈភូមិភាគឧត្តរត្រូវទទួលអ្នកប្រជាជនជម្លៀស ហើយកំណត់អត្តសញ្ញាណ”។ ចុះថ្ងៃ២៦ -- បាទហើយបញ្ជាក់ថ្ងៃទី២៦ មេសា ហ្នឹងគឺបោះពុម្ពដោយតំបន់លេខ៤៣។ សូមលោកបញ្ជាក់បន្ថែមពីបញ្ហានេះ។

[១១:៣៩:៤១]

**ផ៖** បើខ្ញុំចាំបានត្រឹមត្រូវបន្ទាប់ពីខ្ញុំចាកចេញពីកម្ពុជាក្នុងខែមេសា ឆ្នាំ១៩៧៥ ទៅព្រំដែនថៃនោះខ្ញុំបាននិយាយជាមួយមនុស្សមួយចំនួន ដែលទើបតែចាកចេញពីកម្ពុជាដែលរាប់ទាំងអ្នកដែលត្រូវ

បានគេជម្លៀសចេញពីភ្នំពេញ ហើយបានរត់ទៅដល់ព្រំដែនថៃ។ អ្នកនោះបានប្រាប់នូវច្បាប់ដើមនូវឯកសារនោះដែលខ្ញុំថតចម្លង។

**ស៖** សូមអរគុណ។ ខ្ញុំនិយាយអំពីឯកសារយោង គឺថាឯកសារ E190.1.398 គឺមាន*ហ្វូតណូត*ពីរ គឺថានៅទំព័រលេខ១១ គឺនៅ៥៧ ហើយនិង៥៨ ហើយខ្ញុំអានរួមគ្នា ដោយសារប្រភពហ្នឹងជាមនុស្សតែមួយ។ "និយាយអំពីការកាប់សម្លាប់ ដើម្បីបង្ហាញពីគោលជំហរនេះ អំពីការកាប់សម្លាប់ថាជាការចាំបាច់នោះ ការវាយប្រហារសង្គមចាស់"។

បាទ នេះជាលេខយោងទំព័រ៥៧ ទៅនឹងបទសម្ភាសន៍ កែ ពក ហើយហ្វូតណូត៥៨ នៅក្នុងអត្ថបទនេះដោយមិនមាននិយមន័យទេគឺថា ប៉ុល ពត ក៏ត្រូវបានប្រាប់កម្មាភិបាលយោធា និងស៊ីវិលដែលចូលរួមប្រជុំនោះថា "គេត្រូវតែការតស៊ូប្រឆាំងនឹងចារកម្ម កា.ហ្សេ.បេ, សេ.អ៊ី.អា នៅក្នុងជួរទាហានផងដែរ" ហើយយោងទៅរកជើងទំព័រ៥៨នោះ គឺE2/2782 គឺជាប្រវត្តិផ្ទាល់របស់ កែ ពក។ និយាយអំពីបទសម្ភាសន៍ជាមួយ កែ ពក ដែលលោកបានសម្ភាសនោះ ប៉ុន្តែតាមអ្វីដែលលោកបានដឹងផ្ទាល់ តើលោកដឹងអំពីប្រវត្តិផ្ទាល់របស់ ប៉ុល ពត ដែរឬទេ? តើលោកបានឃើញជីវប្រវត្តិហ្នឹងដែរឬទេ?

[១១:៤២:១៧]

**ឆ៖** ខ្ញុំគិតថានេះ គឺជាឯកសារមួយទៀតដែលបានដាក់បញ្ចូលដោយ ខឹម ងន់ នៅពេលដែលខ្ញុំនិយាយពីគាត់កាលពីមុននោះឯង។ គាត់គឺជាអ្នកអាចឲ្យ កែ ពក សរសេរឲ្យគាត់ ឬក៏គាត់កត់ត្រាដោយផ្អែកលើបទសម្ភាសន៍ដែលគាត់បានសម្ភាស កែ ពក។ អត្ថបទនេះ កាលនោះនោះ គឺគេបានជូនទៅមនុស្សមួយចំនួនដោយរាប់បញ្ចូល បើខ្ញុំមិនច្រឡំទេគឺឲ្យទៅមនុស្សមួយចំនួន -- បុគ្គលម្នាក់ហើយគាត់បានបញ្ជូនមកឲ្យខ្ញុំនោះ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងនិយាយអំពីការវាយតម្លៃគឺនៅក្នុងឯកសារ E190.1.398 គឺទំព័រ២០ គឺជើងទំព័រ១០៣ និង១០៤។ និយាយអំពីជើងទំព័រលេខ ១០៣ ជាមុនសិន "អនុលោមតាមវិធីដើម ប្រធានសហករណ៍បានសម្រេចថា តើអ្នកនោះត្រូវរៀនសូត្រឡើងវិញនៅក្នុងមូលដ្ឋាន ឬក៏ត្រូវរាយការណ៍ទៅគណបក្សស្រុកនោះក៏ដោយ ដែលទទួលបន្ទុកសន្តិសុខដើម្បីស៊ើបអង្កេតក៏ដោយ ដោយមូលដ្ឋានទៅលើការស៊ើបអង្កេតនេះ ស្រុកគឺត្រូវតែស្វែងរកសេចក្តីសម្រេចពីតំបន់ អំពីថាតើត្រូវសម្លាប់ជននោះ ឬក៏ត្រូវដាក់ក្នុងគុក ឬក៏ត្រូវដោះលែង។ គឺថាឯកសារស្ពានទូត គឺថាប្រព័ន្ធពន្ធនាគារកម្ពុជា តើ

លោកអាចបញ្ជាក់ពីប្រភព តើលោកបានទទួលដោយរបៀបណាដែរឬទេ?

[១១:៤៤:៣៧]

**ឆ៖** ចំណុចឯកសារមួយនេះ គឺមកដល់ដៃខ្ញុំពីមនុស្សម្នាក់ដែលស្ថិតនៅក្នុងស្ថានទូតសហរដ្ឋអាមេរិកនៅក្នុងទីក្រុងបាងកក នៅពេលដែលឯកសារនោះត្រូវបានព្រាងឡើង។ ប្រហែលជានៅក្នុងក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលបានទទួលនៅទីក្រុងវ៉ាស៊ីនតោន ហើយមានលទ្ធភាពមួយពីរនៅទីនេះ អាច ឆាល ថ្វាយនឹង ឬក៏អាច ធីម ខានី ឬក៏អាច អេនដឺសិន។ ខ្ញុំមិនច្បាស់ មិនចាំច្បាស់អ្នកណាម្នាក់ក្នុងបីនេះ អាចហ្នឹង គឺថាអាចអ្នកណាម្នាក់ក្នុងបីនេះ គឺជា -- គេហៅថាជា "*អែរក្រាម*" – ជាសារតាមអាកាស តាមនោះឯង។

**ស៖** និយាយអំពីសំណួរ អំពីរបៀប ហើយនិងការអនុវត្ត ហើយជាផ្លូវការថ្នាក់តំបន់ចាំបាច់ត្រូវមានការឯកភាពពីគណៈអចិន្ត្រៃយ៍ភូមិភាគមុននឹងសម្លាប់។ នៅឯកសារ E3/12 ដែលថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈិម។ នេះស្របទៅតាមសេចក្ដីសម្រេចថ្ងៃទី៣០ ខែ៣ ៧៦ សិទ្ធិក្នុងការកម្ទេចនៅក្នុង និងខាងក្រៅជួរ ត្រូវតែធ្វើឡើងនៅក្នុងមូលដ្ឋានតាមគណៈអចិន្ត្រៃយ៍របស់ភូមិភាគ។

[១១:៤៦:២៥]

សំណួររបស់ខ្ញុំដូចខាងក្រោមនេះ ខ្ញុំប្រើពាក្យដូចសំណួរខាងដើមខ្ញុំសួរលោកអ៊ីចឹង គឺនិយាយអំពីរបៀបដែលថ្នាក់ស្រុកសុំយោបល់ពីតំបន់ តំបន់ត្រូវមានការឯកភាពអំពីគណៈអចិន្ត្រៃយ៍ភូមិភាគដើម្បីបន្តការកាប់សម្លាប់។ ពីបទសម្ភាសន៍របស់លោក ហើយនិងការទាក់ទងផ្ទាល់ជាមួយអ្នកផ្ដល់សម្ភាសនោះ តើលោកបានប្រមូលព័ត៌មានអ្វីខ្លះថា របៀបនេះ ពិតជាបានគេធ្វើបែបនោះមែនឬទេ?

**ឆ៖** ជាថ្មីម្ដងទៀត ខ្ញុំនិយាយដោយសង្ខេប។ ចំណាប់អារម្មណ៍ទូទៅរបស់ខ្ញុំគឺជាការអនុវត្ត ជាទូទៅមិនបានគោរពទៅតាមរបៀបជាផ្លូវការ បែបបទជាផ្លូវការនោះទេ។ មានករណីកម្រណាស់ដែលថាសេចក្ដីសម្រេចដែលធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ភូមិភាគ ដែលជាទូទៅសេចក្ដីសម្រេចត្រូវតែបានធ្វើនៅខាងថ្នាក់ក្រោម ជួនកាលនៅថ្នាក់ស្រុក ជួនកាលក្រោមថ្នាក់ស្រុកទៀត ដែលគេធ្វើសេចក្ដីសម្រេចរឿងនេះ។ ដូច្នេះគឺយើងមានចំណុចខុសគ្នារវាងនយោបាយជាផ្លូវការ ហើយនិងការអនុវត្តជាក់ស្ដែងនៅតាមមូលដ្ឋាននោះ។

[១១:៤៨:០៧]

**ស៖** ខ្ញុំនឹងសួរសំណួរអំពីព័ត៌មានដែលលោកទទួលបាននោះ គឺលេខជើងទំព័រ១០៥ បាទ នៅ

ក្នុងឯកសារ E190.1.398។ "សក្ខីកម្មរបស់ប្រជាជនថ្មីបញ្ជាក់ថា ប្រធានភូមិ និងអ្នកក្រោមបង្គាប់របស់ខ្លួនផ្ទាល់ គឺអ្នកទទួលខុសត្រូវក្នុងការប្រមូលព័ត៌មានដើម្បីកំណត់អ្នកណាម្នាក់ថាជាខ្មាំង និងមានទំនាក់ទំនងក្បត់ ថាជាអ្នកប្រឆាំងប្រាកដ ឬជាមនុស្សអាចក្លាយជាអ្នកប្រឆាំង។ ហើយបន្ទាប់មកក៏បញ្ជូនទៅថ្នាក់លើបន្ទាប់ទៀត"។ ទាក់ទងទៅនឹងការបញ្ជូនព័ត៌មានទៅថ្នាក់លើនេះ តាមការសម្ភាសហើយនិងការទាក់ទងផ្ទាល់ជាមួយអ្នកផ្តល់សម្ភាស តើលោកបានប្រមូលព័ត៌មានថា ការនេះវាកើតពិតអ៊ីចឹងដែរឬទេ?

**ផ៖** ចម្លើយហ្នឹង គឺថាបាទ និងទេ។ ក្នុងករណីខ្លះគឺជាបែបបទដែលគេបានអនុវត្តតាម ប៉ុន្តែក្នុងករណីខ្លះ គេមិនបានអនុវត្តទៅតាមបែបបទជាផ្លូវការនេះទេ។

[១១:៤៩:២៧]

**ស៖** ទាក់ទងទៅនឹងការរាយការណ៍ សូមលោកទុកមួយផ្នែក។ ឥឡូវយើងត្រឡប់ទៅ*ហ្វាល* លេខ២ ហើយ*ថេប*២ដែរ បាទ *ថេប*៣។ ឯកសារ E3/190 ហើយការពិភាក្សារបស់លោក គឺថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ តើលោកបញ្ជាក់ថា ឯកសារហ្នឹងលោកបានមានហើយឬនៅ?

**ផ៖** បាទ។

**ស៖** មានប្រយោគមួយនៅខាងលើទំព័រ ខ្ញុំសួរគាត់ថា តើលោកមាន -- បាទ ឥឡូវយើងឃើញ -- "ខ្ញុំបានសួរគាត់ ថាតើគាត់បានទទួលរបាយការណ៍ពីភូមិភាគ ឬតំបន់ដែលបានសរសេរអំពីការសម្លាប់ ឬការធ្វើទុក្ខបុកម្នេញទៅលើអ្នកទោស"។ ប្រយោគបន្ទាប់ "គាត់ អៀង សារី ព្រមទទួលថា គាត់បានទទួលរបាយការណ៍នោះ ហើយបានដឹងអំពីការប្រើក្រសួងសម្រាប់ដាក់ទាំងនោះមែន។ ហើយគាត់បានឃើញរបាយការណ៍មួយចំនួនតូចប៉ុណ្ណោះ"។ តើនេះជាការកំណត់ត្រាត្រឹមត្រូវអំពីអ្វីដែលគាត់ប្រាប់លោកក្នុងពេលដែលលោកពិភាក្សាជាមួយគាត់ដែរឬទេ?

[១១:៥១:២៧]

**ផ៖** បាទ។

**ស៖** ឥឡូវនេះ ឯកសារ *ហ្វាល៤ ថេប* ១ ហើយសូមលោកបើក គឺឯកសារ E190.1.398។ វាយតម្លៃឡើងវិញ គឺថាទំព័រ២៣ លោក ហេដឌ័រ បាទ លេខជើងទំព័រ១២៥ "នយោបាយបក្សកុម្មុយ-នីស្តកម្ពុជា គឺសមាជិកជាយក្រុង បាទទាក់ទងនឹងគណៈសង្ឃ សហគមន៍នេះដែលរស់នៅតាមទីប្រជុំជននៅទូទាំងប្រទេស បានផ្តុះបញ្ចាំងគណៈសង្ឃទាំងអស់នៅតាមប្រជុំ គណៈសង្ឃនោះត្រូវបានរំសាយ

ហើយព្រះសង្ឃទាំងអស់ត្រូវបានបណ្តេញចេញពីវត្តអារាមនានាក្នុងទីក្រុងភ្នំពេញ និងទីប្រជុំជនឲ្យទៅកាន់ទីជនបទ ធ្វើយ៉ាងណាទប់ស្កាត់សកម្មភាពប្រមូលផ្តុំ ដើម្បីប្រឆាំងនឹងរបបថ្មី។ ដោយមានជំនឿថា ព្រះសង្ឃស្ថិតនៅក្នុងប្រភេទវណ្ណៈមួយក្នុងចំណោមប្រភេទវណ្ណៈ ដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជាគណៈសង្ឃមានតួនាទីខ្ពស់បំផុត ជាគោលដៅនៃសម្លាប់ភ្លាមៗ ដោយចាត់ទុកគណៈសង្ឃមានឋានៈទាំងនោះស្មើនឹងពួកមានបណ្តាស័ក្តិ”។

[១១:៥៣:១០]

ហើយប្រភពរបស់លោកហ្នឹង តាមជើងទំព័រដែលប្រាប់ហ្នឹង ដែលថា កម្មាភិបាល -- បាទ សៀវភៅកំណត់ត្រាពីកម្ពុជាប្រជាធិបតេយ្យ គឺរបស់កម្មាភិបាលបញ្ជាក់ថា អ្នកដែលមាន -- គណៈដឹកនាំជាន់ខ្ពស់នៃគណៈសង្ឃភាគច្រើន គឺស្ថិតនៅក្រោមឥទ្ធិពលនយោបាយនៃវណ្ណៈខ្ពស់ជាងគេ។ តើលោកអាចបញ្ជាក់ថា គឺផ្អែកលើឯកសារនោះ ហើយនិងអ្នកសម្ភាសដែលលោកបានប្រើជាបង្អែកនៃសៀវភៅរបស់លោកបាទ?

**ឆ៖** មានចំណុចមួយនៅត្រង់នេះ គឺថាដែលខ្ញុំមិនៗច្បាស់ដែលថា អ្វីៗដែលនៅក្នុងប្រយោគនេះមាននៅក្នុងកំណត់ -- សៀវភៅកំណត់ដែរទេ ប៉ុន្តែខ្ញុំត្រូវមើលសៀវភៅនោះ ដើម្បីឲ្យប្រាកដ។

**ស៖** តើមានប្រភពណាផ្សេង សំណួរគឺអំពីព្រះសង្ឃជាន់ខ្ពស់របស់ពុទ្ធសាសនា តើលោកអាចជម្រាបតុលាការ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់យកគណៈសង្ឃដែលមានឋានៈខ្ពស់ៗដើម្បីសម្លាប់ក្នុងពេលភ្លាមៗផ្អែកលើបទសម្ភាសន៍ ហើយនិងការពិភាក្សាជាមួយអ្នកសម្ភាសដែលលោកសម្ភាសនោះ តើលោកបានព័ត៌មានបែបនេះដែរឬទេ?

[១១:៥៤:៤២]

**ឆ៖** ប្រយោគនេះ ជាឧទាហរណ៍មួយនៃសេចក្តីសង្ខេបនូវអ្វីដែលគេបានប្រាប់ខ្ញុំ នៅក្នុងករណីនេះខ្ញុំនឹង -- ដែលធ្វើការសម្ភាសជាច្រើន ដែលពិនិត្យមើលបញ្ហានេះដោយលម្អិតនោះ។

**ស៖** បាទ ហ្វូតណូតមួយទៀតគឺ ១២៦ នៅក្នុងឯកសារ E190.1.398 លោកនិយាយអំពីការធ្វើបាបបំបែកព្រះសង្ឃទាំងនោះចេញពីក្រុមប្រជាជនជម្លៀស ដើម្បីយកទៅកម្ទេចចោល។ ម្យ៉ាងទៀតព្រះសង្ឃដែលមាន ពុំមានបុណ្យសក្តិដែលត្រូវបានជម្លៀសចេញពីទីប្រជុំជន លោកបានដកស្រង់គឺថា ឯកសារ E3/1820 សៀវភៅរបស់ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ “កម្ពុជាឆ្នាំសូន្យ” ហើយនិយាយពី ឆាំង សុង ព្រះពុទ្ធសាសនាក្រោមរបប ប៉ុល ពត។ តើ ឆាំង សុង ជាសៀវភៅការសិក្សាកម្រិតខ្ពស់ ឬក៏ដូចម្តេច?

សូមលោកពន្យល់តុលាការ។

[១១:៥៦:១១]

**ឆ៖** ខ្ញុំគិតថា អាចជារបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំមិនប្រាកដថាធ្លាប់បានបោះពុម្ពផ្សាយបែបនោះទេ ប៉ុន្តែវាអាច យើងអាចរកឃើញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** សូមអរគុណ។ ឯកសារដដែលគឺ *ហ្វាលទី៤ ថេប៤* គឺថាបុគ្គលប្រាំរូបសម្រាប់ធ្វើការចោទប្រកាន់ បុគ្គលប្រាំពីររូបដែលត្រូវចោទប្រកាន់ គឺទំព័រទី៣ នៅក្នុងឯកសារដែលលោកមាននោះ។ អង់គ្លេស 00393523 "ចាប់ពីថ្ងៃរំដោះមក រហូតដល់ចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ ខាងសន្តិសុខដែលមានមន្ត្រីល្អប ហើយនិងមនុស្សគឺធ្វើការចាប់ឃុំខ្លួនសម្លាប់បន្ទាប់ ហើយបន្ទាប់ទៀតអ្នកណាដែរគេចោទប្រឆាំងថាប្រឆាំងនឹងបដិវត្តន៍ ហើយនិងចារកិច្ច ហើយស្ថិតនៅក្នុងប្រជាជនក្រុមមួយចំនួន។ ចាប់ផ្ដើមនៅពាក់កណ្ដាលឆ្នាំ១៩៧៦ សន្តិសុខបានទទួលសញ្ញាពីមេដឹកនាំបក្ស ដែលថាគេត្រូវតែប្រឹងប្រែងឲ្យអស់ពីលទ្ធភាព ដើម្បីកំណត់មន្ត្រីសាធារណរដ្ឋខ្មែរដែលបានរត់ចេញពីការកាប់សម្លាប់។ ពីព្រោះថាសមាសភាពមិនល្អមាននៅក្នុងប្រជាជន គឺនៅមានមិនមែនត្រឹមតែមិនមានចេតនាទេ ប៉ុន្តែគេអាចនឹងសមគំនិតប្រឆាំងនឹងបដិវត្តន៍។ ហេតុដូច្នេះត្រូវតែបំបាត់ចោល។ សន្តិសុខមូលដ្ឋានត្រូវតែឆ្លើយតប ចាប់ខ្លួន សួរចម្លើយ ហើយសម្លាប់ប្រជាជន មនុស្សណាដែលស្ថិតនៅក្នុងក្រុមនេះ។

[១១:៥៨:២១]

បន្ទាប់នេះ គឺថាឯកសារយោងគឺថា E3/798 កំណត់ហេតុរបស់ៗកងពល និងវរសេនាធំឯករាជ្យ គឺនៅថ្ងៃទី១៣ សីហា ឆ្នាំ១៩៧៦។ ការផ្លាស់ប្ដូរនេះ គឺអាចជាការបង្ហាញយ៉ាងច្បាស់ទាក់ទងទៅនឹង សុន សេន បានសង្ខេបអំពីសភាពការណ៍ខ្លាំង អំពីកម្មាភិបាលយោធាដែលថាគាត់ជាសេនាធិការនៅក្នុងឆ្នាំ១៩៧៦ ខែសីហា។ ដូច្នេះកំណត់ហេតុនេះគឺទាក់ទងទៅនឹងបញ្ហាមួយ ទាក់ទងដែលថាជាកិច្ចប្រជុំរបស់យោធា។

**ឆ៖** បាទ ជាការប្រជុំរបស់ -- ជារបស់យោធា គឺជាសេចក្ដីប្រកាសរបស់បក្សដែលថាដែលប្រកាស ដែលទូលាយជាងអង្គភាពយោធាទៅទៀត ប៉ុន្តែវាមានការផ្តុះបញ្ចាំង វាមានលក្ខណៈទូលំទូលាយពីនយោបាយរបស់បក្សនោះ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ការប៉ុនប៉ងចុងក្រោយរបស់ខ្ញុំ លោកប្រធាន ការផ្ទុះបញ្ចាំងអំពីនយោបាយទូលំទូលាយថាតើសាក្សីរូបនេះបានពាក់ព័ន្ធនឹងរចនាសម្ព័ន្ធដែលគាត់អាចនិយាយបានដែរឬទេ? តើចង់ឲ្យបានច្បាស់ ប៉ុន្មានពីសក្ខីកម្មរបស់គាត់ឋានៈជាសាក្សីនោះ បើតាមសំណួរនេះគឺគាត់សុំមតិជាអ្នកជំនាញសុំតុលាការបញ្ឈប់សំណួរបែបនេះ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានជាថ្មីម្តងទៀត ខ្ញុំ -- បើលោកប្រធានប្រាប់គាត់ថាកុំឲ្យសម្តែងមតិក៏ខ្ញុំមិនប្រកាន់ដែរ ក៏ប៉ុន្តែខ្ញុំសួរទាក់ទងទៅនឹងសៀវភៅ ហើយនិងផ្អែកទៅលើលេខយោងទំព័រដែលពន្យល់។ ដូច្នេះខ្ញុំសូមអនុញ្ញាតបន្ត ដូចដែលខ្ញុំជម្រាបសំណួររបស់ខ្ញុំគឺនិយាយអំពីសៀវភៅ និងសេចក្តីពន្យល់ជើងទំព័រ។ អ៊ីចឹងខ្ញុំសូមធានាថា មិនគិតថាលោក កូប៉េ យល់ថា គឺជាការខុសនីតិវិធីនោះទេ។

[១២:០១:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៤:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ប្រគល់ភារៈជូនលោកស្រីចៅក្រមដើម្បីបញ្ជាក់បញ្ហានេះឲ្យបានច្បាស់ ពីព្រោះកើតមានម្តងហើយម្តងទៀត។ ហើយបញ្ហាអាចបញ្ហាវាមានភាពខុសគ្នាដែរ មិនមែនសេចក្តីជំទាស់របស់មេធាវីការពារក្តីវាដូចមុនទេ មានលក្ខណៈខុសប្លែកដែរ។ អ៊ីចឹងសូមបញ្ជាក់ បញ្ហានេះឲ្យច្បាស់លាស់ ដើម្បីឲ្យកិច្ចពិភាក្សាដេញដោលនោះមានប្រយោជន៍សម្រាប់អង្គជំនុំជម្រះយកទៅពិនិត្យវាយតម្លៃជាភស្តុតាងនៅក្នុងការពិចារណាសម្រេចសេចក្តីក្នុងរឿក្តីនេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងមិនសម្រេចថាការជំទាស់មានប្រសិទ្ធ-ភាពទាំងស្រុងនោះទេ គឺជាពិសេសមកពីមេធាវីការពារ នួន ជា គឺនិយាយសំដៅទៅលើតម្លៃជាភស្តុតាងនៃសក្ខីកម្ម ឬក៏ឯកសារដែលកំពុងដាក់ដេញដោលនេះ។ គាត់បានចង្អុលបង្ហាញ -- យើងបានចង្អុលបង្ហាញខាងដើមហើយ អង្គជំនុំជម្រះបានដឹងអំពីកាតព្វកិច្ចក្នុងការថ្លឹងថ្លែងអំពីតម្លៃជាភស្តុតាងនៃវត្ថុតាង

សក្ខីកម្មនេះ។ ការជំទាស់នេះ គឺតម្រង់ទៅរកសក្ខីកម្មរបស់សាក្សីនៅក្នុងឋានៈខ្លួនថា មិនមែនជាសាក្សីជាអ្នកជំនាញ។ ដូច្នេះសហព្រះរាជអាជ្ញាគប្បីតែរំឭកដល់ការណែនាំ ជាពិសេសចាត់ទុកលោក ហេងឪរ ថាជាសាក្សី កុំយល់ថាគាត់ -- កុំសួរបែបជាគាត់ជាអ្នកជំនាញ។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍។ ខ្ញុំមានសំណួរពីរដើម្បីបញ្ចប់ព្រឹកនេះ ហើយខ្ញុំសូមអនុញ្ញាតធ្វើពេលនេះ។

[១២:០៦:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត។ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** នៅក្នុងឯកសារ E3/48 គឺឯកសារ៤ *ថេប៤* គឺទំព័រ១៣៨ ហើយនិង១៣៩ នៅក្នុងសៀវភៅបុគ្គលប្រាំពីររូបដែលត្រូវចោទប្រកាន់។ បាទ ជើងទំព័រ១៣៨ និង១៣៩ "អនុលោមតាម សុន សេន បាតុភូតទាំងអស់នោះ ដែលរារាំងគោលដៅរបស់បក្ស មិនត្រូវចាត់ទុកជាបញ្ហាធម្មតារបស់សង្គមនិយម ឬក៏សង្គមផ្សេងទៀតទេ។ ប៉ុន្តែត្រូវដោះស្រាយដោយលុបបំបាត់ខ្មាំងផ្ទៃក្នុងដែលបង្កប់ខាងក្នុងដើម្បីវាយប្រហារបដិវត្តន៍"។

នៅឯកសារ E3/884 ដែលកំណត់ហេតុអង្គប្រជុំ ហើយនិងគណៈស្រុក ហើយនិងកងពលឯករាជ្យ នៅក្នុងឆ្នាំ១៩៧៦ ហើយនិយាយបន្តទៅទៀត អនុលោមតាមកាលវិភាគរបស់ សុន សេន "ខ្មាំងដែលប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា -- ប្រជាធិបតេយ្យ ដូចជាអ្នកគោះទ្វារពេលយប់ គឺជាផែនការដើម្បីប្រឆាំងនឹងបដិវត្តន៍"។

ហើយយោងឯកសារ E3/789 កំណត់ហេតុអង្គប្រជុំលេខា និងអនុលេខានៃកងពល នៃកងវរសេនាធំឯករាជ្យ នៅថ្ងៃទី៣០ សីហា ១៩៧៦ ហើយនិងថ្ងៃទី១៩ កញ្ញា ឆ្នាំ១៩៧៦ នោះដែរ។ អ៊ីចឹងហើយសូមជាសំណួររបស់ខ្ញុំ ផ្អែកទៅលើបទសម្ភាសន៍របស់លោក ហើយនិងទំនាក់ទំនងជាមួយអ្នកផ្តល់សម្ភាស តើលោកប្រមូលបានព័ត៌មានអំពីការកាប់សម្លាប់ដែលគ្រាន់តែធ្វើខូចខាតរបស់តូចតាច ឬក៏អ្វីហ្នឹងដែរឬទេ?

[១២:០៨:៤១]

**ឆ៖** បាទ។

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណ។ ខ្ញុំបានបញ្ចប់វគ្គនេះហើយ គឺថាអាចនឹងដល់ពេលដែលតុលាការអាចនឹងប្រកាសសម្រាកសម្រាប់ពិសាអាហារថ្ងៃត្រង់ហើយ។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬទីកន្លែងណាមួយសមស្របនៅជិតនឹងសាលសវនាការនេះ សម្រាប់សាក្សីសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១០ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ីវ ហេងឆ័រ។

សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមលោកប្រធាន។

[១៣:៣៤:០៦]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** សូមជម្រាបសួរលោក ហេដឌ័រ ខ្ញុំសូមឲ្យទៅ*ហ្វាល*លេខ៣ បាទត្រង់*ថេបវ័ន – ថេប*១ បាទ។ ខ្ញុំគិតថា លោកមានឯកសារ E3/3169 បាទ ការបោះពុម្ពផ្សាយឆ្នាំ១៩៩១ ប៉ុល ពត, ខៀវ សំផន។ តើលោកបានឯកសារហ្នឹងហើយឬនៅ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំឃើញមួយ គឺអ៊ីម៉ែលដែលមានលេខ D នៅទីនោះ។

**ស៖** គឺ D3/66/7.1.14 រៀបរាប់អំពីឯកសារ តើលោកអាចរៀបរាប់ថា តើក្នុងដំណាក់កាលនៃការសិក្សាកម្រិតខ្ពស់នៅពេលដែលលោកធ្វើការស្រាវជ្រាវ ដែលនាំឲ្យឈានទៅដល់ការបោះពុម្ពសៀវភៅនេះ ហើយការបោះពុម្ពសៀវភៅនៅឆ្នាំ១៩៩១ បាទ?

[១៣:៣៥:៣៨]

**ឆ៖** បាទ នេះជាកំណត់ពន្យល់នៅក្នុងលេខយោងទី១ ជាបឋមដែលខ្ញុំបានធ្វើនៅពេលដែលខ្ញុំធ្វើការនៅសាកលវិទ្យាល័យអូស្ត្រាលី ហើយខ្ញុំប្រមូលព័ត៌មានជាច្រើននៅក្នុងការសិក្សាអាជីពរបស់ខ្ញុំ។ បាទ នៅសាកលវិទ្យាល័យជាតិអូស្ត្រាលីនោះ។

**ស៖** សូមអរគុណ។ ខ្ញុំសូមចាប់ផ្ដើមការប្រើទំព័រនៅខាងលើចុងទំព័រខាងស្ដាំដៃពីមួយទំព័រម្ដង។ បាទឥឡូវទៅទំព័រ៧, អង់គ្លេស ERN00087771, ខ្មែរ 00711377 ហើយបារាំង 00722071។ នៅប្រធានបទនិយាយអំពីបញ្ញវន្ត ឬបញ្ញាជន លោកបានសរសេរថា "បើគិតធាក់ថយទៅវិញ ម៉ែខលវីកឃើរី ក៏បានរាយការណ៍ថា តើបញ្ញវន្តកម្ពុជាក៏ គឺនិយាយពីឈានចូលទៅដល់បញ្ហាសន្តិសុខអំពីការយកចិត្តទុកដាក់បក្សកុម្មុយនីស្តកម្ពុជាដែលថា លោក ខៀវ សំផន ក៏ពាក់ព័ន្ធ។ គាត់បាននិយាយអំពីគ្រូម្នាក់ដែលគាត់បានសម្ភាសនៅពេលដែលរបបនោះត្រូវបានផ្តួលនៅឆ្នាំ១៩៧៩។ ប្រាប់គាត់ថា រហូតដល់ឆ្នាំ១៩៧៥ គាត់មានការពេញចិត្តជាមួយនឹងបដិវត្តន៍ ហើយកោតសរសើរលោក ខៀវ សំផន។ គាត់ក៏បានជឿជាក់នៅកាលនោះ អំពីមូលហេតុនៃបក្សកុម្មុយនីស្តកម្ពុជា ហើយនិងវិធានការរបស់បក្សនេះ ហើយជាពិសេសមិនមានការភ័យខ្លាច ហើយនិងព្រួយបារម្ភអំពីអនាគតដែរ"។ លោកយោងទៅរក

ម៉ៃខល វីកឃើរី កម្ពុជាឆ្នាំ១៩៧៥ ដល់១៩៨២ ហើយ វីកឃើរី នេះគឺមានទំនាក់ទំនងជាមួយគាត់។ តើលោកអាចនឹងបានខ្លឹមសារដូចម្ដេចដើម្បីដាក់ជាលេខយោងនៅក្នុងឯកសារនេះ?

[១៣:៣៨:២៤]

**ឆ៖** ម៉ៃខល វីកឃើរី គាត់ជាអ្នកប្រវត្តិវិទូដើងចាស់អំពីកម្ពុជា ការងារដំបូង គឺគាត់ធ្វើការអំពីសម័យបុព្វកាលកម្ពុជា ហើយគាត់បន្តទៅនឹងនយោបាយសម័យថ្មី ហើយនិងគាត់ការ -- មានអត្ថបទបោះពុម្ពផ្សាយរបស់គាត់។

**ស៖** ហើយនៅក្នុងទំព័រដដែលនេះ ចំណងជើងថា “ខៀវ សំផន ហើយនិងរំដោះ” ហើយនិយាយអំពីការបំពានលើកសេចក្ដីទុកចិត្ត ដែលគាត់មាននោះ គឺ ខៀវ សំផន បានជួយក្នុង -- អំពីរៀបចំមន្ត្រីយោធា ទាហាន លន់ នល់ ដើម្បីការកាប់សម្លាប់ ហើយដើម្បីឱ្យអ្នកទាំងអស់ហ្នឹងអាចជួបនូវជោគវាសនាស្លាប់។ ដូច្នេះ បក្សកុម្មុយនីស្ដកម្ពុជាអាចពង្រឹងគោលការណ៍របស់ខ្លួនដល់ការជោគជ័យរហូតដល់៤ខែមុនឆ្នាំ -- ក្នុងឆ្នាំ១៩៧៥។ ខៀវ សំផន ក៏បានធ្វើការវាយប្រឆាំងនឹងពួកគេ មានតែមេដឹកនាំកំពូលតែប្រាំពីរនាក់តែប៉ុណ្ណោះដែលនឹងត្រូវពិឃាដនៅពេលពួកគេចុះចាញ់។

ជើងទំព័រ២៥ នៅថ្ងៃទី២៤-២៥ ខែកុម្ភៈ “ខៀវ សំផន បានធ្វើជាប្រធាននៃសមាជជាតិដែលជាកិច្ចប្រជុំរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ដែលមានតំណាង ២៧៣ នាក់ដែលចូលរួម។ សន្និសីទនេះប្រកាសថា ជនក្បត់ត្រូវស្លាប់ ប៉ុន្តែអ្នកដែលមានឋានៈខ្ពស់នៅក្នុងសាធារណរដ្ឋខ្មែរគប្បីចូលរួមក្នុងភាគី សីហនុ។ បន្ទាប់មកគឺថាពីរបីសប្ដាហ៍មុនកាន់កាប់ភ្នំពេញ ខៀវ សំផន បាននិយាយក្នុងការវិទ្យុផ្សាយបន្តផ្ទាល់របស់បក្សកុម្មុយនីស្ដកម្ពុជា គឺការវាយប្រហារជនក្បត់ទាំងប្រាំពីរ ហើយប្រកាសមន្ត្រីយោធាសាធារណៈ ទាហានសាធារណរដ្ឋឱ្យទម្លាក់អាវុធ ហើយនិងចូលរួមខាងភាគីខាង សីហនុ។ ហើយគាត់ធ្វើជាប្រធាននៃការប្រជុំលើកទី២ ហើយប្រកាសនៅថ្ងៃទី០១ ខែមេសា”។ ខ្ញុំសួរអំពីការផ្សាយនៅថ្ងៃទី០១ ខែមេសា -- មិនមានជើងទំព័រទេនៅកន្លែងនេះ -- តើលោកនៅចាំទេ អំពីខ្លឹមសារដែលគេយោងនៅថ្ងៃទី០១ ខែមេសា នេះ? តើលោកនៅកម្ពុជាទេពេលនោះ? តើលោកបានឮថាតើលោកបានព័ត៌មានអីដែលអាចសរសេរនៅក្នុងអត្ថបទនេះបាន?

[១៣:៤១:២៤]

**ឆ៖** លេខយោងគឺថាទៅតាមលំដាប់លំដោយដែលចងក្រងដោយ ធីម ខានី ដែលពេលនោះគាត់ជាមន្ត្រីទទួលបន្ទុកយោធានៅស្ថានទូតអាមេរិកនៅកម្ពុជាកាលនោះ។ ខ្ញុំពឹងផ្អែកលើព័ត៌មានរបស់

គាត់ ពីព្រោះខ្ញុំមិនទាន់មាននៃឯកសារបកប្រែពីសេវាផ្សាយព័ត៌មានបរទេសតាមវិទ្យុនោះនៅឡើយទេ។ ខ្ញុំនៅ -- ខ្ញុំមិនបាននៅកម្ពុជាទេ នៅថ្ងៃទី១ នោះ ហើយយើងក៏មិនមានលទ្ធភាព របាយការណ៍ប្រចាំថ្ងៃ បរទេសនោះដែរ។ ស្ថានទូតអាមេរិកក៏បានផ្សព្វផ្សាយតាមរយៈប្រព័ន្ធទូរសារប្រចាំថ្ងៃ។ ខ្ញុំបានអាន ប៉ុន្តែ ខ្ញុំមិនបានឯកសារដែលនោះទេ។ ខ្ញុំផ្អែកលើឯកសាររបស់ ខានី ដែលផ្អែកទៅលើការបកប្រែរបស់ សេវាផ្សាយព័ត៌មានបរទេសកាលណោះ។

[១៣:៤២:៤៣]

**ស៖** ដើម្បីយើងច្បាស់ អ្វីដែលយើងហៅថា "ហ្វីប៊ីស" គេហៅថាឯកសារផ្សព្វផ្សាយព័ត៌មានបរទេស ហើយលោកបានអាននៅក្នុងឆ្នាំ១៩៧៥។ ប៉ុន្តែលោកមិនមានទៅដល់ដៃលោកទេ នៅពេលដែលលោកសរសេរឯកសារនេះ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ខ្ញុំចង់សួរសំណួរមួយអំពីឯកសារហ្វីប៊ីសនេះ។ ការផ្សព្វផ្សាយនេះគឺឯកសារ E3/118។ ប៉ុន្តែខ្ញុំចង់ឲ្យឃើញរូប យល់ពីរូបភាពថាតើការផ្សព្វផ្សាយនេះ គេផ្សព្វផ្សាយដូចម្តេច? ថាតើលោកអាចនឹងអានព័ត៌មាននៅក្នុងហ្វីប៊ីសនេះដូចម្តេច? តើលោកយល់ទេ?

**ឆ៖** បុគ្គលិករដ្ឋាភិបាលសហរដ្ឋអាមេរិកធ្វើការតាមដានការផ្សព្វផ្សាយព័ត៌មានអន្តរជាតិនេះ គេមានទីតាំងនៅប្រទេសថៃ។ គេស្តាប់ការផ្សព្វផ្សាយ ហើយកត់ត្រា ហើយគេធ្វើការបកប្រែ។ អ្វីដែលគេធ្វើនៅពេលនោះគឺការបកប្រែ និងគេបញ្ជូនទៅស្ថានទូតអាមេរិកទូទាំងពិភពលោកក្នុងរូបភាពជា *តេឡេថាយ* បាទគឺគេចាត់ទុកថាជាឯកសារសាធារណៈនៅក្នុងប្រព័ន្ធរដ្ឋាភិបាលសហរដ្ឋអាមេរិក។

[១១:៤៤:២៤]

ដូច្នេះ យើងអាច យើងឃើញអាចទៅមើលបាន ដែលយើងឃើញអាចអានជារៀងរាល់ថ្ងៃ នៅមានបន្ទប់សម្រាប់អានមួយនៅស្ថានទូតអាមេរិកនៅភ្នំពេញ។ ថាតើហ្វីប៊ីសហ្នឹងបានបកប្រែអ្វីខ្លះ? មានឯកសារខ្លះ បើមិនទាំងអស់ទេ គឺនៅក្នុងអត្ថបទបកប្រែតាមតេឡេថាយនេះគឺគេបានចងក្រងជារបាយការណ៍ប្រចាំថ្ងៃ។ អាចមានរូបភាពជាទស្សនាវដ្តី គេដាក់នៅតាមបណ្ណាល័យមួយចំនួននៅតាមពិភពលោក មិនមែនសាកលវិទ្យាល័យអូស្ត្រាលីទេ។ តាមពិតនៅខូណែល គេមានជាអត្ថបទជាភាសាអង់គ្លេសហ្នឹង គឺមានច្បាប់ចម្លងដែលគេផ្សាយ គឺថាមានចំណុចមួយចំនួន ប៉ុន្តែអត្ថបទហ្នឹងដូចគ្នានឹងគេផ្សាយដើមនោះ។

**ស៖** ខ្ញុំដឹងពីអ្វីដែលលោកយល់ ប៉ុន្តែខ្ញុំចង់ឲ្យលោកពន្យល់ដើម្បីប្រយោជន៍តុលាការ ឯកសារនៅក្នុងសំណុំរឿងគឺមានហ្វីប៊ីស គឺមានពាក្យនៅលើហ្នឹង អេស.ដាប់ប៉ែលយូ.ប៊ី។ បាទតើអ្វីលោកអាចពន្យល់បានទេ? លោកនិយាយថា លោកមកកម្ពុជាក្នុងឆ្នាំ១៩៧៣ តើត្រូវទេ?

[១៣:៤៦:០១]

**ឆ៖** បាទ ដំបូងគឺឆ្នាំ១៩៦៩ គ្រាន់តែមកឆ្លងកាត់ ប៉ុន្តែមកធ្វើការក្នុងឆ្នាំ១៩៧៣។

**ស៖** តើក្នុងសមត្ថភាពជាអ្នកកាសែត ជាអ្នករាយការណ៍ តើជាគោលបំណង ហើយនិងប្រវត្តិការងារអ្វីដែលថាលោកមកកម្ពុជាឆ្នាំ១៩៧៣នោះ?

**ឆ៖** ខ្ញុំបញ្ចប់អនុបណ្ឌិតនៅខូណែល ហើយខ្ញុំចង់ធ្វើជាអ្នកកាសែត ជាអ្នកសារព័ត៌មាន។ ដំបូងខ្ញុំទៅហុងកុង បន្ទាប់មកមកបាងកក ហើយខ្ញុំធ្វើការអំពីប្រទេសចិន និងប្រទេសថៃ ប៉ុន្តែនៅហុងកុងមានការលំបាក។ ប៉ុន្តែអាចនឹងធ្វើការងារល្អជាងនៅបាងកក ហើយខ្ញុំអាចមកកម្ពុជាមិនមានការប្រកួតប្រជែងច្រើនទេ។ រឿងរ៉ាវទាំងអស់ហ្នឹង គឺយើងស្រួលប្រមូលព័ត៌មាន ហើយតាមអ្វីដែលខ្ញុំចាំនោះក្នុងខែឧសភា ឆ្នាំ១៩៧៣ ខ្ញុំមកដល់កម្ពុជា។

**ស៖** តើលោកនៅចាំទេហេតុការណ៍ពីរបីដំបូង ដែលលោកបានរាយការណ៍ ហើយនិងយកព័ត៌មានកាលណោះ?

**ឆ៖** បាទ រឿងធំៗអំពីដំណាក់កាលនោះគឺ ព្រឹទ្ធសភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់មួយបានបញ្ចប់ការទម្លាក់គ្រាប់បែកនៅកម្ពុជា គឺថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣។ នោះគឺជាការរំពឹងជាទូទៅថាភ្លាមៗ ដែលសហរដ្ឋអាមេរិកបានបញ្ចប់ការទម្លាក់គ្រាប់ ខ្មែរក្រហមនឹងដើរចូលមកភ្នំពេញហើយដោយសារសារធាណរដ្ឋខ្មែរនឹងដួលរលំ។

[១៣:៤៨:១៦]

នោះគឺជាទស្សនវិស័យដែលខ្ញុំយល់ អាចជាដំណឹងល្អដំណឹងអាក្រក់កាលណោះ។ ដំណឹងអាក្រក់នោះមានន័យថាអំណាចខ្ពស់ៗ គឺថាការឆ្លើយឆ្លងសារព័ត៌មាននោះគឺពួកគេមកច្រើន ពួកគេមកភ្នំពេញមកចាំមើលថាខ្មែរក្រហមចូលដូចម្តេច។ អ៊ីចឹងហើយពួកគេក៏បានបិទផ្លូវមិនឲ្យខ្ញុំចូលទៅក្នុងការងារនោះបានស្រួលដែរ។ គឺថាមានមនុស្សច្រើន គឺថាដោយសារខ្ញុំមិនមានការងារដោយពិតប្រាកដទេ។ ដំណឹងល្អគឺថាមានមនុស្សជាច្រើនគេត្រូវការជំនួយ ហើយខ្ញុំក៏បានភ្ជាប់ធ្វើការងារ ជាការងារបន្តបន្ទាប់។ បាទជាមុខតំណែងពេញម៉ោង ហើយដែលខ្ញុំធ្វើការងារជាមួយ "អ៊ិន.ប៊ី.ស៊ី" ហើយជាបណ្តាញទូរទស្សន៍

និងវិទ្យុផងដែរ ហើយនិងសារព័ត៌មាន "*ថាមស៍-ញូវម៉ាហ្គាហ្សីន*" ផងដែរ។ ខ្មែរក្រហមមិនទាន់មកទេកាលនោះ ហើយសារព័ត៌មានថាមស៍ក៏បានចេញទៅ ហើយរឿងរ៉ាវទាំងអស់ហ្នឹងគឺថាយើងត្រូវនៅចាំធ្វើការបន្តទៅទៀតកាលនោះ។

**ស៖** ខ្ញុំចង់ឲ្យរៀបរាប់ពីរូបភាព តើពិភពអ្នកកាសែតឆ្នាំ១៩៧៣ និង១៩៧៤នោះយ៉ាងដូចម្ដេច? ខ្ញុំចង់សួរលោកបែបនេះ តើទំនាក់ទំនងរវាងសមាជិកអ្នកសារព័ត៌មានឆ្លើយឆ្លងគ្នាដូចម្ដេចនៅក្នុងកម្ពុជា? តើមនុស្សប៉ុន្មាននាក់ដែលធ្វើការរាយការណ៍? អ្នកណាដែលបានចេញទៅតាមមូលដ្ឋាន តាមវាល? តើលោកយល់ទេ អ្នកចូលទៅក្នុងវាលទៅតាមមូលដ្ឋាននោះ? សូមលោកនិយាយមើលអំពីពិភព អាជីពដែលលោកធ្វើការនៅក្នុងនោះ តើមានអ្នកណាខ្លះនៅក្នុងភ្នំពេញ ក្រៅភ្នំពេញ ដើម្បីប្រមូលព័ត៌មានជាដើម?

[១៣:៥០:២៩]

**ឆ៖** យើងមានពីរផ្នែកមានអ្នកឆ្លើយឆ្លងព័ត៌មានជាបុគ្គលិកនៅទីភ្នាក់ងារព័ត៌មានខ្លះ អ្នកខ្លះគឺថាមានវ័យចំណាស់ អ្នកខ្លះធ្លាប់ធ្វើការជាមួយខាងវៀតណាម ហើយជាអ្នកឆ្លើយឆ្លងព័ត៌មានតាមសមរភូមិ ហើយយើងមានក្រុមមួយវ័យក្មេងៗទេ។ ខ្ញុំស្ថិតនៅក្រុមពួកក្មេងៗ ប៉ុន្តែអ្នកកាសែតចាស់នោះគាត់ឈ្មោះ នៀល ដេវីស ជនជាតិអូស្ត្រាលី។ ហើយគាត់ក៏ជាអ្នកថតរូបផងដែរ អ្នករាយការណ៍ ហើយអ្នករាយការណ៍បារាំងឈ្មោះ វីង គាត់បានជួយខ្ញុំ។ ខ្ញុំបានធ្វើការច្រើនជាមួយគាត់។ ហើយមានអ្នកថតរូបជប៉ុនក្មេងម្នាក់ មិនមែនម្នាក់ទេដែលខ្ញុំលើកពីមុនទេ។ ខ្ញុំធ្វើការជាមួយគាត់ច្រើន ហើយខ្ញុំប្រើពេលមួយចំនួនជាមួយម្នាក់ទៀតឈ្មោះ កូគី *(តាមសូរស័ព្ទ)* ជាអ្នកធ្វើការឲ្យក្យូដូ ជនជាតិជប៉ុន ហើយនិងពេលខ្លះខ្ញុំជាមួយ អេលីហ្សាប៊េត បេកយ័រ ផងដែរ។ កាលនោះខ្ញុំថា -- គាត់ធ្វើការឲ្យវ៉ាស៊ីនតោនប៉ុស្តិ៍ នៅពេលដែលរឿងរ៉ាវធំ អ្នកកាសែតមកពីហុងកុង មកពីសៃហ្គន។ យើងក្មេងៗហ្នឹងយើងផ្សាភ្ជាប់ជាមួយអ្នកទាំងអស់នោះ ប៉ុន្តែបើមិនមានស្ងប់ស្ងាត់ -- មិនមានអ្វីទេយើង ពួកជើងចាស់នោះក៏ចេញទៅអស់នៅតែយើងក្មេងៗទេ។ ហើយយើងធ្វើការងារម្ដងម្កាលតែប៉ុណ្ណោះនៅក្នុងអំឡុងឆ្នាំដែលលោកសួរនេះ។

**ស៖** ខ្ញុំសួរលោកថា នៅតាមមូលដ្ឋាន នៅតាម តើឬក៏ជាអ្នករាយការណ៍ពីការិយាល័យនៅភ្នំពេញ តើវិធីនៃការធ្វើការងាររបស់លោកនោះដូចម្ដេច?

[១៣:៥២:៤៧]

**ឆ៖** ខ្ញុំមិនមែនជាអ្នកយកព័ត៌មាននៅតាមមូលដ្ឋាន ដល់ទីកន្លែង ដូចជាអ្នកដែលចុះទៅតាមសមរភូមិនោះទេ។ ខ្ញុំចំណាយពេលខ្លះនៅតាមមូលដ្ឋានឬក៏តាមសមរភូមិ នៅជុំវិញភ្នំពេញដូចជានៅឧដុង្គ ពេលខ្លះខ្ញុំទៅបាត់ដំបង។ ខ្ញុំក៏មានការងារសិក្សាស្រាវជ្រាវសម្រាប់ថ្នាក់បរិញ្ញាបត្ររបស់ខ្ញុំដែរ ខ្ញុំចង់ដឹងអំពីប្រវត្តិ ហើយនិងប្រវត្តិខ្មែរក្រហមឆ្នាំ១៩៧០ ឬក៏៦៩។ ខ្ញុំធ្វើការងារបណ្ណសារ ហើយការងារចុះមូលដ្ឋាន ហើយខ្ញុំធ្វើតាមសមរភូមិខ្លះដែរ។ ជាពិសេសគឺនិយាយអំពីយោធារបស់សាធារណរដ្ឋខ្មែរ លន់ នល់ នៅភ្នំពេញ។

**ស៖** តើថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ គឺជាការសម្រេចបញ្ចប់ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក? តើលោកបានឃើញតើអ្នកណាប្រាប់លោកថាមានការបន្តទម្លាក់គ្រាប់បែកបន្ទាប់ពីហ្នឹងទៅទៀតទេ?

**ឆ៖** អត់ទេ។ ចំណុចនោះការទម្លាក់គ្រាប់បែករបស់ទ័ពអាកាសអាមេរិកនោះក៏បានបញ្ចប់ភ្លាមពេលនោះ។ កងកម្លាំងសាធារណរដ្ឋខ្មែរនៅបន្តទម្លាក់គ្រាប់បែក ជាពិសេសគឺនៅបន្តសកម្មភាព និងទ័ពជើងគោកដែរ សាធារណរដ្ឋខ្មែរនោះ។

[១៣:៥៤:៤៣]

**ស៖** ឥឡូវនេះសួរសំណួរនៅពេលក្រោយ។ ខ្ញុំមិនអាចនិយាយពី១ថ្ងៃទៅ១ថ្ងៃទេ ដែលលោកបាននៅទីនេះកាលនោះ។ បាទ បើសិនជាលោកដឹងនៅខែឧសភា ឆ្នាំ១៩៧២ ហើយខ្ញុំដឹងថាលោកបានចាកចេញខែមេសា ឆ្នាំ១៩៧៥ តើថ្ងៃណាដែលលោកបានចាកចេញទៅវិញនោះ?

**ឆ៖** បាទ គឺថ្ងៃទី១១ ខែមេសា ដូចដែលខ្ញុំបញ្ជាក់ហ្នឹង ដែលខ្ញុំជិះយន្តហោះជាមួយ ដេវីស។ ខ្ញុំជិះយន្តហោះចេញជាមួយការជម្លៀសពលរដ្ឋអាមេរិកាំង ហើយអ្នកដែលចង់ទៅជាមួយនោះ ក៏អាចទៅបានខ្លះដែលកាលណោះ។

**ស៖** ខ្ញុំចង់សួរលោកអំពីសមរភូមិ ពីខែឧសភា ឆ្នាំ១៩៧៣ ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៥ អំពីសំណួរជាក់លាក់នេះឯងបាទ។ តើលោកខ្លួនឯងបានឃើញ ឬក៏អ្នកណាប្រាប់លោក ឬក៏ព័ត៌មានអីមកដល់លោក អំពីតើមានកើតឡើងក្នុងករណីដែលរឿងហ្នឹងវាកើតឡើង អំពីទាហាន លន់ នល់ ដែលគេចាប់ខ្លួនបាននោះ។ គឺទាហាន លន់ នល់ ដែលគេចាប់បាន គឺ ដែលកងកម្លាំងខ្មែរក្រហមចាប់បាន ស៊ី.ភី.អិន.អិល, អេ.ហ្វេស នោះ តើលោកអាចពន្យល់បានទេ? លោកដឹងអ្វីខ្លះអំពីរឿងនេះ?

[១៣:៥៦:៣១]

**ឆ៖** ខ្ញុំអាចឆ្លើយថា ទេ ខ្ញុំនឹកមិនឃើញភ្លាមទេ វាអាចមាននៅក្នុងឯកសារ។ ខ្ញុំនឹកមិនឃើញជាក់លាក់អ្វីដើម្បីប្រាប់លោកនៅពេលនេះបានទេ។

**ស៖** លោកនិយាយអំពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣។ តើខ្ញុំអាចសូមឱ្យលោកព្យាយាមគិត តើហេតុការណ៍សំខាន់ៗមួយពីរ បន្ទាប់ពីនោះមក ដែលលោកនៅចាំថាលោកបានយកការណ៍ និងរាយ-ការណ៍ពីហេតុការណ៍នោះទេ?

**ឆ៖** បាតុកម្មប្រឆាំង លន់ នល់ នៅក្នុងទីក្រុងភ្នំពេញក៏មានឡើង ដោយរាប់បញ្ចូលទាំងហេតុការណ៍ដែលរដ្ឋមន្ត្រីពីររូបត្រូវបានគេសម្លាប់។ ការវាយប្រហារ វាយលុកនៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥ ហើយនិងសមរភូមិបន្តបន្ទាប់នៅបរិវេណជុំវិញភ្នំពេញនេះ ក្នុងខណៈពេលដែលកងកម្លាំងខ្មែរក្រហមវាយសម្រុកចូលមកនោះ។ ហើយរហូតមកដល់របាយការណ៍ចុងក្រោយដែលនិយាយអំពីការជម្លៀសរបស់សហរដ្ឋអាមេរិកចេញពីភ្នំពេញ។ គឺការជម្លៀសបុគ្គលិក ឬក៏ប្រជាជនសហរដ្ឋអាមេរិក ឬក៏អ្នកណាដែលចង់ទៅជាមួយអាមេរិកកាលណោះ បាទ។

[១៣:៥៨:១៨]

**ស៖** នៅក្នុងរយៈកាលនេះ តើលោកបានរស់នៅភាគច្រើននៅក្នុងភ្នំពេញ តើលោកទៅ ចុះទៅតាមមូលដ្ឋាន ឬក៏លោកទៅកន្លែងផ្សេងៗទៀតក្នុងប្រទេសដែរឬទេ?

**ឆ៖** អត់ទេ ខ្ញុំនៅភ្នំពេញ នៅភាគខាងត្បូង ខាងនិរតីនៃភ្នំពេញ។ ខ្ញុំចេញទៅកន្លែងនោះ ពីព្រោះកន្លែងដែលខ្ញុំនៅហ្នឹង គឺគ្រាប់ផ្លោង១០៥ ធ្លាក់កៀកៗពេក អ៊ីចឹងហើយខ្ញុំ មួយគឺ១០៧មិល្លីម៉ែត្រគឺមកពីខាងកើត គឺថាអ៊ីចឹងខ្ញុំត្រឡប់មកនៅចំកណ្តាលដើម្បីជៀសវាងការផ្លោងគ្រាប់នោះ។

**ស៖** ដើម្បីឱ្យលោកបញ្ជាក់ជារូបភាពរួម។ សំណួរថាតើលោកនៅភ្នំពេញ លោកឃើញថាគេផ្លោងដាក់មក តើការផ្លោងនោះវាទៀងទាត់? វាច្រើនប៉ុនណា? តើអ្វីដែលលោកដឹង លោករស់នៅក្នុងភ្នំពេញ ថាតើការផ្លោងៗ មកពីខាងណា? វាទៀងទាត់ម៉េច ថ្ងៃយប់យ៉ាងដូចម្តេច? សូមលោកបញ្ជាក់។

[១៣:៥៩:៤៤]

**ឆ៖** វាដូចជាលោកធ្វើដូចជាអគ្គនាយក "*ថាមស៍ មេហ្គាហ្វិន*" របស់ខ្ញុំអ៊ីចឹង គាត់សួរខ្ញុំអ៊ីចឹង។ គឺគ្រាប់ផ្លោង គឺថានៅពេលដែលខ្ញុំនៅភាគនិរតីនៃក្រុងភ្នំពេញ ខ្ញុំជីកបាំងគ័រនៅក្រោមផ្ទះរបស់ខ្ញុំ – ជាត្រង់សេ – ខ្ញុំត្រូវថាតើត្រូវដាក់ដីកម្រាស់ប៉ុន្មានដើម្បីឱ្យសុវត្ថិភាព ខ្ញុំចូលទៅឮពេលអ្វី -- បាទ និយាយដោយសង្ខេបនៅពេលដែលគ្រាប់ផ្លោងធ្លាក់មកពី -- គេផ្លោងមកពីខាងកើត យើងអាចអង្គុយនៅមុខរាំង

មាត់ទន្លេ គឺថាយើងឃើញៗថាគេបាញ់ផ្លោងមករំលងក្បាលយើង ហើយធ្លាក់ចំកណ្តាលទីក្រុងភ្នំពេញអង្គាល់ណោះ។ ហើយមានមនុស្សជាច្រើនបានស្លាប់ ស្ថានភាពសេដ្ឋកិច្ចសង្គមនៅក្នុងទីក្រុងនោះ គឺថាវាមានភាពតានតឹងណាស់។ ម្នាក់ៗដឹងថាមនុស្សមានច្រើនណាស់ ដែលមកពីជនបទមកនៅភ្នំពេញដែរ។ ស្ថានភាពនយោបាយនោះ គឺជាគេប្រឆាំងនឹងរដ្ឋាភិបាល ជាពិសេសពួកនិស្សិត គឺជាស្ថានភាពបដិវត្តន៍ជាទ្រង់គំរូមួយ គឺថានិស្សិតបញ្ញវន្ត គឺប្រឆាំងនឹងរដ្ឋាភិបាលវណ្ណៈកណ្តាល គឺមានចំនួនតិច គឺក៏អាចប្រឆាំងរដ្ឋាភិបាលដែរ។

[១៤:០១:១៨]

ហើយសភាពការណ៍ទាំងអស់នេះ នាំឲ្យយើងអាចយោងនៅក្នុងឯកសារនេះថា គឺជាការចាប់ផ្តើមនៃការពិភាក្សានេះឯង។ ខ្ញុំគិតថា ខ្ញុំនិយាយនៅក្នុងឯកសារនេះ ជារឿងរ៉ាវ នៅក្នុង "*ថាមស៍មេហ្គាហ្សីន*" ដែលមិនបានបោះពុម្ពផ្សាយ ខ្ញុំនិយាយពីគេ ការដឹកនាំរបស់ខ្មែរក្រហម។ ហើយមានរឿងមួយចំនួនដែលគេឲ្យខ្ញុំធ្វើ ប៉ុន្តែមិនដែលបានបោះពុម្ពផ្សាយដែរ។ និយាយដោយសាមញ្ញ គឺជាអ្វីដែលប្រជាជនភ្នំពេញគិតនៅកាលណោះ ថានឹងកើតអ្វីនៅពេលដែលខ្មែរក្រហមមកចូលមកនោះ។

នេះក្នុងបរិបទនៃពេលវេលាមានការពិភាក្សាជាច្រើនបន្ត -- ជាច្រើននៅសហរដ្ឋអាមេរិកដែលនិយាយជាសំខាន់អំពីវៀតណាម ដែលកម្ពុជាគឺគ្រាន់តែជារឿងតូចមួយទេ កាលណោះអាមេរិកគិត។ នៅពេលដែលកុម្មុយនីស្តឈ្នះ នៅឆ្នាំ១៩៧៥ មិនអាចជៀសបានទេថា តើគឺមានការត្រឡប់មកវិញរបស់សហរដ្ឋអាមេរិក។ ហើយអគ្គនាយករបស់ខ្ញុំហ្នឹងថា សួរខ្ញុំថាតើកម្ពុជានៅភ្នំពេញ ៗថាគេចង់ឲ្យមានការពាក់ព័ន្ធអាមេរិកមកវិញអត់? បើតាមដឹងទៅ គេចង់បានតែសន្តិភាព ភាគច្រើនគេថាអត់ទេ អត់ចង់បានទេ។

[១៤:០៣:០៣]

ហើយតាមពិត មូលហេតុមួយចំនួនសំខាន់ៗដែលហេតុអីបានប្រជាជននិយាយបែបនេះ គឺគេជឿជាក់ថា ខ្មែរក្រហមនឹងត្រូវដឹកនាំដោយ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ដែលអ្នកទាំងនេះគឺថាមនុស្សភាគច្រើន ទាំងអ្នកឆ្វេងនិយម ស្តាំនិយម គិតថាពួកគាត់ហ្នឹងជាមនុស្សល្អ ស្នេហាជាតិ ជាមនុស្សដែលធ្វើការងារល្អសម្រាប់ប្រទេស សម្រាប់ប្រជាជន គឺជាការយល់ជាទូទៅនៅពេលនោះ ដែលថាខ្មែរក្រហមអាចនឹងខុសគ្នាពីអ្វីដែលគេយល់ពីដើម។

ហើយទស្សនៈម្យ៉ាងទៀតនោះ គឺថាពួកគេប៉ុន្តែអាក្រក់ជាជាងកុម្មុយនីស្តដទៃទៀត។ ខ្ញុំចាំទាក់ទង

ទៅនឹងចំណុចមួយដែលថា ខ្ញុំអាចនឹងនិយាយពីបញ្ហានេះ គាត់និយាយថា បញ្ហាថាតើកម្ពុជាអាចនឹង -- ខ្មែរក្រហមអាចនឹងខុសទេ ប៉ុន្តែរូបភាពខុសក្នុងទាក់ទងតាមរបៀបជាយូហ្គោស្លាវី ដែលលក្ខណៈជាកុម្មុយនីស្តកណ្តាល ឬក៏អាល់បានី កុម្មុយនីស្តអាល់បានី ដែលមានលក្ខណៈជ្រុលនិយមបាទ។ ទស្សនៈទូទៅ គឺវាមានលក្ខណៈជាបដិវត្តន៍កណ្តាលទេ នោះគេគិតបែបនោះ។ នោះគឺជាទស្សនៈគេយល់ដឹងជាទូទៅនៅក្នុងទីក្រុងនោះ។

[១៤:០៤:៥១]

**ស៖** ខ្ញុំមានសំណួរពីរ អាចនឹងជាសំណួរ លោកគិតថា “អូ្ហ!សំណួររាក់ម្ល៉េះ!” ប៉ុន្តែខ្ញុំត្រូវតែសួរលោក។ នៅពេលដែលលោកចូលទៅក្នុងត្រង់សេដែលលោកចូល នៅពេលដែលមានគ្រាប់ផ្លោងមកពីទិសពីរកន្លែង។ តើអ្នកណាជាអ្នកផ្លោងគ្រាប់នោះ? តើលោកដឹងដែរឬទេ គ្រាប់នោះផ្លោងមកពីណាអ្នកណាអ្នកផ្លោង?

**ឆ៖** គឺគ្រាប់ហៅអារទីរីនោះ គឺៗចេញមកពីកងកម្លាំងពិសេសដែលដឹកនាំដោយ ណាត – អ៊ិនលន ហៅ ណាត។ ១០៧ មិល្លីម៉ែត្រ គឺបាញ់មកពីទិសខាងកើត មកពីកងពលមួយខាងប៉ូពាំហ្នឹងរបស់ -- ខ្ញុំដឹងថានៅពេលនោះខ្ញុំឮថាជារបស់ គឺស្នងការខាងយោធា។ ជប៉ុនបានប្រាប់ខ្ញុំថាចេញមកពីកងកម្លាំងរបស់ខ្មែរក្រហមហ្នឹងឯង។

**ស៖** តើថាតើការដែលបាញ់ផ្លោងនោះវាចំផ្លោងមកហ្នឹង គឺគេតម្រង់យកកន្លែងណាជាជាក់លាក់ទេ? គឺអាចចំសាលារៀន ចំអគាររដ្ឋាភិបាល ឬក៏គេកំណត់ទិសដៅទេ គ្រាប់ផ្លោងនោះ?

[១៤:០៦:៤៩]

**ឆ៖** គ្រាប់ផ្លោងទាំងអស់នេះ ទោះជាគ្រាប់អារទីរី ឬក៏គឺមិនមានការរើសទីកន្លែង គឺអាចធ្លាក់នៅទីលំនៅដ្ឋានប្រជាជនក៏មាន។ ឧបទ្ទវហេតុដែលអាក្រក់បំផុតមួយគឺវាកើតឡើង គឺធ្លាក់ចំកន្លែងដែលអ្នកដែលគេលក់សាំងជាច្រើននៅតាមផ្លូវ។ ការលក់សាំងនៅតាមផ្លូវនោះ គឺជាទម្លាប់របស់ប្រជាជនកម្ពុជាដែលមានលក់រហូតទៅដល់សព្វថ្ងៃហ្នឹង។ ហើយពេលដែលផ្លោងចូលមកដល់កន្លែងនេះ នៅពេលយប់ កន្លែងលក់សាំង ហើយទីពីកន្លែងដែលមានមនុស្សរស់នៅច្រើននោះ គឺថាឆេះទាំងស្រុងតែម្តង។

**ស៖** តើផ្នែកណានៃភ្នំពេញដែលកន្លែងលក់សាំងហ្នឹង គឺថាវាឆេះឡើងហ្នឹង?

**ឆ៖** នៅភាគខាងលិចនៃក្រុងភ្នំពេញ។

**ស៖** លោកយល់ថាគ្រាប់១០៥ អាចផ្លោងដោយក្រុម ណាត ហើយគ្រាប់មួយចំនួនទៀតអាច

មកពីភូមិភាគបូព៌ា។ តើជាកងទ័ពរបស់អ្នកណា លោកដឹងទេ? ថាតើស្ថិតនៅក្រោមការបញ្ជារបស់មេបញ្ជាការណាដែរ?

**ឆ៖** ការនេះគឺជាទាហានភូមិភាគ ដែលស្ថិតនៅក្រោមការបញ្ជារបស់នាយអគ្គសេនាធិការនៅពេលនុ៎ង។ គឺពេលហ្នឹងគឺថាត្រូវដឹកនាំដោយនាយអគ្គសេនាធិការឈ្មោះ សុន សេន ហើយក្រោយមកគឺថាដឹកបញ្ជារួមដោយ ប៉ុល ពត។

[១៤:០៨:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ លោកតំណាងសហព្រះរាជអាជ្ញាផ្អាកបន្តិចសិន!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ បាទខ្ញុំមើលទៅឃើញថា ហាក់បីដូចជាមានភាពច្របូកច្របល់ គឺហាក់នៅសួរក្នុងជាសាក្សីដោយផ្ទាល់នូវអ្វីដែលគាត់ឃើញក្នុងឆ្នាំ១៩៧៥ ហើយនិងសួរសំណួរថាអ្នកណាជាអ្នកបញ្ជាកងទ័ពទាំងអស់ហ្នឹង។ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ គឺថាខ្ញុំទទួលយកបានហើយក៏ប៉ុន្តែនៅក្នុងពេលនេះ ត្រូវញែកឲ្យដាច់ពីគ្នាការសួរដល់សាក្សីរបៀបនេះ។

**លោក ឃីត វេយ៍ន័រ៖**

ខ្ញុំយល់ស្របគាត់ជំទាស់នេះត្រឹមត្រូវហើយ។

[១៤:០៩:៤៥]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** បាទ ត្រឡប់ទៅឆ្នាំ១៩៧៥ឡើងវិញ បាទសុំសួរសំណួរបញ្ជាក់ដំបូងឡើងវិញ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ នៅពេលដែលលោកបានដឹងដោយផ្ទាល់អំពីកម្លាំងគ្រាប់បែក វាដែលអាចប៉ះពាល់ទៅដល់លោក ឬក៏ប៉ះពាល់ទៅដល់អ្នកដែលរស់នៅក្នុងទីក្រុងភ្នំពេញតែម្ដងនោះ តើក្នុងខែណាឆ្នាំណាដែរ?

**ឆ៖** ប្រហែលជាក្នុងរដូវប្រាំង ឆ្នាំ៧៣ ឬ៧៤។ ប៉ុន្តែការផ្គោងទ្រង់ទ្រាយធំគឺឆ្នាំ៧៤ វាចាប់ផ្ដើមតាំងពីឆ្នាំ១៩៧៣, ៧៤ គឺចុងឆ្នាំ៧៤ ហើយបន្តរហូតទៅដល់៧៥ និងបន្តរហូតទៅដល់ខែមេសា ៧៥ តែម្ដង។

**ស៖** លោកនិយាយអំពីកងទ័ព ដោយសារតែមានសេនានុព័ន្ធយោធាអមស្ថានទូតជប៉ុន ដែលប្រាប់ទៅលោក សូមលោកបញ្ជាក់ពីចំណុចនេះបន្តិចបានទេ? តើចំណុចនេះត្រឹមត្រូវអ៊ីចឹងទេ?

[១៤:១១:២០]

**ឆ៖** បាទ មានការបញ្ជាឲ្យប្រយុទ្ធព័ត៌មានក្នុងការបញ្ជាឲ្យប្រយុទ្ធ ដែលព័ត៌មាននេះខ្ញុំបានដឹងជាមួយគ្នានឹងសេនានុព័ន្ធយោធាអមស្ថានទូតជប៉ុន ដែលថានេះយើងបានដឹងពីភ្នាក់ងារទាហានសាធារណរដ្ឋខ្មែរ។ គឺទាហានសាធារណរដ្ឋខ្មែរ និងជនស៊ីវិល ភ្នាក់ងារជនស៊ីវិល ដែលក្នុងនោះគឺមានគេហៅថាអង្គលេខ ត្រូវបានរៀបចំឡើងដោយភ្នាក់ងារស៊ីវិល អំពីរចនាសម្ព័ន្ធ និងអង្គការចាត់តាំងរបស់កងទ័ពខ្មែរក្រហម ក៏ដូចជារចនាសម្ព័ន្ធនយោបាយ មេដឹកនាំនយោបាយរបស់ខ្មែរក្រហម។ មានតាំងពីកំណត់ទីតាំង និងជាពិសេសអង្គភាពយោធា ឈ្មោះមេបញ្ជាការយោធា និងអង្គភាពនយោបាយដែលភ្ជាប់នៅជាមួយផង។ ដូច្នេះ គឺយើងមានគេហៅថា តារាងបញ្ជាទូទៅនៃរចនាសម្ព័ន្ធរបស់ខ្មែរក្រហម ដែលគេបានដឹងរួចទៅហើយពេលហ្នឹង។ ហើយពេលហ្នឹងគឺថាហាក់បីដូចជាថា វាមានភាពសុក្រឹតមែនទែននេះគឺព័ត៌មានពីភ្នាក់ងារសម្ងាត់ ដែលបានផ្តល់មកឲ្យសេនានុព័ន្ធយោធាស្ថានទូតជប៉ុន ដល់ហើយក្រោយមកដល់ស្ថានទូតអាមេរិក ហើយព័ត៌មាននេះធ្លាយមកដល់ខ្ញុំដែរ។

[១៤:១៣:១៨]

**ស៖** ខ្ញុំចង់សួរអំពីឯកសារពីរ គឺការបញ្ជាប្រយុទ្ធ និងអង្គការលេខ។ លោកនិយាយថាព័ត៌មានគឺធ្លាយមកដល់លោកតាមរយៈស្ថានទូតអាមេរិក។ បាទ លោកលើកឡើងចំណុចលើសពីនេះទៅទៀត។ នូវអ្វីដែលខ្ញុំសួរលើកមុន គឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធកងទ័ព ហើយលោកលើកឈ្មោះមេបញ្ជាការពីរនាក់ ខ្ញុំអត់ចាំទេពេលនេះ។ មួយឈ្មោះ អ៊ិន លន ហៅ ណាត ហើយក្រោយមកលោកនិយាយអំពី សុន សេន ហើយនិយាយមនុស្សម្នាក់ទៀតផងដែរ។

ខ្ញុំសូមសួរលោករបៀបនេះ តាមរយៈឯកសារបញ្ជាក់អំពីការបញ្ជាប្រយុទ្ធ ឬឯកសារនិយាយអំពីអង្គការចាត់តាំង តើលោកនៅចាំទេ នៅក្នុងឯកសារទាំងពីរហ្នឹង អ្នកណាស្ថិតនៅកំពូល អ្នកណាបន្ទាប់? បាទ សូមចាប់ផ្តើមពីមេបញ្ជាការដែលលោកនិយាយឈ្មោះអម្បាញ់មិញទៅ ឡើងទៅដល់កំពូលទៅ?

**ឆ៖** បាទ យ៉ាងហោចណាស់ឯកសារនេះគឺថា សាឡុត ស ស្ថិតនៅកំពូលហើយ។ ប៉ុន្តែមានការមិនចុះសម្រុងគ្នាថាតើ សាឡុត ស ហ្នឹងជាអ្នកណាអីអ្នកណា គឺថាមានការមិនចុះសម្រុងគ្នា។ ប៉ុន្តែក្រោយពីមានការរាយការណ៍ដោយ អ៊ិត សារិន ដែលគាត់ស្ថិតនៅក្នុងក្បាលម៉ាស៊ីនរបបសាធារណរដ្ឋ

ខ្មែរហើយចូលទៅខាងខ្មែរក្រហម ចូលទៅជាក្នុងក្បាលម៉ាស៊ីនដឹកនាំខ្មែរក្រហម។ ចំពោះ ណាត គាត់ស្ថិតនៅក្នុងភូមិភាគពិសេស។ តាមការចងចាំរបស់ ខ្ញុំនៅពេលនោះមាន វន វ៉េត គាត់ជាប្រធានភូមិភាគពិសេស ហើយក្នុងនោះក៏មាន សោ ធួក ហើយ តាម៉ុក ក៏គេមាននិយាយឈ្មោះគាត់ លើកពីឈ្មោះតាម៉ុក នៅពេលនោះ។ ហើយនៅភូមិភាគបូព៌ាមានឈ្មោះ សោ ភឹម ហើយឈ្មោះហៅក្រៅហៅ សូវណ្ណា ហើយនិងលេខាភូមិភាគដទៃទៀតគឺថាត្រូវបានគេកំណត់ ឈ្មោះយ៉ាងត្រឹមត្រូវតែម្តង។ ញឹម នៅភូមិភាពពាយ័ព្យ រស់ ញឹម ជាដើម។ល។ ដូច្នេះខ្ញុំអាចនិយាយបាន ថាព័ត៌មាននេះគឺវាសុក្រឹតគ្រាន់បើដែរ។

[១៤:១៦:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ មានបញ្ហា! លោកស្រី! មន្ត្រីរដ្ឋបាលតុលាការរៀបចំនូវក្បាលមីក្រូហ្វូនឲ្យគាត់ឲ្យល្អ ងាកមកលិចបន្តិចមក ហើយឲ្យជិតគាត់បន្តិច កុំឲ្យជិតពេក តែជិតពេកវាខ្ទរហើយឆ្ងាយពេកវាស្តាប់មិនឮទេ។ ឲ្យងាកមកលិចបន្តិចទៀត! ទៀត!

សូមអញ្ជើញ! សូមអញ្ជើញបន្ត!

[១៤:១៧:២៦]

**លោក ស៊្វីវ ហេងឌ័រ៖**

បាទ ប្រហែលជាអាចឮគ្រាន់បើហើយ។

**សួរដោយលោក ឃីត រេយ៉ន៍រ៖**

**ស៖** បាទ ឥឡូវនេះគឺថាពាក់ព័ន្ធទៅនឹងលទ្ធភាពក្នុងការទទួលបានព័ត៌មានពីសេនានុព័ន្ធយោធាអមស្ថានទូតជប៉ុន អង្គការលេខ ឯកសារទាំងអស់នេះ។ តើលោកអាចមានលទ្ធភាពទទួលបានរបាយ-ការណ៍ដទៃទៀតទេ ឧទាហរណ៍លោកអាចជម្រាបបានទេ លោកមានលទ្ធភាពច្រើនជាងនេះទៀតទេដើម្បីទទួលបានឯកសារផ្សេងៗនោះ?

**លោក ស៊្វីវ ហេងឌ័រ៖**

**ឆ៖** ខ្ញុំពេលនោះមិនដឹងជាមានការប្រកួតប្រជែងគ្នារបៀបម៉េចទេ។ មានមនុស្សខ្លះនៅស្ថានទូតខ្លះហាក់បីដូចជាពេញចិត្តណាស់នូវអ្វីដែលខ្ញុំ -- ខ្ញុំដូចជាថាកណ្តុរគឺថាតែចូលទៅក្នុងបណ្ណាល័យចេះតែប្រមូលព័ត៌មានបណ្ណសារផ្សេងៗ។ ដូច្នេះ អ្នកដែលស្ថិតនៅក្នុងស្ថានទូត ដែលចាប់អារម្មណ៍អំពីប្រវត្តិ-

សាស្ត្រ គេហាក់មានសមានចិត្តជាមួយនឹងខ្ញុំ និងជាមួយអ្នកកាសែតដទៃទៀត។ សម្រាប់ខ្ញុំ ខ្ញុំទទួលបាន ហើយអ្នកខ្លះគឺអត់ទទួលបាន។ ខ្ញុំមិនដឹងអ្នកដទៃគេទទួលបានរបៀបម៉េច? ប៉ុន្តែខ្ញុំអត់ផ្ដល់ព័ត៌មាននេះ ទៅឲ្យមិត្តភក្តិ ឬសហការីខ្ញុំទេ។

[១៤:១៩:១៧]

**ស៖** លោកនិយាយអំពីការផ្សាយសំឡេងពីខ្លាំង ខ្ញុំចង់សួរលោកអំពីការផ្សាយវិទ្យុផ្សាយសំឡេង ពីខែឧសភា ១៩៧៣ រហូតទៅដល់ថ្ងៃទី១១ ខែមេសា ៧៥ ពេលលោកចាកចេញទៅ។ តើវិទ្យុផ្សាយ សំឡេងនេះផ្សព្វផ្សាយឡើងដោយ ឬក៏ក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា ឬក៏យ៉ាងម៉េច? កុំថាមើល ទៅទំនងហាក់ដូចជាខ្ញុំជាអ្នកនិពន្ធនាយកសារព័ត៌មានរបស់លោក តើលោកគ្រប់ដណ្ដប់លើរឿងអី? តើវិទ្យុហ្នឹង លោកស្ដាប់វិទ្យុដោយខ្លួនឯង ឬក៏ស្ដាប់ជាមួយអ្នកកាសែតដទៃ? តើការផ្សាយសំឡេងនៃ ដំណើររឿងរ៉ាវនេះ វាផ្សព្វផ្សាយសំឡេងដោយរបៀបណាដែរ?

**ឆ៖** ដោយសារតែវាជាផ្នែកមួយនៃការរៀនភាសា ខ្ញុំគឺ -- គេផ្សាយជាភាសាខ្មែរ គឺផ្សាយនៅ ពេលព្រឹក និងនៅថ្ងៃល្ងាច បាទ។ និយាយអំពីការប្រយុទ្ធនៅតាមសមរភូមិផ្សេងៗ គេរំដោះបានកន្លែង នេះ គេរឹបអូសបានកន្លែងនោះ ហើយពេលខ្លះនោះ វាមានការផ្សាយអំពីគោលនយោបាយផងដែរ។ ថា តើគោលនយោបាយនៅក្នុងតំបន់រំដោះហ្នឹង មានគោលនយោបាយបែបណា និងទិសដៅរបស់បដិវត្តន៍។ ពេលហ្នឹងមិនទាន់ហៅ ថាតើបដិវត្តន៍ហ្នឹងវាទៅជាយ៉ាងណា? ពេលហ្នឹង គឺថាខ្ញុំអានកាសែតហ្វីប៊ីស គឺ ថាស្រួលអាន ស្រួលងាយយល់ គឺថាមិនបាច់ប្រើវចនានុក្រមអីច្រើនដើម្បីពិនិត្យពាក្យពេចន៍នោះទេ។

[១៤:២១:៣៦]

**ស៖** ពេលដែលលោកស្ដាប់វិទ្យុផ្សាយសំឡេង ថាតើវាមានវិទ្យុស្ថានីយផ្សាយសំឡេង? ថាតើ អ្នកផ្សាយសំឡេងហ្នឹង តើលោកដឹងថាគេផ្សាយពីខាងណា ចេញពីទីតាំងណាអីដែរទេ?

**ឆ៖** គឺថាអត់ដឹងទេ គឺថាមិនច្បាស់លាស់។ គេថាជាការប្រព័ន្ធផ្សាយសំឡេងបន្តៗទី២ ជា សំឡេងរបស់រណសិរ្សរួបរួមជាតិកម្ពុជាចេញពីភ្នំពេញ។ ក្រោយពីខ្ញុំមកដល់ហ្នឹងគឺ -- ប៉ុន្តែកាលណោះ ខ្ញុំមិនបានតាមដានដឹងថា វាផ្សាយចេញពីកន្លែងណាឲ្យច្បាស់លាស់នោះទេ។ ពេលខ្លះ គឺថាការផ្សាយ ហ្នឹងហាក់ដូចជាតំណាងឲ្យ គឺថាយើងមានសំឡេង ខៀវ សំផន ឬក៏ក្នុងនាមឲ្យ ខៀវ សំផន។

**ស៖** ខ្ញុំចង់ពិចារណាអំពីការផ្សាយដោយ ខៀវ សំផន ឬក៏ក្នុងនាម ខៀវ សំផន។ តើលោកអាច ជម្រាបជូនតុលាការបានទេ? លោកនិយាយអំពីការប្រយុទ្ធសមរភូមិ គោលនយោបាយ តើលោកនៅចាំ

ទេ ពេលណានិយាយ ថាកាលណាមានការផ្សាយដោយ ខៀវ សំផន ឬក៏ក្នុងនាម ខៀវ សំផន តើកម្មវត្ថុនៃការផ្សាយហ្នឹង វាខុសពីអ្វីដែលលោកទើបនឹងបានលើកឡើង ឬក៏វាដូចគ្នា? សូមលោករៀបរាប់លម្អិតបន្តិច។

**ផ៖** និយាយដោយស្មោះទៅ គឺវាកំពុងតែច្របូកច្របល់ហើយ ពេលខ្ញុំអានហ្វីប៊ីសផង អានហើយទៀតៗ ក្នុងពេលផ្សព្វផ្សាយហ្នឹង គឺថាខ្ញុំពិបាកញែកមួយណាផ្សាយវិទ្យុផ្សាយសំឡេង មួយណាតាមរយៈកាសែតហ្វីប៊ីសនេះ ខ្ញុំមិនអាចញែកបានទេ។

[១៤:២៣:៥០]

**ស៖** ទាក់ទងទៅនឹងការផ្សាយសំឡេងដោយ ខៀវ សំផន ឬក្នុងនាម ខៀវ សំផន តើម្តងពីរដង ១០ដង ជាង១០ដង ឬក៏យ៉ាងណានោះ? លោកអាចជម្រាបបានទេ ការផ្សាយសំឡេងដែលលោកបានស្តាប់នោះ ប្រហែលជាលោកស្តាប់បានប៉ុន្មានដងដែរ?

**ផ៖** ប្រហែលជាច្រើនដងដែរ ប្រហែលជាជាង១០ដង។

**ស៖** ឥឡូវខ្ញុំនិយាយអំពី ប៉ុល ពត និង ខៀវ សំផន គឺឯកសារ E3/3169។ លោក ហេដឌ័រ សូមត្រឡប់ទៅឯកសារហ្នឹង ខ្ញុំសូមរំឭកម្តងទៀត គឺឯកសារលេខ៣ ឧបសម្ព័ន្ធ១។ យើងកំពុងតែនៅត្រង់ទំព័រ៨។ ERN ដូចគ្នា ដូចដែលខ្ញុំបានជម្រាបជូនលើកមុនអ៊ីចឹង។ ខ្ញុំសូមសួរសំណួរជាក់លាក់មួយនៅថ្ងៃទី១ ខែមេសា ខៀវ សំផន ផ្សព្វផ្សាយសំឡេងតាមរយៈវិទ្យុកុម្មុយនីស្តកម្ពុជា ដែលនិយាយអំពី ខៀវ សំផន ធ្វើជាអធិបតីភាពនៅក្នុងសមាជបក្សលើកទី២ តើផ្សាយតាមវិទ្យុផ្សាយសំឡេងហ្នឹង ឬក៏តាមហ្វីប៊ីស ឬក៏តាមអ្វីដែរ លោកនៅចាំទេ?

[១៤:២៥:៣២]

**ផ៖** នេះ គឺជាចំណុចមួយដ៏ធំនៅពេលនុ៎ង ខ្ញុំចាំថា ពេលដែលខ្ញុំចាំ កាសែតហ្វីប៊ីសដែលមានពណ៌ខៀវ ដែលនិយាយអំពីសមាជហ្នឹង ខ្ញុំអង្គុយនៅក្នុងស្ថានទូតអាមេរិក ហើយអានកាសែតហ្វីប៊ីសហ្នឹង។

**ស៖** បាទ នៅឯកសារដដែល ទំព័រដដែលគឺ E3/3169 លោកចាប់ផ្តើមនិយាយអំពី ដែលកាសែតនិយាយអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និយាយអំពីខ្មាំងដែលទទួលបរាជ័យ ហើយមន្ត្រីរបបសាធារណរដ្ឋខ្មែរមួយចំនួន ខ្ញុំមិនដឹងថា ខ្ញុំត្រូវអានទៀត ដោយសារថា ទំព័របន្ទាប់ភាគីច្រើនវាពាក់ព័ន្ធទៅនឹងចម្លើយសារភាព ប៉ុន្តែនៅខាងលើនៃទំព័រ ERN អង់គ្លេស 008773 *(ស៊ីក)*, បារាំង

0022072 *(ស៊ីក)*, ខ្មែរ 00711379។

[១៤:២៦:៥៥]

នៅត្រង់ប្រធានបទនេះ លោកនិយាយថា ក៏មានភស្តុតាងឯកសារពាក់ព័ន្ធទៅនឹងការសម្លាប់មនុស្សផងដែរ គឺសម្លាប់មនុស្សនៅអង្គភាព គឺអង្គភាពយោធា ដែលមកពីភូមិភាគ បាទ គឺមកពីកងពលលេខ៧០៣ គឺភូមិភាគពិសេស។ នេះគឺជាបញ្ជាការ ចុះហត្ថលេខាដោយលេខាកងពល ដើម្បីសម្លាប់ប្រជាជន ភាគច្រើនគឺត្រូវសម្លាប់មន្ត្រីកងទ័ពសាធារណរដ្ឋខ្មែរ ដែលស្ថិតនៅក្នុងការឃុំខ្លួនរបស់កងពលចុះថ្ងៃទី០៤ ខែមិថុនា ៧៥ ដែលលើកឡើងថា "មនុស្សទាំង១៧នាក់នេះ ត្រូវបានបក្សទទួលបាន ហើយបក្សបានសម្រេចថា ត្រូវតែសម្លាប់អ្នកទាំងនេះចោល។ ដូច្នេះ ស្នើសុំឲ្យសមមិត្តទាំងអស់អនុវត្តគោល-នយោបាយរបស់បក្សនេះ"។ បញ្ចប់ការដកស្រង់។

*ហ្វូតណូត* គឺលេខយោងឈ្មោះ ពីន សេចក្ដីសម្រេចថ្ងៃទី០៤ មិថុនា ៧៥ ហើយឯកសារមួយចម្លង គឺលោក ដេវីដ ហក បានផ្ដល់ទៅឲ្យលោក។ តើលោកទទួលបានឯកសារដោយរបៀបណា? ហើយលោកជម្រាបផងថា ដេវីដ ហក ហ្នឹង គឺជាអ្នកណា?

[១៤:២៨:២១]

**ឆៈ** ដេវីដ ហក ជានាយកនៃអង្គការលើកលែងទោសអន្តរជាតិ – *អាមណេសធី អ៊ីនធើណា-ស្យូណាល* – របស់សហរដ្ឋអាមេរិក គាត់ជាជនជាតិអាមរិក។ ក្រោយពីចាកចេញពីតំណែងនេះទៅ គាត់មកអាស៊ីអាគ្នេយ៍ គាត់ធ្វើឲ្យអង្គការមួយផ្នែកខាងសាសនាដែលមានទីតាំងនៅប្រទេសថៃ ហើយរៀបចងក្រងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ និយាយថា "គណៈកម្មការចងក្រងឯកសារពីប្រទេសកម្ពុជា" ទិសដៅនោះគឺដើម្បីព្យាយាមប្រមូលភស្តុតាង -- អាហ្នឹងគេអាចនិយាយថាអ៊ីចឹងបាន -- ដើម្បីគឺថាចាត់ការ ថាតើវាជាមួយប្រៀបធៀបកតិកាសញ្ញាស្ដីអំពីអំពើប្រល័យពូជសាសន៍ដើម្បីធ្វើជារបាយការណ៍ពីរឿងនេះឡើង។ ហើយគាត់បានមកទស្សនកិច្ចភ្នំពេញ នៅ -- ហើយក្រោយមក មកមើលទួលស្លែង – សារមន្ទីរទួលស្លែង – នៅឆ្នាំ១៩៨០។ ឯកសារនេះ គឺថាត្រូវបានឈ្មោះ -- គេបានផ្ដល់ទៅឲ្យគាត់តាមរយៈអ្នកគ្រប់គ្រងនៅសារមន្ទីរទួលស្លែងបាទ។

[១៤:២៩:៥៣]

**សៈ** សូមអរគុណ។ ទំព័រដដែលបារាំងដូចគ្នា "ខៀវ សំផន ស្ថិតនៅក្រោមអំណាចរបស់ ប៉ុល ពត នៅក្នុងខែឧសភា ៧៥ បក្សកុម្មុយនីស្តកម្ពុជាបានបើកសមាជ ដែលបញ្ជាក់អំពីសមាជិកភាពរបស់

ខៀវ សំផន នៅក្នុងគណៈមជ្ឈិម ដែលពេលនោះគឺថាតើគណៈមជ្ឈិមមានអំណាចដោយរបៀបណា? ប៉ុន្តែគេយល់ឃើញថា គាត់មិនបានទទួលបានសមាជិកភាពមកដល់គណៈអចិន្ត្រៃយ៍ទេ នៅពេលបក្សនៅកាន់អំណាច។ បើទោះបីជាសមាសភាពពីប្រាំពីរ ទៅ ប្រាំបួននាក់ចន្លោះពី៧៥ ទៅដល់៧៨ នេះគឺថាមិនបានដឹងឲ្យច្បាស់លាស់ឡើយនោះទេ។ ខៀវ សំផន មិនដែលបានអ្នកណាដឹងថាស្ថិតនៅក្នុងសមាជិកនៃគណៈអចិន្ត្រៃយ៍នេះទេ។ ក៏ប៉ុន្តែកំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ដែលបានធ្វើឡើងនៅឆ្នាំ១៩៧៥ ដល់៧៦ បង្ហាញឲ្យឃើញថាគាត់បានចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ជាទៀងទាត់”។

លេខយោងជើងទំព័រនេះ គឺ៣៣ លេខយោង៣៣ ដែលលោកលើកឡើងថាកំណត់ហេតុគណៈអចិន្ត្រៃយ៍។ ហើយខ្ញុំនឹងផ្ដល់កាលបរិច្ឆេទ គឺថ្ងៃទី០២ វិច្ឆិកា ១៩៧៥, ២២ កុម្ភៈ ១៩៧៦, ថ្ងៃ១១ មីនា ១៩៧៦, ១៧ ឧសភា ៧៦, ០៣ ឧសភា ៧៦ កិច្ចប្រជុំទាំងអស់នេះគឺថាមានវត្ត -- បង្ហាញពីវត្តមាន ខៀវ សំផន គឺលោកបានទទួលឯកសារនេះពី ដេវីដ ឆេនដ៍ល័រ។

[១៤:៣១:៣៧]

លោក ហេដឌ័រ ខ្ញុំចង់សួរថានៅក្នុងដំណាក់កាលនេះ គឺពេលដែលលោកសរសេរឯកសារនេះគឺនៅក្នុង៩១។ លោកនិយាយថា “មានតែកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ប្រាំទេ បង្ហាញអំពី ខៀវ សំផន វត្តមាន ខៀវ សំផន ក្នុងកិច្ចប្រជុំប្រាំលើកនេះ”។ នៅពេលលោកសរសេរហ្នឹង លោកដែលឃើញឯកសារនៃ គឺកំណត់ហេតុគណៈអចិន្ត្រៃយ៍នេះដែលលោកយោងនៅក្នុងលេខយោងជើងទំព័រ៣៣នេះទេ?

**ឆ៖** ខ្ញុំថាខ្ញុំស្មាន ខ្ញុំគិតថាកំណត់ហេតុនេះដែល ដេវីដ ឆេនដ៍ល័រ បានផ្ដល់មកឲ្យខ្ញុំ។ ហើយខ្ញុំសូមបន្ថែមបន្តិចបើអាចធ្វើទៅបាន គឺផ្នែកនៅត្រង់ខែឧសភា ៧៥ នោះ តាមដែលខ្ញុំចាំបន្តបន្ទាប់អ្វីដែលកើតឡើងនៅខែឧសភា ៧៥ គឺមានសមាជកិច្ចប្រជុំរបស់គណៈមជ្ឈិម ខៀវ សំផន ពេលហ្នឹងមិនទាន់បានដំឡើងនោះទេ រហូតទៅដល់ខែមករា ឆ្នាំ១៩៧៦ ឯណោះ។ មិនមានវាអ្វីគួរឲ្យភ្ញាក់ផ្អើលទេ បើសិនណាវាខុសនោះ។

[១៤:៣៣:២០]

**ស៖** ហើយបន្ទាប់មកលោកនិយាយថា គាត់មិនមែនជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍ ឬក៏សមាជិកគណៈអចិន្ត្រៃយ៍ តែចូលរួមប្រជុំជាទៀងទាត់។ ការចាត់តាំងនេះគឺថាវាកើតមានឡើងក្រោយពីការមានការសម្លាប់សមាជិកគណៈអចិន្ត្រៃយ៍ ដែលត្រូវចោទប្រកាន់ថាជាភ្នាក់ងារយួន ដោយសារថា ប៉ុល ពត បានដឹង ឬក៏សង្ស័យថា ពួកគេប្រឆាំងជាមួយគោលនយោបាយ និងភាពដឹកនាំរបស់គាត់។

នៅត្រង់លេខយោង៣៤ លោកនិយាយអំពីឈ្មោះមនុស្សដែលយោងទៅនេះ។ តើនេះត្រឹមត្រូវឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តាមការសិក្សាស្រាវជ្រាវរបស់លោក កិច្ចសម្ភាសន៍របស់លោកពិចារណាទៅលើឯកសារទាំងនេះ តើលោកបានដឹងថាមានអ្នកដទៃទៀត ដែលជាសមាជិកគណៈមជ្ឈិមបានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ជាញឹកញាប់ ឬក៏ជាទៀងទាត់ដែរឬទេ?

**ឆ៖** --

[១៤:៣៤:៤៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយហេតុថាការបញ្ជាក់អំពីការបានដឹងរបស់សាក្សីរូបនេះ អំពីវត្តមានរបស់សមាជិកគណៈមជ្ឈិមដទៃទៀតចូលរួមប្រជុំ វាជាផ្នែកមួយនៃការស្រាវជ្រាវបានអាចរកឃើញ។ មិនមែនសាក្សីធម្មតាអាចបង្ហាញភស្តុតាងទាក់ទងនឹងចំណុចនេះបានទេ។ ដូច្នេះក្នុងឋានៈលោកជាសាក្សី មិនអាចធ្វើការបំភ្លឺទាក់ទងទៅនឹងលក្ខណៈបែបជាជំនាញបែបនេះឡើយ។ បាទ សូមជំទាស់ សូមអរគុណ។

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំយល់ហើយលោកមេធាវី ដែលលោកជំទាស់ ខ្ញុំនឹងរៀបចំឃ្លាសំណួរខ្ញុំឡើងវិញបាទ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ផ្អែកតាមប្រភពអង្គហេតុ គឺព័ត៌មានអង្គហេតុជាហេតុការណ៍ដែលកើតឡើង តើមានព័ត៌មានបែបនេះឬទេ ដែលចង្អុលបង្ហាញថា បុគ្គលផ្សេងៗទៀតដែលសមាជិកគណៈមជ្ឈិមបានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ផ្អែកលើគោលការណ៍ជាទៀងទាត់ ឬញឹកញាប់នោះ? លោកសាក្សីអាចឆ្លើយបានទេ?

[១៤:៣៦:២៥]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ម្នាក់ដែលខ្ញុំនឹកឃើញនោះគឺ សឿ វ៉ាស៊ី ហៅថា ឌឿន ក្រៅពីគាត់នោះខ្ញុំមិនអាចនឹកឃើញភ្លាមៗទេនៅពេលនេះ។

**ស៖** យើងនឹងនិយាយពី ឌឿន នៅពេលបន្ទាប់ទៀត។ នៅទំព័រដដែល ERN ដដែលដើម្បីកំណត់ត្រាតុលាការ E3/319។ លោក ហេដឌ័រ តើលោកមានទំព័រនេះទេ E3/3169 គឺទំព័រ១០? បាទ នៅខាងក្រោមទំព័រនេះបាទ។ "ក្នុងខណៈដែល ខៀវ សំផន ក្រោយមកគាត់ទទួលស្គាល់ខ្លួនឯងថា ការជំទាស់ ប៉ុល ពត គឺកាន់តែខ្លាំង ទោះបីជានៅក្នុងគណៈមជ្ឈិមក៏ដោយ។ នៅក្នុងបទសម្ភាសន៍ជាមួយអ្នកនិពន្ធនៅថ្ងៃទី០៤ សីហា ឆ្នាំ១៩៨១ គាត់អះអាងថាភ្នាក់ងារខ្មែរដែលមកពីវៀតណាមបានចូលទៅក្នុងគណៈមជ្ឈិម មិនបានពាក់កណ្តាលនៃសមាជិកទេ ប៉ុន្តែនៅគណៈអចិន្ត្រៃយ៍ គឺអាចបានដល់ពាក់កណ្តាល"។ សំណួរទី១ តើចំណុចនេះលោកបានសរសេរក្នុងសៀវភៅរបស់លោកពីចំណុចនេះទេ? បើសិនជាលោកឆ្លើយយ៉ាងណាខ្ញុំនឹងសួរបន្តទៅទៀត។

[១៤:៣៨:១០]

**ឆ៖** បាទ ពិតជាចំណុចដែលខ្ញុំសរសេរក្នុងសៀវភៅខ្ញុំមែន។

**ស៖** ឯកសារដដែលត្រង់*ថេប*៦--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សំណួរសូមឲ្យបំភ្លឺនៅក្នុងឯកសារ គឺថាក្នុងទំព័រ៩ដែលបានដកស្រង់ គ្រាន់តែចង់ជម្រាបកុំឲ្យមានការភ័ន្តច្រឡំ។ ខ្ញុំមាននៅក្នុងមុខខ្ញុំគឺ E3/319, ERN 00279 *(ស៊ីក)* ប៉ុន្តែខាងក្រោមទំព័រ៩ទេ។

[១៤:៣៨:៥៨]

**លោក ឃីត រេយ៍ន័រ៖**

គឺជាឯកសារដដែល ប៉ុន្តែគេហៅថា E --បាទជាឯកសារ E3/3169 ERN ដែលខ្ញុំនិយាយគឺអង់គ្លេសគឺ00087774។ ខ្ញុំគិតថាលោកមេធាវីអាចចង្អុលបង្ហាញឲ្យគាត់មើលឯកសារមួយដែលឯកសារ

ដែលបោះពុម្ពផ្សាយ ដែល D366/7.1.14 ជាអត្ថបទពីរនៅក្នុង*ខេស-មេប* ហើយនិង*ខេស-ហ្វាល*។ ជាអត្ថបទបោះពុម្ពផ្សាយ ដែលមានពណ៌ខ្មៅជាង ហើយអត្ថបទដែលល្អជាង គឺពណ៌ស-ខ្មៅច្បាស់ដែលមាននៅក្នុងឯកសារ E3/3169។ បាទ តើ--

**លោក វ៉ិចទ័រ កូប៉េះ**

បាទ ERN ដែលខ្ញុំមានគឺ 00002754 គឺខុសគ្នា ប៉ុន្តែខ្ញុំឃើញថាទំព័រនេះគឺជាទំព័រ៩ ជាផ្នែកនៃអត្ថបទសារព័ត៌មានហ្នឹងនោះឯង។ នេះអាចចង្អុលបង្ហាញថា អាចនឹងមាន *វើសិន* គឺថាមានច្បាប់ដើមមួយទៀត មុននឹងមានអាច្បាប់ក្រោយដែលលោកយកមកយោងនេះ ឬដូចម្ដេច?

[១៤:៤០:២៤]

**លោក ឃីត រេយ៍ន័រ៖**

គឺមានឯកសារពីរនៅក្នុងសំណុំរឿង គឺE3/3169 គឺរូបភាពបែបនេះ បាទ។ ខ្ញុំគិតថា មេធាវីមានកូពីនេះ ហើយអត្ថបទនៅខាងស្ដាំដៃខ្ញុំនៅក្នុងសំណុំរឿង គឺអានេះងាយស្រួលអានជាងដែលពណ៌ខ្មៅនេះ ពិបាកអានជាងបន្តិច។ ខ្ញុំនឹងប្រាកដថា កុំឲ្យច្រឡំ ខ្ញុំនឹងឲ្យលេខ ERNគ្រប់ទំព័រ។ ហើយខ្ញុំនឹងព្យាយាមជួយលោកឲ្យច្រើនបំផុតដែលអាចធ្វើទៅបាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក។ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ីវ ហេងឌ័រ។

សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកលោកប្រធាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីអត្ថបទវាយអង្គុលីលេខ គឺ D3/66/7.1.14 ហើយយើងមានអត្ថបទវាយជាអង្គុលីលេខ ហើយយើងមានការថតចម្លងផ្ទាល់ពីស្នាដៃដែលបានបោះពុម្ពផ្សាយ។ លោកហេងឌ័រ ខ្ញុំចង់សួរលោក តើឯកសារដែលយើងពិនិត្យមើល គឺជាអត្ថបទវាយអង្គុលីលេខ តើជាអ្វីដែលលោកផលិត ឬក៏សាកលវិទ្យាល័យបានផលិត? តើលោកដឹង អាចប្រាប់បានទេថាប្រវត្តិឯកសារនេះដូចម្តេច?

[១៥:០៣:៣៣]

**លោក ស៊ីវ ហេងឌ័រ៖**

**ឆ៖** ខ្ញុំមិនដឹងអំពីអ្វីដែលទាក់ទងទៅនឹងឯកសារដែលលោកធ្វើការទេ។ ខ្ញុំដឹងអំពីឯកសារដែលថតចម្លងអំពីច្បាប់ដើមនៅអូស្ត្រាលី។ គេអាចវាយអង្គុលីលេខឡើងវិញ ការកំណត់ជាទម្រង់ទំព័រហ្នឹងគឺខុស គឺថា ហើយមានទំព័រទី១ នៅទំព័រដើម ប៉ុន្តែច្បាប់ផ្សេង គឺថា គឺអត់ដូចគ្នាទេ គេចាប់ផ្តើមពីលេខ ២ ទៅផ្សេងទៀតនោះ។

**ស៖** សូមអរគុណ។ ខ្ញុំបានសួរសំណួរលោកមួយ សួរអំពីសៀវភៅដែលលោកនិយាយអំពីសួរជាមួយអ្នកនិពន្ធនៅឆ្នាំ១៩៨០ ដែលថា ភ្នាក់ងារខ្មែរដែលមកពីវៀតណាមបានចូលទៅក្នុងគណៈមជ្ឈិមមិនបានពាក់កណ្តាលទេ ប៉ុន្តែនៅក្នុងគណៈអចិន្ត្រៃយ៍ជិតបានពាក់កណ្តាល។ នេះជាខ្លឹមសារដែលនៅក្នុងសៀវភៅរបស់លោក អ្វីដែលចង់ឲ្យខ្ញុំ -- ខ្ញុំចង់ឲ្យលោកហ្នឹង គឺថាឯកសារ៣ *ថេប*១។ ឥឡូវនេះ ឯកសារ E3/203 ជាប្រតិចារឹកនៃសំណួរនិងចម្លើយនៅក្នុងបទសម្ភាសន៍ ដែលលោកបានសម្ភាសជា

មួយ ខៀវ សំផន ថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៨០។ តើលោកបញ្ជាក់ថាលោកបានទទួលឯកសារក្នុងដៃហើយឬនៅ មើលឃើញហើយឬនៅ?

**ឆ៖** បាទ។

[១៥:០៥:៣១]

**ស៖** ឥឡូវនេះខ្ញុំទៅ ឲ្យលោកទៅមើលទំព័រ១៩ នៃឯកសារនេះ អង់គ្លេស ERN 00424014, ខ្មែរ 00434233 នោះជាបារាំងទេបាទ ហើយខ្មែរ 00385410 ដល់ 11។ នៅទីនេះលោកបាននិយាយហើយ ខៀវ សំផន បានឆ្លើយអំពីភ្នាក់ងារវៀតណាម ហើយបាននិយាយបំផ្លាញដោយសម្ងាត់នូវមាគ៌ាបក្ស។ នេះជាសំណួររបស់លោកសួរទៅ ខៀវ សំផន៖ “នៅឆ្នាំ១៩៧៥ តើភាគរយនៃអ្នកទាំងនោះនៅក្នុងថ្នាក់អ្នកជាន់ខ្ពស់របស់បក្ស នៅក្នុងគណៈមជ្ឈិម និងនៅក្នុងគណៈអចិន្ត្រៃយ៍? ចម្លើយ៖ មានច្រើន។ សំណួរ៖ ពាក់កណ្តាល? ចម្លើយ៖ តិចជាងពាក់កណ្តាលនៅគណៈមជ្ឈិម ប៉ុន្តែជិតពាក់កណ្តាលនៅក្នុងគណៈអចិន្ត្រៃយ៍។ សំណួរពីលោក៖ ជាងពាក់កណ្តាល? តើអ្នកណាខ្លះ? ចម្លើយ៖ ខ្ញុំមិនចង់បញ្ជាក់ពីបញ្ហានេះទេ មិនទាន់ដល់ពេលដែលត្រូវពិភាក្សាលម្អិតពីរឿងនេះ អំពីអ្វីបានឆ្លងកាត់ទេ ដោយសារយើងមានការរស់ជាមួយសង្គ្រាមក្នុងយកឈ្នះលើវៀតណាម។ យើងរស់ជាមួយនឹងមហាជោគជ័យរបស់យើង”។ តើអ៊ីចឹងលោកនៅចាំថាតើនេះជាការកត់ត្រាត្រឹមត្រូវសំណួរចម្លើយ ដែលលោកបានសម្ភាសលោក ខៀវ សំផន កាលនោះទេ?

[១៥:០៧:២៧]

**ឆ៖** បាទ នេះជាការបកប្រែ គឺខុសគ្នាតែបន្តិចបន្តួច ប៉ុន្តែអត្ថន័យគឺដូចគ្នា។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់ទៅឯកសារដែល D366/7.1.14 លោកមេធាវី កូប៉េ ប្រហែលជាខ្ញុំអាចយោងទៅលេខយោងទំព័រ គឺឯកសារនៅក្នុងឯកសារយោង៣៧ នៅក្នុងលេខយោងនោះ ៣៩ និង ៤០។ ខ្ញុំនឹងសង្ខេបពីខ្លឹមសារទូទៅ ប៉ុន្តែនឹងធ្វើការយោងជាក់លាក់ទៅនឹងឯកសារមុនហ្នឹងតណ្ឌួត៣៧ មុនលេខយោង៣៧។

លោកបាននិយាយជាទូទៅអំពី ខៀវ សំផន នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាគឺនៅទំព័រ ១១ នៃឯកសារនោះ ហើយនិងរណសិរ្សរួបរួមជាតិកម្ពុជាគឺថា អំពីការបំផ្លាញរណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិនោះ គឺមានដំណាក់កាលបី។ គឺថាទី១ គឺអនុម័តរដ្ឋធម្មនុញ្ញគឺដែលចុះកាលបរិច្ឆេទឆ្នាំ៧០។ ទី២ ដែលគេចាត់ទុកនេះគឺការបោះឆ្នោតជ្រើសរើសសភា ដើម្បីជំនួសសមាជិករណសិរ្ស

រួបរួមជាតិកម្ពុជាដែលលោក ខៀវ សំផន នៅក្នុងនោះដែលជាស្ថាប័នធ្វើសេចក្ដីសម្រេចនយោបាយនៅក្នុងចលនាបដិវត្តន៍។ ទី៣ គឺការបង្កើតរដ្ឋាភិបាលថ្មី ហើយនិងស្ថាប័នរដ្ឋដើម្បីជំនួសរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។

[១៥:០៩:៣០]

ខ្ញុំចង់សួរចំណុចទី២ និយាយអំពីការបោះឆ្នោត។ ខ្ញុំសូមមើលឯកសារដដែលទៅដល់*ថេប*២។ នេះជាឯកសារ E3/390 ជាប្រតិចារឹកនៃបទសម្ភាសន៍របស់លោកជាមួយ ម៉ាត់ លី យើងបានយោងទៅរកឯកសារនេះនៅព្រឹកមិញនេះក្នុងតុលាការ។ ដូច្នេះយើងពិនិត្យមើលទំព័រ២៨ នៃឯកសារនេះ អង់គ្លេស 00436873 ខ្ញុំមិនមាន ERN ជាភាសាខ្មែរទេ ខ្ញុំចង់ឲ្យសហសេវិកខ្ញុំនឹងជួយពិនិត្យមើល។ ខ្ញុំសូមអនុញ្ញាតពិនិត្យ១នាទីបាទ។

*(សម្រាករយៈពេលខ្លី)*

គឺមានជាភាសាខ្មែរ ហើយនិងបង្ហាញនៅក្នុងអេក្រង់ជាភាសាខ្មែរ ក្នុងគោលបំណងរបស់យើង លោក ហេងឆ័រ ទំព័រ២៨។ និយាយអំពី ប្រហែលជាមួយភាគបីនៅទំព័រ នៅត្រង់១៥០ប្រយោគ គឺថាវិធីសាស្ត្រនៃការបោះឆ្នោតរបស់យើង លោកឃើញហើយ នេះជាសម្ដីរបស់ ម៉ាត់ លី។ "វិធីសាស្ត្រនៃការបោះឆ្នោតរបស់ខ្ញុំ មណ្ឌលនីមួយៗមានបោះឆ្នោតមួយ គឺខ្ញុំ ម៉ាត់ លី កោះហៅមនុស្សឲ្យមកបោះឆ្នោត បើគេមិនពេញចិត្តសូមបំបាត់ចោលចេញ។ ខ្ញុំសូមប្រាប់ គឺថាមិនមានអ្នកណាមានប៊ិកនៅនឹងហោប៉ៅទេក្រៅពីកម្មាភិបាល។ សួរបងដែលមកជម្លៀសពីភ្នំពេញ--

**ប្រធានអង្គជំនុំ៖**

លោកៗតំណាងសហព្រះរាជអាជ្ញាផ្អាកបន្តិចសិន! មានបញ្ហាបកប្រែភាសាបារាំង។

[១៥:១២:០០]

*(មានបញ្ហាបច្ចេកទេស)*

[១៥:១២:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា! សូមរៀបចំសំណួរចុងក្រោយរបស់លោកសាជាថ្មីម្ដងទៀត ព្រោះអំមិញមានបញ្ហាបកប្រែភាសាបារាំង មិនមានការបកប្រែជាភាសាបារាំង។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ហេងឌ័រ ផ្នែកដែលយើងនឹងចាប់ផ្ដើម "ប៉ុន្ដែវិធីសាស្ត្រនៃការបោះឆ្នោតរបស់ខ្ញុំ" តើលោកមានទំព័រហ្នឹងទេ?

**លោក ស៊ួរ ហេងឌ័រ៖**

**ឆ៖** បាទ។

**ស៖** "វិធីនៃការបោះឆ្នោតខ្ញុំសូមប្រាប់អ្នក មណ្ឌលមួយៗមានសន្លឹកឆ្នោតតែមួយ ជាឧទាហរណ៍ ខ្ញុំដូចជា ម៉ាត់ លី នេះគេហៅមនុស្សឲ្យមកបោះឆ្នោត។ និយាយប្រាប់ថា បើសិនគេមិនពេញចិត្តត្រូវតែលុបចោលទៅ។ ខ្ញុំសូមប្រាប់អ្នកថា គ្មានអ្នកណាក្រៅពីកម្មាភិបាលដែលមានប៊ិកធំនៅនឹងហោប៉ៅទេ នៅក្នុងសម័យនោះនោះ។ អ្នកណាម្នាក់សួរបងប្អូនដែលមកពីភ្នំពេញទេ? ប្រសិនបើឃើញមួយគេនឹងលាក់ខ្លួន ពីព្រោះថាគេអាចនឹងជាអ្នកមិនចេះអក្សរ គេត្រូវលាក់។ គឺថាអ្នកណា ដែលពាក់វ៉ែនតា គេខ្លាចគេហៅថាបញ្ញវន្ត គេអាចនឹងយកទៅសម្លាប់អស់។ គេថាបញ្ញវន្តជាប់ឥទ្ធិពលចក្រពត្តិនិយម ជាពិសេសគេថាការបោះឆ្នោតគឺថាចូលទៅម្នាក់ ប្រជាជនបោះឆ្នោតគេគ្រាន់តែអាចឈរមើល។ ដោយសារមិនមានរូបថតនៅលើសន្លឹកឆ្នោត គេគ្រាន់តែសរសេរថា ម៉ាត់ លី។ គេឲ្យតុមួយមកខ្ញុំអង្គុយ ហើយគេឲ្យមនុស្សបោះឆ្នោត។ គេមើលមុខខ្ញុំ ហើយដាក់ទៅក្នុងប្រអប់សំបុត្រ ហើយក៏ត្រឡប់ ហើយមិនមានអ្នកណាម្នាក់ហ៊ានគូសឈ្មោះរបស់ខ្ញុំចោលទេ"។ តើលោកអាចពន្យល់បានទេ តើ ម៉ាត់ លី ពិតជាបាននិយាយអ៊ីចឹងនៅក្នុងបទសម្ភាសន៍ដែរឬទេ?

[១៥:១៥:០៣]

**ឆ៖** បាទ។

**ស៖** ឥឡូវនេះយើងចូលទៅអំពីសភា។ ម៉ាត់ លី ក៏គាត់និយាយបន្ត៖ "ដូច្នេះបន្ទាប់ពីការបោះឆ្នោតនៅថ្ងៃទី១១ ឧសភា គេបានកោះខ្ញុំទៅកិច្ចប្រជុំ ហើយខ្ញុំចេញពីស្រុក ខ្ញុំនៅក្នុងកិច្ចប្រជុំនៅថ្ងៃទី១២ នៅថ្ងៃទី១៣ ខ្ញុំត្រឡប់មកវិញ។ មកហ្នឹងគេណែនាំឲ្យប្រាប់ថា សភារបស់បក្ស ហើយឥឡូវធ្វើការ ត្រូវធ្វើឲ្យបក្សធ្វើ។ ប៉ុន្ដែសភាយើងនេះ គឺមានច្បាប់ និងទម្លាប់អ៊ីចឹង ដើម្បីឲ្យអន្តរជាតិគេដឹងថា យើងមានច្បាប់ មានទម្លាប់ មានសភាអ៊ីចឹងត្រឹមត្រូវដូចគេដែរ។ អាហ្នឹងគេប្រាប់យើងអ៊ីចឹង។ ប៉ុន្ដែខ្លឹមសារអង្គប្រជុំនោះ គឺមិននិយាយអំពីចាត់តាំងរដ្ឋមន្ត្រី ក្រុមប្រឹក្សារដ្ឋមន្ត្រី ឬក៏ក្រុមប្រឹក្សារដ្ឋទេ។ និយាយពីវិធីចាត់តាំងសភា។ សភាមានចាត់តាំងក្នុង២៥០នាក់ហ្នឹង គេថាមានគណៈអចិន្ត្រៃយ៍មាន១០នាក់។

១០នាក់មានប្រធានមួយគឺ នួន ជា ហ្នឹងឯង។ ហើយមានអនុប្រធានពីរ ហើយក្រៅពីហ្នឹងសុទ្ធតែសមាជិក។ ក្នុងហ្នឹងខ្ញុំជាសមាជិកអចិន្ត្រៃយ៍ម្នាក់ដែរ។ សមាជិកទី៨ គឺខ្ញុំ។ អ៊ីចឹងតើប្រជុំហ្នឹងពិភាក្សាអំពីអ្វី? គឺមិនមានពិភាក្សាអ្វីទេ គេគ្រាន់តែអាន ហើយយើងគ្រាន់តែលើកដៃ។ ជាឧទាហរណ៍ គេអានអំពីការចាត់តាំង មួយ ពីរ បី។ អ្នកណាជាប្រធាន អ្នកណាជាអនុប្រធាន អ្នកណាសមាជិក ហើយយើងក៏ទះដៃ។ រីឯរដ្ឋធម្មនុញ្ញតែមួយភ្លែតទេ គេសរសេរល្អណាស់។ រដ្ឋធម្មនុញ្ញគេហ្នឹង ជាឧទាហរណ៍ គេសរសេរថា ប្រជាជនមានសិទ្ធិជឿសាសនា ឬមិនជឿសាសនាក៏បាន តែហាមដាច់ខាត មិនឲ្យជឿសាសនាប្រតិកិរិយា។ គេសរសេរអ៊ីចឹង ប៉ុន្តែធាតុពិតមុននឹងការប្រជុំសភាហ្នឹងគេលុបសាសនាអស់ទៅហើយ"។

[១៥:១៧:៣៣]

ហើយគាត់និយាយបន្តិចទៀតខាងក្រោម "ហើយពួកអ្នកកាន់តំណែងធំៗមាន ប៉ុល ពត, មាន ហ៊ូ នឹម គឺជារដ្ឋមន្ត្រីឃោសនាការ និងវប្បធម៌ ហើយគេចាត់តាំង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ។ ហើយ សោ ភឹម គឺជាអនុប្រធានទី១។ រស់ ញឹម នៅដែលគេហៅថាបស្ចិមអ៊ីចឹង។ តើត្រូវទេគឺថាពាយ័ព្យ? ឆ្លើយ៖ អនុប្រធានទី២ ហើយគេសម្លាប់ចោលទាំងពីរនាក់។ អ៊ីចឹងហើយបានថាទាំងអស់នេះគ្មានមុខ។ គេបង្ហាញមុខ យើងគ្រាន់តែបោះលើកដៃ ហើយក៏យកតែម្តង។ អ៊ីចឹងគឺសភាប្រជុំតែ២ម៉ោងប៉ុណ្ណោះ។ បាទ (ស្តាប់មិនបាន) ថ្នាក់ដឹកនាំប្រទេស មានបង ជា ស៊ីម។ចាប់ផ្តើមម៉ោងប្រាំពីរកន្លះ ហើយចប់ម៉ោងប្រាំបួនកន្លះ។ ចប់ហើយ ខ្ញុំបានពាក់អាវធំនឹងគេបាន២ម៉ោង អាវធំ ក្រវាត់ក។ ចេញមកវិញគេឲ្យដោះនៅក្រសួងការបរទេស គេឲ្យដោះឲ្យគេវិញ ស្លៀកខោអាវខ្មៅទៅស្រុកវិញ។ ប៉ុន្តែ តើអ្នកណាជាអ្នកផ្សព្វផ្សាយយ៉ាងម៉េច? នៅថ្ងៃទី១១ មិនទាន់មានប្រជុំទេ។ ថ្ងៃទី១២ ប្រជុំពេលព្រឹកថ្ងៃ១៣ ត្រឡប់ទៅស្រុកវិញ។ ព្រលឹមឡើងនៅថ្ងៃ១៤ គេប្រកាសតាមវិទ្យុថា សភាបានធ្វើយ៉ាងមមាញឹក ពិភាក្សាលម្អិតលម្អន់ពីច្បាប់ទម្លាប់អី ហើយតាំងគណៈរដ្ឋមន្ត្រីណារយៈកាល៣ថ្ងៃ"។

សំណួរ តើនេះជាខ្លឹមសារដែលបានកត់ត្រាតាមសម្តី ម៉ាត់ លី ដែលប្រាប់លោកដែរឬទេខ្លឹមសារទាំងនេះ?

[១៥:១៩:៥១]

**ឆ៖** បាទ។

**ស៖** លោក ហេងឌ័រ ទាក់ទងទៅនឹងព័ត៌មានជាអង្គហេតុចេញមកពីប្រភពផ្ទាល់ តើលោកបាន

ទទួលព័ត៌មានជាអង្គហេតុទៀតអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត លោកប្រើពាក្យថា ការងារដែលគេអះអាងថាជាការបោះឆ្នោត តើមានភស្តុតាងអ្វី ថាតើវាមានការបោះឆ្នោត? តើញឹកញាប់ដូចម្ដេច? តើលោកអាចជួយពន្យល់បានដែរឬទេ?

**ឆ៖** ក្នុងចំណុចនេះគឺថា ខ្ញុំដូចជាមិនចាំ ខ្ញុំមិនបានសួរច្រើនពីបញ្ហានេះទេ។

**ស៖** ទំព័រ១២ នៅក្នុងឯកសារលោក និងឯកសារដែលខ្ញុំមាន គឺឯកសារដែលនាំឲ្យមានជើងទំព័រលេខ៤១ លោក កូប៉េ ក៏អង់គ្លេសគឺ 00087776, ខ្មែរ 00711385, បារាំង 00722075។ ១០ថ្ងៃក្រោយពីការបោះឆ្នោត គឺមានឯកសារគណៈកម្មាធិការសំខាន់កំណត់ពីសេចក្ដីសម្រេចថ្នាក់ដឹកនាំលើបញ្ហាសំខាន់ៗ និយាយពីនយោបាយពីការសម្លាប់ ហើយនិងការបំផ្លាញចោលនូវរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមកម្ពុជា។ ហើយលោកបាននិយាយសេចក្ដីសម្រេចចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ គឺលេខយោង៤១ និយាយថាឯកសារនេះ អ្វីដែលលោកយោងទៅរកគឺត្រូវបានបកប្រែដោយប៉ែន យៀរនិន ហើយនៅក្នុងផែនការរបស់ ប៉ុល ពត សម្រាប់អនាគត បញ្ជាក់ថា ការបកប្រែរបស់ខ្ញុំគឺខុសបន្តិចពីរបស់គាត់ ច្បាប់ដើមខ្មែរនោះអាចផ្ដល់មកខ្ញុំដោយ ដេវីដ ឆេនដ័ល័រ។

[១៥:២២:២០]

ខ្ញុំសួរលោកទាក់ទងទៅនឹងការបកប្រែឯកសារនេះ តើមានភាពខុសគ្នាអ្វីសំខាន់ទេ ទាក់ទងទៅនឹងបញ្ហានយោបាយ អំពីការសម្លាប់ទាក់ទងទៅនឹងការបំផ្លាញចោលរណសិរ្សរួបរួមជាតិកម្ពុជា ហើយនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា?

**ឆ៖** ខ្ញុំគិតថា មានបញ្ហាតែងតែកើតឡើងអំពីការបកប្រែពីខ្មែរ ដោយសារមិនមានភាពខុសគ្នាទាក់ទងទៅនឹងពហុវចនៈ ហើយនិងឯកវចនៈ។ ជួនកាលមិនច្បាស់ថាតើយើងនិយាយអំពីមន្ទីរ ឬក៏មន្ទីរនានា មន្ទីរទាំងឡាយ។ ជួនកាលជាបញ្ហាទាក់ទងទៅនឹងអំពីគុណនាមដែលពន្យល់នូវនាម។ ពេលខ្លះយើងពិបាកនឹងប្រាប់ ថាតើពាក្យ“អចិន្ត្រៃយ៍”ហ្នឹងគឺពន្យល់ឲ្យពាក្យមួយណា? តើ“គណៈអចិន្ត្រៃយ៍”ហ្នឹងពន្យល់អត្ថន័យឲ្យ “គណៈ” ណាមួយហ្នឹង? អ៊ីចឹងគឺថាពិបាក។ នេះគឺបញ្ហាដែលថាកិច្ចការបកប្រែគឺគេអាចកំណត់តាមបរិបទ។ ជួនកាលគឺមិនមានដំណោះស្រាយឲ្យច្បាស់ទេ ពេលខ្លះយើងត្រូវស្មានយក។

[១៥:២៤:០០]

**ស៖** យើងមើលទំព័រដដែល លោកបានពន្យល់ពីឯកសារតាមន័យនៃភាសាខ្មែរដែលលោកចេះ។

ខ្ញុំសូមដកស្រង់ ឯកសារចាប់ផ្ដើមនិយាយអំពី "ការបំភ្លឺនយោបាយទាក់ទងសិទ្ធិក្នុងការសម្រេច ក្នុងការកម្ទេចនៅក្នុង និងក្រៅជួរបក្ស។ គេប្រកាសថាត្រូវតែមានរង្វង់អំណាចដែលការងារក្នុងការអនុវត្ត ផ្ដាច់ការបដិវត្តន៍របស់យើង ដែលត្រូវធ្វើការកាប់សម្លាប់នោះ។ នៅបន្ទាប់គេងាកចេញដែលថា ស្ថាប័នណាភាគីណា បក្សណាដែលអាចចេញបញ្ជាឲ្យធ្វើការសម្លាប់នៅក្នុងបរិបទផ្សេងៗ។ ជាឧទាហរណ៍ និយាយអំពីការប្រកាសអ្នកណាដែលស្ថិតនៅក្នុងមន្ទីរមជ្ឈិមបក្ស មជ្ឈិមបក្សត្រូវធ្វើសេចក្ដីសម្រេច។ អ៊ីចឹងយើងឃើញថាអ្នកដែលនៅមន្ទីររបស់មជ្ឈិម យ៉ាងហោចណាស់ក្នុងករណីមួយចំនួននិយាយ -- កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលធ្វើការនៅក្នុងរដ្ឋាភិបាលដូចជារដ្ឋមន្ត្រី ប៉ុន្តែគាត់មិនស្ថិតនៅក្នុងជាសមាជិកគណៈមជ្ឈិមទេ"។ តើការធ្វើសង្ខេបពីការអានឯកសារនេះ ត្រូវទៅតាមអត្ថន័យភាសាខ្មែរដែលលោកយល់បានពីអត្ថបទដែលមិនច្បាស់នោះទេ?

[១៥:២៥:៣២]

**ឆ៖** បាទ នោះជាបញ្ហាដែលខ្ញុំបញ្ជាក់ជូន គឺកើតឡើងនៅក្នុងបរិបទនេះឯង។ ដូច្នេះ នៅកន្លែងដែលនិយាយថា ចំពោះដែលអ្នកនៅជុំវិញមន្ទីរមជ្ឈិមជា អាចជាមន្ទីរមួយ។ មន្ទីរមជ្ឈិមបាទ មន្ទីរគណៈមជ្ឈិមនោះ គឺជាមន្ទីរគណៈមជ្ឈិម។ អ៊ីចឹងវាមានភាពស្រពេចស្រពិល មិនច្បាស់នៅពេលដែលយើងអានឃើញឃ្លាហ្នឹង ឃើញពាក្យហ្នឹង។ បើមិនមានបរិបទ ហើយនិងព័ត៌មានអីបន្ថែមទេ យើងមិនដឹងថាជា ឯកវចនៈនាម ឬពហុវចនៈនាមទេ។

**ស៖** នៅខាងក្រោម នៅទំព័ររបស់យើងនេះ ទំព័រ១២ ដែលបន្តមកពីលេខយោងទំព័រ៤៣ លោកបានយោងទៅរក សឿ វ៉ាស៊ី។ ហើយយើងត្រឡប់ទៅទំព័រ១៣ ដែលអង់គ្លេស 0087777, ខ្មែរ 00711386, បារាំង 00722076។ បក្សកុម្មុយនីស្តកម្ពុជាដែលថា "ឈ្មោះបដិវត្តន៍ឈ្មោះ ខឿន ក៏ដូចជា ខៀវ សំផន ដូចជាបញ្ញាជនដែរ ប៉ុន្តែមិនសូវល្បីទេ។ មិនអ្នកណាម្នាក់ គឺថាមានការធ្វើការនៅកម្រិតខ្ពស់ដែលមានជាអ្នកបញ្ជូនវន្តមកពីសម័យ សីហនុ ទេ គឺជាប្រធានមន្ទីរ៨៧០ គឺជាឋានៈដែលមានអំណាចមួយ ដោយសារថាអាចកំណត់ពីភារកិច្ច ដែលអាចតាមដាននូវការអនុវត្ត" របស់គណៈរបស់សេចក្ដីសម្រេចនយោបាយរបស់គណៈអចិន្ត្រៃយ៍។ សេចក្ដីយោង គឺទៅថ្ងៃទី០៦ ខែ -- ថ្ងៃទី០៩ តុលា ឆ្នាំ១៩៩៥ គឺឯកសារ E3/192។ តើលោកនិយាយអំពីការកំណត់ភារកិច្ចអ្វីនៅក្នុងកំណត់ហេតុដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំពីមុនហ្នឹង ឬដូចម្ដេច?

[១៥:២៨:១២]

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** និយាយអំពីព័ត៌មានជាអង្គហេតុ តាមប្រភពដែលជាអង្គហេតុមិនមែនមតិយោបល់របស់លោក មិនមែនជាការស្មានរបស់លោកទេ។ ក្រៅពីចម្លើយសារភាពមកពីមន្ទីរស-២១ តើលោកបានឃើញឯកសារណាដែលបញ្ជាក់ពីអង្គហេតុ ពីព័ត៌មាននិយាយអំពីការងាររបស់មន្ទីរ៨៧០ ដែរឬទេ?

**ឆ៖** ខ្ញុំគិតថា បាទ។ ប្រសិនបើត្រូវពិនិត្យមើលរឿងនេះ ខ្ញុំនឹងត្រូវមើលឯកសារនីមួយៗម្ដងទៀត ដើម្បីនឹងឲ្យច្បាស់ គឺថាមានបញ្ហាគេបញ្ជាក់នៅក្នុង ពីព្រោះនេះជាបញ្ហាចម្រូងចម្រាស ហើយនិងបញ្ហាសំខាន់ គឺវាមានការមិនច្បាស់លាស់ទាក់ទងទៅនឹងការប្រើពាក្យពេចន៍បច្ចេកទេស។ ហើយដូច្នេះខ្ញុំផ្អែកលើមូលដ្ឋានអង្គហេតុដោយមិនមានឯកសារមកពិនិត្យទេ ខ្ញុំមិនអាចជូនជាចម្លើយបានទេ។

[១៥:២៩:៣៥]

**ស៖** សូមអរគុណ។ ទំព័រ១៤ នៅលើឯកសារយើងហ្នឹង ដែលបន្ទាប់ពីជើងទំព័រ៤៩ អង់គ្លេស ERN 00087778, ខ្មែរ 00711389, បារាំង 00722077។ នៅខាងក្រោមទំព័រ១៤ ដែលលោកមាននេះ៖ "ខែតុលា ឆ្នាំ១៩៧៥ នៅពេលដែល ខៀវ សំផន ជាអនុនាយករដ្ឋមន្ត្រីគឺចំពោះបញ្ញវន្តទាំងប្រាំបួននាក់ តួអង្គនយោបាយសំខាន់ដែលគាត់ធ្វើការជាមួយនៅក្នុងភ្នំពេញមុនបដិវត្តន៍នោះ។ ប៉ុន្តែគេមិនសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាមានឋានៈទាបៗជាងគាត់ ហើយមិនមានទំនាក់ទំនងផ្ទាល់ជាមួយមេដឹកនាំបក្សនៅក្នុងគណៈអចិន្ត្រៃយ៍ទេ"។

បន្ទាប់លោកបានពិភាក្សាអំពីតួអង្គផ្សេងទៀត។ មួយភាគបីនៅក្រោម -- ក្នុងទំព័រនេះ លោកនិយាយថា៖ "ក្នុងចំណោមគាត់ដែលថាសមាជិកហ្វុងនៅក្នុងក្រុង១៦នាក់របស់លោក ខៀវ សំផន បានក្លាយទៅជាជនរងគ្រោះនៃការសម្លាប់ គឺថាប្រាំបួនក្នុងចំណោម១៦នាក់នោះ"។ តើខ្លឹមសារនេះ លោកដឹងគឺថាវាត្រឹមត្រូវអ៊ីចឹងដែរឬទេ ការពិតនោះ?

[១៥:៣១:២៥]

**ឆ៖** ខ្ញុំគិតថាបាទ ខ្ញុំត្រូវពិនិត្យមើល ហើយឥឡូវខ្ញុំត្រូវរាប់មើល។ គឺថា ចម្លើយគឺ "បាទ"។

**ស៖** បាទ អ៊ីចឹងគឺថាចំនួនប្រាំបួននាក់នៅក្នុងលេខយោង៤១នោះ តើលោក -- តើចំនួនប្រាំបួនដែលចែងនៅក្នុងលេខយោង៥០ហ្នឹង ច្បាស់អ៊ីចឹងឬទេបាទ?

**ឆ៖** បាទ ឈ្មោះប្រាំបួនគឺបានបញ្ជាក់នៅក្នុងលេខយោងលេខ៥០ហ្នឹង។

**ស៖** ខ្ញុំនឹងទៅមើលទំព័រ១៩ នៅក្នុងឯកសារយើង គឺអត្ថបទទាក់ទងទៅនឹងលេខយោង៦៦

អង់គ្លេស 00087738, ខ្មែរ 0071138, 00722081 បារាំង។ "និយាយអំពីការផ្សព្វផ្សាយតាមវិទ្យុផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យនូវសុន្ទរកថារបស់ ប៉ុល ពត ដែលលាតត្រដាងជាលើកដំបូងអំពីវត្តមាននៃបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី២៧ កញ្ញា ឆ្នាំ១៩៧៧។ ជាសុន្ទរកថាទស្សនៈរបស់ ប៉ុល ពត អំពីប្រវត្តិទាំងមូលរបស់ចលនាកុម្មុយនីស្ត ហើយនិងពីការជោគជ័យ និងការបរាជ័យ។ ចង់បង្ហាញសាធារណៈដើម្បីមានការជឿជាក់ ដែលលើបុគ្គលពីរនាក់ដែលគាត់ទុកចិត្តក្នុងការបោសសម្អាតអ្នកដែលផ្សេងទៀតដូចមាន នួន ជា និង ខៀវ សំផន អ្នកទាំងពីរនាក់នេះនៅក្នុងមេដឹកនាំបក្សដែល ប៉ុល ពត បានបញ្ជាក់ពីការគាំទ្រ។ ប៉ុល ពត ពណ៌នា ខៀវ សំផន ថាជាបញ្ញាជន ដែលថាជាអ្នកគួរឲ្យគោរព ហើយដែលហើយគាត់សកម្មភាពនយោបាយរបស់គាត់ៗបានធ្លាប់មានពិរុទ្ធភាពក្នុងសង្គមដើម"។

គឺថាឯកសារហ្នឹងគឺ E3/144។ អ៊ីចឹង គឺថាផ្អែកលើប្រភពជាអង្គហេតុ ឬក៏ព័ត៌មានច្បាស់លាស់ថាតើលោកបានដឹងពីការពិតដូចម្ដេច អង្គហេតុដូចម្ដេចដែល ប៉ុល ពត និយាយពីអ្នកផ្សេងៗទៀតអំពីការសរសើរអ្នកណាផ្សេងដូច ខៀវ សំផន និងលោក នួន ជា នេះដែរឬទេ?

[១៥:៣៤:០៩]

**ឆ៖** តាមដែលខ្ញុំចាំមិនធ្លាប់មានទេ។

**ស៖** ខ្ញុំសូមបន្តទៅទំព័រ២៥ នៅក្នុងឯកសារយើងហ្វូតណូត៧៤ លោក កូប៉េ ERN អង់គ្លេស 00087789, ខ្មែរ 00711408, បារាំង 00722089។ នេះគឺជាសំណួរដែលលោកសួរទៅ ខៀវ សំផន ក្នុងឋានៈជាមេដឹកនាំ ហើយចៅក្រម ឡាវែន៍ គាត់បានសួរប៉ុន្មានសប្ដាហ៍មុនមកហើយ ហើយខ្ញុំក៏សួរសំណួរបន្ថែមផ្ដើមចេញពីការសួររបស់លោកចៅក្រម ទាក់ទងទៅនឹងតួនាទីរបស់ ខៀវ សំផន នៅមុនឆ្នាំ -- ក្រោយឆ្នាំ១៩៧៥ សូមទោស ៧៩។ ក្នុងទំព័រ២៥នេះ លោក -- ឯកសារបានសរសេរថា "នៅក្នុងខែធ្នូ ឆ្នាំ១៩៧៩ ១១ខែ ក្រោយពីអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានបាក់បែក ដោយសារតែការវាយប្រហាររបស់កងទ័ពវៀតណាម។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគឺត្រូវបានកែប្រែឡើងវិញ។ ប៉ុល ពត បានចុះចេញពីអំណាច ហើយត្រូវ ខៀវ សំផន បានជំនួសតួនាទីជានាយករដ្ឋមន្ត្រី"។

លេខយោងជើងទំព័រ៧៤ "កម្ពុជាប្រជាធិបតេយ្យ" ប្រវត្តិរូបរបស់សមាជិកនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលជាអក្សរឯកសារដែលវាយដោយអក្សរពុម្ព ដែលមាននៅក្នុងការកាន់កាប់របស់អ្នកនិពន្ធ។ តើលោកអាចពន្យល់បានទេ ថាតើលោកនេះកាន់កាប់ឯកសារដែលវាយជាអក្សរពុម្ពហ្នឹងដោយរបៀបណា?

[១៥:៣៦:៣៥]

**ផ៖** ឯកសារនេះគឺគេបានឲ្យមកខ្ញុំ គឺអ្នកកាសែតម្នាក់ ឬក៏ច្រើនម្នាក់ ដែលអ្នកកាសែតទាំងនុំង គឺខាងខ្មែរក្រហមបានឲ្យមកពួកគេ។ ជាឯកសារជាភាសាអង់គ្លេស ដែលត្រូវចែកជូនទៅអ្នកកាសែត ក្នុងពេលនុំង ហើយអ្នកកាសែតទាំងនោះក៏បានឲ្យឯកសារនេះមកខ្ញុំ។ ខ្ញុំគិតថាឈ្មោះ ចាន់ យូរ៉ាន់ គឺថា ជា ចាន់ យូរ៉ាន់ ឬក៏ជាអ្នកណា។

**ស៖** ទំព័របន្ទាប់គឺទំព័រ២៦ ហ្វូតណូត៧៧ ERN 007790 *(ស៊ីក)* ខ្មែរ 00711410, បារាំង 00722088។ បន្ថែមទៅលើតួនាទីជានាយករដ្ឋមន្ត្រី ខៀវ សំផន ក៏ក្លាយទៅជាប្រធានស្តីទីនៃរណសិរ្ស រួបរួមជាតិកម្ពុជា។ ឯកសារយោង កម្ពុជាប្រជាធិបតេយ្យ ឯកសារនេះមានឈ្មោះថា សមាសភាព បន្ថែមនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយអ្នកនិពន្ធគឺថាជាអ្នកគ្រប់គ្រងនូវឯកសារវាយជាអក្សរ ពុម្ពនេះ។ គឺវាស្រដៀងគ្នាទៅនឹងឯកសារដែលខ្ញុំយោងទៅនឹងជើងទំព័រពីមុននេះ។

**ផ៖** បាទ ខ្ញុំគិតថា ឯកសារជាភាសាអង់គ្លេស។ ឯកសារនេះគេមានអ្នកកាសែត ដែលបាន ទទួលពីពួកខ្មែរក្រហមហ្នឹង អ្នកកាសែតហ្នឹងបានឲ្យមកខ្ញុំ។

**ស៖** ខ្ញុំសូមបន្តទៅទំព័រ២៨ នៅលើឯកសាររបស់យើងនេះ។ បាទ ទាក់ទងទៅនឹងលេខយោង ជើងទំព័រនេះ ជាអត្ថបទទាក់ទងទៅនឹងឯកសារចន្លោះពីជើងទំព័រ៨៣, ៨៤។ លោកនិយាយអំពីកិច្ច សម្ភាសន៍ជាមួយ ខៀវ សំផន ក្នុងឆ្នាំ១៩៨០ ហើយបង្ហាញនូវការវិភាគ គឺនៅទំព័រ២៨ខាងក្រោម។ ប្រហែលជាមានសារៈសំខាន់ណាស់ក្នុងការដកស្រង់ឯកសារដ៏វែង ដែល ខៀវ សំផន បានបញ្ជាក់ជូន អ្នកនិពន្ធនៅខែសីហា ឆ្នាំ១៩៨០។ ឯកសារនេះគឺបានជូននៅក្នុងខែកក្កដា ឆ្នាំ១៩៨៧ ក្នុងពេលដែលគាត់ កាប់អំណាចនោះ។

[១៥:៣៩:៤៩]

ខ្ញុំមិនលើកនិយាយអំពីភាពអត់ឃ្លានអីទេ ខ្ញុំនិយាយអំពីភាពផ្សេងវិញ គឺពាក់កណ្តាលទំព័រខាង ក្រោម ឃ្លាចាប់ផ្តើមទាក់ទងទៅនឹងការកាប់សម្លាប់។ ឃ្លានេះបានសរសេរដូចតទៅ៖ “ទាក់ទងទៅនឹង ការសម្លាប់ គាត់គឺ ខៀវ សំផន បានអះអាងស្រដៀងគ្នាថា ការពិតជាស្តែងនោះគឺថា មិនមានការកាប់ សម្លាប់ក្នុងលក្ខណៈជាប្រព័ន្ធដោយសារតែគោលនយោបាយនោះទេ។ នេះគឺថាជាពាក្យពេចន៍មួយនិយាយ យ៉ាងប្រត្យក្ស។ ហើយបន្ទាប់មកគាត់បាននិយាយប្រហែលជាបួនឃ្លាមកខាងក្រោម៖ “ដូច្នេះក្រោយ ពីសួរគាត់ សួរទៅគាត់ថាតើមានការគិតឃើញដែលពាក់ព័ន្ធប៉ះពាល់ទៅដល់ជីវិតរបស់ប្រជាជនទេ?

គាត់ឆ្លើយថា៖ វាមានប៉ះពាល់ហើយតាមការពិតនោះ ទោះបីជាវាមិនមានការកាប់សម្លាប់ទ្រង់ទ្រាយធំក៏ដោយ។ ហើយគាត់បន្ថែមទៅទៀតថា ការអត្ថិភាពនៃការសម្លាប់របស់នេះគួរតែត្រូវបញ្ជាក់។ គឺថាវាជាលទ្ធផលដោយសារភ្នាក់ងារវៀតណាម ភ្នាក់ងារខ្មែរដែលជាពួកវៀតណាម ជ្រៀតបញ្ចូលមកក្នុងជួរអំណាចរដ្ឋរបស់យើង ដែលគេកាន់កាប់តួនាទីសំខាន់ៗ"។ លោកនិយាយសំដៅទៅលើ សោ ភឹម, រស់ ញឹម និង ជូ ជេត ដែលអ្នកខ្លះគឺថាទទួលខុសត្រូវកាន់កាប់ភូមិភាគ។ ហើយលោកដកស្រង់ពីកិច្ចសម្ភាសន៍នេះថា៖ "ពីឆ្នាំ១៩៧៧ ដល់ ៧៨ យើងបានដោះស្រាយពួកហ្នឹងអស់ហើយ ហើយបានដាក់ការបញ្ជាឲ្យមានភាពប្រក្រតីឡើងវិញ ទៅចំពោះស្ថានភាពនៅក្នុងប្រទេសជាតិ"។ ចំពោះអ្វីដែលលោកសរសេរនៅក្នុងទំព័រនេះ ហើយនិងអ្វីដែល ខៀវ សំផន ប្រាប់ទៅលោកក្នុងពេលលោកសម្ភាសគាត់នោះ សូមលោកបញ្ជាក់បន្តិច។

[១៥:៤២:០០]

**ឆ៖** ខ្ញុំគិតមើលពាក្យថា "*ស្ងួតធឹង-អៅ*" នេះគឺថាបានចាត់ចែងអស់ហើយ ដោះស្រាយអស់ហើយនេះ។ ខ្ញុំកំពុងតែពិនិត្យមើលទៅហ្វូតណូត។

**ឆ៖** ប្រសិនបើណាខ្ញុំជួយបង្ហាញលោកទៅលើកិច្ចសម្ភាសន៍នេះផ្ទាល់តែម្តង។ *ថេប*៦ នៅក្នុង*ក្រុណូ*ដែលជូនលោកនោះ ទំព័រ១៨។ ឥឡូវនេះ នេះគឺជាកិច្ចសម្ភាសន៍មែនទែនគឺ E3/203 ERN អង់គ្លេស 00424013, ERN ជាភាសាបារាំង 00434232, ERN ជាភាសាខ្មែរ 00385409 ដល់ 10។ នេះគឺជាប្រតិចារឹកនៃកិច្ចសម្ភាសន៍ផ្ទាល់ បើសិនណាជាលោកមើលនៅផ្នែកខាងក្រោមនៃទំព័រ១៨ ដែលអ្នកទទួលខុសត្រូវភូមិភាគខ្លះ គឺត្រូវបានដោះស្រាយរួចរាល់ហើយ។ ហើយខ្ញុំសូមអានតែម្តង ហើយសូមលោកបញ្ជាក់ថា នេះពិតជាអ្វីដែលលោក ខៀវ សំផន បានឆ្លើយប្រាប់លោកក្នុងពេលសម្ភាសនោះ ឬយ៉ាងម៉េច?

[១៥:៤៣:៤៣]

ខ្ញុំសូមចាប់ផ្តើមជាមួយនឹងឃ្លាថា "អ្នកខ្លះគឺទទួលខុសត្រូវនៅភូមិភាគសំខាន់ៗ ហើយគេបានក្បត់ជួររបស់យើង។ គេមិនសប្បាយចិត្ត គេគឺធ្វើប៉ះពាល់ដល់ជីវិតរបស់ប្រជាជន។ តើគេធ្វើបែបនេះដើម្បីអ្វី? គេដើម្បីដាក់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឲ្យនៅឯកោពីប្រជាជន គឺអ៊ីចឹងដើម្បីងាយស្រួលសម្រាប់ពួកគេធ្វើរដ្ឋប្រហារ។ នេះគឺជាមិនមែនជាការវាយប្រហារពីខាងក្នុងទេ ជាការវាយប្រហាររបស់យើងមកពីខាងក្នុងចេញទៅខាងក្រៅ។ ប៉ុន្តែយើងបានវាយប្រយុទ្ធបកជាបន្តបន្ទាប់ ហើយធ្វើឲ្យ

ពួកវាបរាជ័យ។ រហូតមកដល់ឆ្នាំ១៩៧៧ ដល់៧៨ យើងបានចាត់ចែងដោះស្រាយជាមួយអ្នកទាំងអស់នេះរួចរាល់ទាំងស្រុងអស់ហើយ។ ហើយវាបានធ្វើឲ្យប្រទេសជាតិមានសណ្ដាប់ធ្នាប់ឡើងវិញ ហើយប្រជាជនមានការសប្បាយរីករាយណាស់”។ លោកសាក្សី តើនេះគឺជាការកត់ត្រាយ៉ាងត្រឹមត្រូវនៅពេលលោកសម្ភាសជាមួយលោក ខៀវ សំផន ហ្នឹងឬក៏យ៉ាងម៉េច?

[១៥:៤៤:៥៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សហព្រះរាជអាជ្ញាបានបញ្ចប់ចម្លើយនេះទាំងស្រុងហើយ នៅពេលគាត់អានទំព័រចុងក្រោយ។ សូមឲ្យអានទំព័រចុងក្រោយ១៨ឡើងវិញ។

**លោក ឃីត រេយ៍ន័រ៖**

លោកមេធាវីការពារក្ដីមាន លោកអាចសួរនៅត្រង់ចំណុចនេះនៅពេលសួរតទល់ទៅ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក ហេដឌ័រ តើលោកអាចជួយបញ្ជាក់បានទេ នេះគឺជាអ្វីដែលលោកសម្ភាស លោក ខៀវ សំផន មែនទេ?

[១៥:៤៥:៣៦]

**ប្រធានអង្គជំនុំ៖**

សូមសាក្សីឆ្លើយតប!

សូមអញ្ជើញ!

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថាខ្លឹមសារជាមូលដ្ឋាននៃឯកសារនេះ ដែលទើបកំពុងតែយោងអម្បាញ់មិញនេះ ខ្លឹមសារដែលបោះពុម្ពផ្សាយនេះ គឺយកចេញពីកិច្ចសម្ភាសន៍ដូចតែមួយនេះឯង។ វាអាចមានលក្ខណៈខុសគ្នាបន្តិចបន្តួចដោយសារតែការបកប្រែពីភាសាមួយទៅភាសាមួយ ក៏ប៉ុន្តែខ្លឹមសារនេះគឺថាវាដូចគ្នាហើយ បើទោះការបកប្រែមិនដូចទាំងស្រុងក៏ដោយ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ទាក់ទងទៅនឹងកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន នៅថ្ងៃទី០៤ សីហា ១៩៨០ សំណួរស្រដៀងគ្នាទាក់ទងទៅនឹងសំណួរដែលលោកសួរ ខៀវ សំផន ថាតើកិច្ចសម្ភាសន៍នេះរៀបចំឡើងដោយរបៀបម៉េច? លោកអាចមានលទ្ធភាពជួបគាត់បានដោយរបៀបណា? អ្នកណាមានវត្តមានក្នុងកិច្ចសម្ភាសន៍ហ្នឹងខ្លះ? សូមលោករៀបរាប់ប្រវត្តិនៃកិច្ចសម្ភាសន៍នេះខ្លះៗបាទ។

[១៥:៤៧:០១]

**ឆ៖** កិច្ចសម្ភាសន៍នេះធ្វើឡើងនៅពេលដែលខ្ញុំនៅវិទ្យាស្ថានអាស៊ី មានទីតាំងនៅជូឡាឡុងកនបាងកក។ ការរៀបចំកិច្ចសម្ភាសន៍នេះ គឺសម្របសម្រួលឡើងដោយអ្នកសិក្សាស្រាវជ្រាវជនជាតិថៃម្នាក់ដែលពេលនោះគាត់ជាប្រធានផ្នែកវិទ្យាស្ថានមួយនៃសកលវិទ្យាល័យ ហើយនិងក៏មានការជំនួយពីអ្នកកាសែតអតីតសហការីរបស់ខ្ញុំដែលអ្នកកាសែតមកពីក្បូដូ ដែលគឺគាត់និងខ្ញុំធ្វើការសម្ភាសជាមួយគ្នាក្នុងឯកសារមួយ យើងបានពិភាក្សាយ៉ាងទូលំទូលាយ។ មានអ្នករួមដំណើរដោយអ្នកកាសែតមួយចំនួនទៀត។ ខ្ញុំកំពុងតែព្យាយាមនឹកអ្នកកាសែតហ្នឹងមានឈ្មោះអ្វីខ្លះ ប្រហែលជាម្នាក់នោះ ឈ្មោះ ហ្គារីប៊ីនដែលជាអ្នកកាសែតខាងផ្នែកទូរទស្សន៍ អ្នកសារព័ត៌មានទូរទស្សន៍ ហើយអ្នកដទៃទៀតខ្ញុំចាំឈ្មោះមិនច្បាស់ថាអ្នកណាជាអ្នកណាទេ។

គេបានមកដឹកយើងចេញពីបាងកកដោយឡានកម្ពុជាប្រជាធិបតេយ្យ ហើយដឹកយើងមកសំដៅព្រំដែនកម្ពុជា-ថៃ។ ប្រហែលជាដឹកយើង ដឹកពីពេលហ្នឹងឆ្លងមកខាងទឹកដីខ្មែរ គឺនៅក្នុងទឹកដីព្រះវិហារគឺជាតំបន់ដែលមានជម្លោះនឹងគ្នាពេលហ្នឹង។ វាលក្ខណៈរបៀបដូចជាសន្និសីទ កាសែតទម្រង់នៃកិច្ចសម្ភាសន៍នេះ។ ខៀវ សំផន គាត់បានរៀបចំនូវសេចក្តីថ្លែងការណ៍របស់គាត់ ដើម្បីថ្លែងមកកាន់ខ្ញុំនិងអ្នកកាសែតដែលមានវត្តមាននៅពេលនោះ។ ហើយខ្ញុំមានកិច្ចសម្ភាសន៍ដាច់ដោយឡែកមួយជាមួយ ខៀវ សំផន បើតាមខ្ញុំចាំគឺមួយទល់មួយ។ អ្នកកាសែតដទៃទៀតគឺមិនមានវត្តមានទេ មានតែ ខៀវ សំផន និងខ្ញុំ មួយទល់មួយ ហើយខ្ញុំថតជាខ្សែអាត់ទៀត។ ហើយពួកយើងខ្ញុំជាអ្នកកាសែតបានសម្រាកនៅទីនោះមួយយប់។ ហើយបើខ្ញុំចាំមិនភ្លេចទេ យើងព្រឹកស្អែកឡើងយើងចាកចេញ ហើយគេដឹកយើងត្រឡប់ទៅបាងកកវិញតាមរយៈឡានរបស់កម្ពុជាប្រជាធិបតេយ្យ។

[១៥:៤៩:៥៨]

**ស៖** តើទីតាំងហ្នឹងឈ្មោះទីតាំងអ្វី គឺនៅជាយក្រុង នៅក្នុងទីក្រុង នៅក្នុងព្រៃ? តើសម្ភាសនៅ

ឯណា? ហើយរៀបចំកិច្ចសម្ភាសន៍ដោយរបៀបម៉េច? ហើយអ្នកណាមកជាមួយ ខៀវ សំផន? សូមលោករៀបរាប់អំពីទម្រង់ការនេះបន្តិចមើល៍។

**ផ៖** បាទ កិច្ចសម្ភាសន៍នេះ គឺនៅកំពូលភ្នំ ឬក៏ជិតកំពូលភ្នំដងរែក ដែលទីហ្នឹង វាជាទីកន្លែងមួយបង្កើតបានជាព្រំដែនរវាងកម្ពុជា-ថៃ ដែលមានជម្លោះនឹងគ្នា។ ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចសម្ភាសន៍ មានអ្នកឈ្មោះ ជួន ម៉ុម ក៏មានវត្តមាន ហើយក្នុងពេលនោះក៏មានវត្តមានរបស់ សុន សេន ហើយខ្ញុំក៏បាននិយាយទៅគាត់ដោយក្រៅផ្លូវការ។ នេះគឺជាអ្វីដែលយើងសម្ភាសពីភាគីកម្ពុជាប្រជាធិបតេយ្យ សុន សេន អ្វីដែល សុន សេន និយាយមកខ្ញុំនោះគឺថា វាទើបតែងើបចេញមកពីកិច្ចការ គឺថាវាមានទំនាស់ផ្ទៃក្នុង ហើយយើងកំពុងតែធ្វើការប្រយុទ្ធជាមួយនឹងពួកវៀតណាម។ ហើយពេលហ្នឹង គឺថាខ្ញុំនិយាយចិន និងខ្ញុំអាចនិយាយចិន និងនិយាយថៃ គឺអ្នកសិក្សាស្រាវជ្រាវជាជនជាតិបស្ចិមប្រទេស គេមិនសូវចង់ជួបទេ តាំងពីភ្នំពេញដួលរលំទៅ។ នេះគឺជាកិច្ចសម្ភាសន៍ ដែលធ្វើឡើងនៅទីបញ្ជាការរបស់គណៈមជ្ឈិម។

[១៥:៥២:០៨]

**ស៖** ខ្ញុំចង់ឲ្យលោកពិនិត្យមើលទំព័រទី១ *ក្រណាត់*លេខ៣ *ថេប*១ ផ្នែកខាងមុខនៃ -- គឺសម្ភាសរយៈពេល៤៧នាទី គឺទៅដល់ ០០ ទៅ ១៦ នាទី ហើយបន្ទាប់មកខ្ញុំសួរលោកនៅទំព័រចុងក្រោយនៃឯកសារនេះ។ នៅទំព័រមុខបំផុត គឺលោកសម្ភាសមានរយៈពេល៤៧នាទី ដំបូងសូមឲ្យលោកបញ្ជាក់កិច្ចសម្ភាសន៍នេះ។

**ផ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ហើយបើលោកមើលទំព័រចុងក្រោយនៃឯកសារ E3/203 យើងមកដល់ចុងបញ្ចប់នៃឯកសារ *ថេប*១ហើយ។ តើខ្សែអាត់លេខ៦នេះ ថាតើលោកកត់ត្រាដោយរបៀបណា?

**ផ៖** ជាកាសែតធម្មតានាសម័យនុំង។ កាសែតដែលគេប្រើចាក់ស្តាប់បទចម្រៀងអីអង្កាល់សម័យនោះ។

**ស៖** ថាតើការថតហ្នឹងថតនៅខ្សែអាត់ថតនុំង លោកថតដោយបើកចំហតែម្តង ឬក៏មានការលួចថត ឬក៏យ៉ាងម៉េច?

**ផ៖** នេះមិនមែនជាការថតដោយស្ងាត់ៗទៀត គឺថាជាកិច្ចសម្ភាសន៍មួយត្រឹមត្រូវ គឺថាយើងថតផ្លូវការតែម្តង។

[១៥:៥៤:០២]

**ស៖** ខ្ញុំសូមចូលទៅទំព័រ២០ នៃឯកសារ E3/203 សូមទោស ប្រហែលជាវាងាយស្រួលជាងបើខ្ញុំ -- បាទ ខ្ញុំសូមចូលទៅទំព័រចុងក្រោយ គឺទំព័រ២១ ERN អង់គ្លេស 00424016, ខ្មែរ 0038914 និងបារាំង 00434236 ដល់ 7។ សូមដកស្រង់សំណួររបស់លោក សំណួរសួរទៅ ខៀវ សំផន "អ្វីដែលខ្ញុំចង់សួរលោក គឺនៅពេលដែលគេចោទប្រកាន់អ្នកណាម្នាក់ថាជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ភ្នាក់យួន។ ខ្ញុំចង់សួរលោកថាតើមានអ្នកខ្លះក្នុងចំណោមហ្នឹងត្រូវបានគេប្រកាន់ថាភ្នាក់ងារយួន ដើម្បីសម្លាប់គេនោះទេ? ឬក៏ដើម្បី -- តើវាមានអ្វីកើតឡើងទៅដល់ថ្នាក់លើដែរទេ? ឆ្លើយ៖ បាទ មានសមមិត្តយើងអាយុចាស់ហើយត្រូវភ្នាក់ងារយួនចោទប្រកាន់។ ពួកគេទទួលខុសត្រូវ ពួកគេចោទប្រកាន់គាត់ ប៉ុន្តែមិនជោគជ័យទេ ដោយសារយើងស៊ើបអង្កេតរឿងហ្នឹងទៅបានទាន់ពេលវេលា"។ ខ្ញុំចង់បញ្ឈប់ត្រឹមនេះ ដោយសារប្រតិចារឹកនេះគឺនៅចុងបញ្ចប់នៃកាសែតលេខ៦ តើត្រឹមត្រូវទេត្រង់ទំព័រនេះ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[១៥:៥៦:១៣]

**ស៖** ឥឡូវនេះខ្ញុំចង់ឲ្យលោកត្រឡប់មកឯកសារដដែល។ កាសែតលេខ១ ជាសៀវភៅដែលសរសេរអំពី "ប៉ុល ពត និង ខៀវ សំផន"។ ហើយលេខទំព័រគឺ២៩, ERN អង់គ្លេស លេខយោង៨៩ នៅអត្ថបទខាងក្រោមសម្រាប់បញ្ជូនទៅលោក កូប៉េ។ ERN អង់គ្លេស 00087793, បារាំង 00722009, ខ្មែរ 00385413 ដល់ 14។ បើលោកមើលក្បាលទំព័រ២៩ លោក -- សូមអធ្យាស្រ័យ មិនមែនលោកឃៀរនិន ទេលោក ហេដឌ័រ។ វាច្រឡំបន្តិចហើយ កៀកម៉ោង។

នេះជាការបកប្រែពីកិច្ចសម្ភាសន៍៖ "មានសមមិត្តមកពី -- ដែលចាស់ៗហើយមកពី -- ដែលត្រូវពួកភ្នាក់ងារវៀតណាមចោទប្រកាន់ថាទទួលខុសត្រូវពីខាងលើគាត់។ ទាក់ទងទៅនឹងបញ្ហានេះ គេអាចធ្វើការចោទប្រកាន់ដោយសារគេមិនអាចធ្វើយ៉ាងនេះបាន ដោយសារតែយើងដោះស្រាយពិនិត្យស្ថានភាពទាន់ពេលវេលា"។

លោកបានសរសេរនៅក្នុងសៀវភៅថា៖

"នៅពេលគេតាមដានស្វែងរកបញ្ហានេះតទៅទៀត នៅពេលសមមិត្តនៅភាព -- សមមិត្តនៅពាយ័ព្យនោះ ចេះតែព្យាយាមបង្កបញ្ហាតទៅទៀត គឺថាមានបញ្ហាកើតឡើង។ សំណួរ៖ ចុះចំពោះ ហ៊ូ នឹម, ហ៊ូ យន់ និងអ្នកដទៃទៀតដែលត្រូវបានសម្លាប់ដោយសារតែចោទប្រកាន់ថា មានប្រព្រឹត្តអំពើ

ក្បត់។ ហ៊ូ យន់, ហ៊ូ នឹម គឺជាមិត្តរបស់លោក ហើយខ្ញុំគិតថាលោកក៏ស្គាល់កម្មាភិបាលនៅថ្នាក់ដឹកនាំដទៃទៀតដែលត្រូវបានគេសម្លាប់នោះផងដែរ ដោយសារគេចោទប្រាន់ថាជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ភ្នាក់ងារ កា.ហ្សេ.បេ ឬក៏ជាភ្នាក់ងារវៀតណាម។

[១៥:៥៨:៥២]

ចុះចំពោះភូមិភាគតំបន់ និងលេខាភូមិភាគតំបន់ លេខារងទៀត ហើយលេខាស្រុក អនុលេខាស្រុក និងសមាជិកដទៃទៀត។ ខ្ញុំពិបាកនឹងជឿណាស់ ដោយសារមានភ្នាក់ងារច្រើនណាស់ ហើយនិងវៀតណាមនៅក្នុងបក្ស។ ខ្ញុំឥឡូវគិតថាអ្នកទាំងអស់នេះគឺជាភ្នាក់ងារ ដែលអ្នកទាំងអស់នេះ ដែលត្រូវគេសម្លាប់នៅក្នុងកម្រិតនេះ គឺត្រូវបានគេចោទប្រកាន់យ៉ាងត្រឹមត្រូវ ហើយគួរតែត្រូវគេសម្លាប់មែនហ្នឹង។ តើលោកមិនគិតថា វាថាជាការចោទប្រកាន់ខុស ឬយ៉ាងម៉េច ដែលអ្នកខ្លះគឺជាអ្នកស្មោះត្រង់នឹងកុម្មុយនីស្តជាអ្នកស្នេហាជាតិ ហើយត្រូវគេសម្លាប់ដោយខុសដែរឬទេ តាមដែលលោកដឹង? មិនមានករណីណាមួយដែលថាអ្នកណាគ្មានទោស ហើយត្រូវបានគេចោទប្រកាន់ទេ? មិនមានទេ ឆ្លើយ។ សំណួរ៖ ថាអ៊ីចឹងអត់មានចោទប្រកាន់ខុសអីមួយទេ? ឆ្លើយ៖ អត់ទេ។ សួរ៖ ដូច្នេះអ្នកដែលត្រូវគេសម្លាប់ហ្នឹងគឺជាពួកក្បត់? ឆ្លើយ៖ ត្រូវហើយតាមដែលខ្ញុំភ្លាប់បាន គឺក្បត់ហើយ។ សំណួរ៖ អ៊ីចឹង មិនមានអ្នកណាត្រូវបានគេចោទប្រកាន់ខុសទេអី? ឆ្លើយ៖ ដូចដែលខ្ញុំបាននិយាយថា គឺថាមានបុរសចាស់ម្នាក់មកពីខាងលិច ដែលត្រូវបានចោទប្រកាន់ថាជាមនុស្សក្បត់ ប៉ុន្តែតាមការពិតគឺជាមនុស្សដែលស្មោះត្រង់ទេ"។

ដូច្នេះសំណួរទី១របស់ខ្ញុំគឺថា នេះគឺជាអ្វីដែលលោកសរសេរនៅក្នុងឯកសាររបស់លោក កាសែតរបស់ហ្នឹង ដំបូងនោះ?

**ឆ៖** បាទ អ៊ីចឹងហើយ។

[១៦:០០:៣៨]

**ស៖** នៅពេលលោកសរសេរកាសែត ហើយយោងទៅលើកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន តើលោកយោងទៅលើកំណត់ត្រាមួយណា ដើម្បីដកស្រង់សម្តីផ្ទាល់មាត់ សំណួរដែលខ្ញុំសួរនិងឆ្លើយដែលខ្ញុំទើបបង្ហាញលោកអម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំកំពុងតែមើល ថាតើបញ្ហាវានៅត្រង់ណា។ តាមរបៀបដែលខ្ញុំសរសេរកាសែតហ្នឹង គឺវាមានកាសែតមួយទៀត។ ប្រហែលជាបាត់ហើយកាសែតហ្នឹងប៉ុន្មានឆ្នាំកន្លងហ្នឹង ហើយក៏វាអាចផងដែរ ក្រោយពីបាត់កាសែតយើងក៏សរសេរ ឬក៏សរសេរក្នុងពេលបាយល្ងាច ឬក៏សរសេរព្រឹកព្រលឹមឡើង។

យើងវាបាត់កាសែតដែលសម្ភាសក្នុងជាផ្លូវការហ្នឹង។ ប៉ុន្តែរបៀបនៃការសរសេរនេះ នេះគឺខ្ញុំគិតឃើញថាមិនមានអ្វីមិនខុសអ្វីពីកាសែតហ្នឹង ប៉ុន្តែកាសែតបាត់ហើយ វាបាត់គឺបាត់ហើយ។

**ស៖** តើលោកពេញចិត្តទេ? យល់ឃើញថាត្រឹមត្រូវទេ? សួរនិងឆ្លើយឆ្លុះបញ្ចាំងសំណួរដែលលោកសួរទៅកាន់ ខៀវ សំផន និងចម្លើយដែលគាត់ឆ្លើយមកលោកទេ? វាឆ្លុះបញ្ចាំងអ៊ីចឹងទេ?

**ឆ៖** ខ្ញុំមានការចាំយ៉ាងច្បាស់អំពីការសន្ទនាមួយនេះ ដោយសារជាព្រឹត្តិការណ៍ប្រឈមតទល់មុខគ្នា។ នេះគឺអ្វីដែលខ្ញុំចាំ គឺអ៊ីចឹងហើយ។

[១៦:០២:៣៤]

**ស៖** ឥឡូវនិយាយក្នុងបរិបទបែបនេះ: មានកាសែតប្រាំមួយថតក្នុងរយៈពេល៤៧នាទី ប្រហែលជា៣០០នាទី។ បាទ ប្រាំមួយ -- សូមលោករំឭកឡើងវិញបន្តិចមើល នៅពេលលោកអង្គុយទល់មុខជាមួយ ខៀវ សំផន ហើយលោកសួរសំណួងអ៊ីចឹង លោកមានអារម្មណ៍យ៉ាងម៉េចដែរក្នុងខ្លួនលោក? លោកសួរអំពី ហ៊ូ នឹម, ហ៊ូ យន់ អ៊ីចឹង លោកមានអារម្មណ៍យ៉ាងម៉េចក្នុងខ្លួនលោកហ្នឹង?

**ឆ៖** ខ្ញុំបានដឹងថា ខ្ញុំគ្មានទោសពៃរ៍អីទេ។ ខ្ញុំគិតថាគាត់ៗមិនបានដឹងថាខ្ញុំរៀបចំនូវខ្សែចង្វាក់សំណួរបែបនេះទេ ជាពិសេសដោយសារខ្សែចង្វាក់នៃសំណួរនេះ គឺវាល្អិតល្អន់ ហើយវាឆ្លុះបញ្ចាំងនូវការដឹងឮអំពីរចនាសម្ព័ន្ធអង្គការចាត់តាំងនេះរួចទៅហើយ ខ្ញុំដឹងអំពីដំណើររបស់វាហើយ។ អ៊ីចឹងដូចដែលខ្ញុំជម្រាបជូនហើយ វាជាការតទល់មុខគ្នារវាងគាត់និងខ្ញុំ គឺថាវាហាក់បីដូចជាមានអារម្មណ៍រន្ធត់រវាងភាគីទាំងពីរ។

**លោក ឃីត រេយ៉ន័រ៖**

ដោយសារតែពេលវេលានេះ ខ្ញុំសូមជម្រាបថា ខ្ញុំសល់ពីរទំព័រទៀត ប្រហែលជាមានពីរ ឬបីសំណួរទេ បើសិនណាបង្កលក្ខណៈនេះទៅបាន។ លោកប្រធានខ្ញុំសូមការអនុញ្ញាត សូមបន្តតែពីរបីសំណួរទៀតទេ ខ្ញុំសូមការអនុញ្ញាតបាទ។

[១៦:០៤:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត. សូមអញ្ជើញ!

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ខ្ញុំបន្តជាមួយសៀវភៅគឺឯកសារ D366/17.1.14 យោងត្រង់អង់គ្លេស ERN

00087794, ខ្មែរ 00711416 ដល់ 7, បារាំង 00722091។ លោកបាននិយាយនៅក្នុងសៀវភៅនេះ និងការឆ្លើយតបទៅនឹងសំណួរដែលឆ្នាំមកហើយនោះ សំណួរដែលយើងបានពិនិត្យមើល ខៀវ សំផន មន្ទីរមុខងារជាអនុប្រធាននៃកម្ពុជាប្រជាធិបតេយ្យ ក្រសួងការបរទេសបានចេញឯកសារនៅថ្ងៃទី១៥ កក្កដា ឆ្នាំ១៩៧៨។ ខ្ញុំសួរថាតើនេះជាការយោងត្រឹមត្រូវទៅនឹងកាលបរិច្ឆេទ ដែលត្រឹមត្រូវទេ ឬក៏អាចឆ្នាំ១៩៨៧?

**ផ៖** បាទ គឺថាដូចក្នុងលេខ*ហ្វូតណូត*អ៊ីចឹង គឺ១៩៨៧ ដែលត្រឹមត្រូវនោះបាទ។

**ស៖** ខ្ញុំមិននិយាយលម្អិតទេ ប៉ុន្តែលោកនិយាយថានៅខាងក្រោមពីរបីប្រយោគហ្នឹងគឺថាអាចឃើញថាមានការកាប់សម្លាប់ច្រើនជាងដែលលោក ខៀវ សំផន ទទួលស្គាល់ក្នុងឆ្នាំ១៩៨០ ក៏ដូចជាការស្លាប់ដោយការអត់អាហារ ការកាប់សម្លាប់ ថាជាជនក្បត់ជាតិ ប៉ុន្តែមនុស្សដែលត្រូវបានសម្លាប់ខុសនោះ គឺមិនមែនជាភ្នាក់ងាររបស់វៀតណាមទេ។ ប៉ុន្តែឯកសារហ្នឹង គឺត្រូវតែធ្វើការវាយតម្លៃមិនត្រូវច្រើនដែលថាការស្លាប់សរុបហ្នឹង គឺថាអាចជាការប៉ុនប៉ងចោទទៅលើការអត់ឃ្លាន ហើយនិងការចោទថាជាអ្នកនោះជាខ្មាំង។ ឯកសារ E3/703 ក្នុងសំណុំរឿង ខ្ញុំមិនពន្យល់បន្ថែមទេ គឺពិនិត្យមើលតែ--។

[១៦:០៧:០៥]

ខ្ញុំសូមអាននៅក្នុងអត្ថបទនេះ៖ "ខៀវ សំផន គ្រាន់តែបញ្ជាក់ដដែល គឺថាគាត់មិនបានគាំទ្រ ហើយគាត់បានធ្វើការជាមួយ ប៉ុល ពត។ ហើយនយោបាយដែលបរាជ័យ ហើយគាត់បាននិយាយបំភ្លឺអំពីតួនាទី អំពើ និយាយអំពីការឧក្រិដ្ឋក្នុងនយោបាយក្នុងការសម្លាប់នោះ។ ហើយគាត់និយាយថាគោលនយោបាយរបស់ ប៉ុល ពត ជោគជ័យក្នុងការកែលម្អជីវភាពប្រជាជន ហើយគាត់បានថានៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាច ជីវិតរបស់គេបានប្រសើរឡើង។ អ្នកទាំងអស់នោះ គឺមានបាយគ្រប់គ្រាន់ សម្លៀកបំពាក់ស្លៀកពាក់ ហើយសុខភាពរបស់គេគឺបានល្អជាបន្តបន្ទាប់តាំងពីឆ្នាំ១៩៧៦។ ហើយជីវភាពកាន់តែកើនរហូតមកដល់ឆ្នាំ១៩៧៨"។

ទាក់ទងទៅនឹងឯកសារនេះ ជើងទំព័រ៨៦ គឺថាមុខតំណែងជាអនុប្រធានកម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកការបរទេស ថាតើការពិត ហើយនិងយុត្តិធម៌អំពីការចោទប្រកាន់ពីការកាប់សម្លាប់រង្គាលតាំងពីឆ្នាំ១៩៧៥ ដល់១៩៧៨ ហើយការកត់ត្រាឯកសារនៅក្នុងដៃរបស់អ្នកនិពន្ធលោក ហេងឌ័រ តើៗឯកសារនេះលោកទទួលបានដោយរបៀបណា?

[១៦:០៨:៥០]

**ឆ៖** នៅក្នុងករណីពិសេសមួយនេះ តាមដែលខ្ញុំចងចាំគឺថាជនជាតិខ្មែរអាមេរិកកាំង ឈ្មោះ កែម សុះ ជាអ្នកឲ្យខ្ញុំ។ ខ្ញុំគិតថានៅពេលនេះ គាត់ធ្វើការនៅ ជាមន្ត្រីការបរទេសរបស់សហរដ្ឋអាមេរិកម្នាក់ដែរ។ គាត់ជានយោជិករបស់ស្ថានទូតអាមេរិកនៅបាងកក ដែលធ្វើការនៅព្រំដែនខ្មែរ-ថៃ។

**ស៖** ដើម្បីបញ្ជាក់ថាយើងនិយាយឯកសារតែមួយ គឺនិយាយពី*ថេប*ទី៧។ ឯកសារ E3/703 តើនេះឯកសារដែលលោកបានទទួលដែរឬទេ? ខ្ញុំមិនដឹងថាឯកសារដើមជាខ្មែរ ឬអង់គ្លេស។ ប៉ុន្តែយើងឃើញនេះជាភាសាអង់គ្លេស សូមលោកជម្រាបតុលាការមើល៍ តើដូចម្ដេច?

**ឆ៖** ជាឯកសារដដែលទេ គឺខ្លឹមសារដដែល។ ខ្ញុំច្បាស់ថា ដែលមានចំណារ យុ ឆាំង នៅលើនោះ គឺដែលខ្ញុំបានទទួល ហើយគាត់បានចំណារនៅលើនោះ ប៉ុន្តែនេះជាឯកសារតែមួយនោះឯង ទាក់ទងទៅនឹងដែលថាមានខ្លឹមសារដូចគ្នា ច្បាប់ដើមគឺជាភាសាអង់គ្លេស។ មិនមែនច្បាប់ដើមទេ ប៉ុន្តែគេបកប្រែពីខ្មែរទៅជាអង់គ្លេស ដែលសរសេរ -- ក្រោយមកគឺគេមានជាភាសាខ្មែរ។

[១៦:១០:៥១]

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ដែលបានផ្ដល់ពេលឲ្យខ្ញុំហួសពេលបន្តិច។ សូមអរគុណលោកសាក្សី ហេងឆ័រ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ហេងឆ័រ។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៥ ខែកក្កដា ឆ្នាំ២០១៣ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយនៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឆ័រ។ សូមភាគីនៃរឿងក្ដី មន្ត្រី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

លោក ស៊ីវ ហេងឆ័រ ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើបន្តសវនាការស្ដាប់សក្ខីកម្មរបស់លោក នៅថ្ងៃចន្ទសប្ដាហ៍ក្រោយទៀត។ ដូច្នេះអង្គជំនុំជម្រះសូមកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទ ទី១៥ ខែកក្កដា ដើមសប្ដាហ៍ក្រោយទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

[១៦:១១:៥៥]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ស៊ីវ ហេងឆ័រ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទ ទី១៥ ខែកក្កដា ដើមសប្តាហ៍ក្រោយនៅវេលាម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ និងឲ្យនាំខ្លួនពួកគាត់ត្រឡប់ចូលរួមសវនាការវិញនៅព្រឹកថ្ងៃចន្ទ ទី១៥ ខែកក្កដា ឲ្យមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី)*